# ស្វែងរកការពិត

៧

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



# បន្តការសួរដេញដោល និងពិនិត្យ ភស្តុតាងក្នុងសំណុំរឿង ០០២

ខែមីនា ឆ្នាំ២០១២

## មាតិកា


បន្តការសួរដេញដោល និងពិនិត្យ ភស្តុតាងក្នុងសំណុំរឿង០០២ ១

ការជំទាស់លើឯកសារពាក់ព័ន្ធនឹង សវនាការដំណាក់កាលដំបូង ១១

សក្ខីកម្មរបស់នាយករង មជ្ឈមណ្ឌលឯកសារកម្ពុជា ៣២

ការសួរដេញដោលលើ សាក្សី ប្រាក់ យុត ៣២



ក្រុមស្វែងរកការពិត ៖

ផាយ ឈុនលី, ឌី សុផាត,

លឹម ជ័យច័ន្ទ និង ចាន់ ប្រាថ្នា



# ទង់ បដិវត្ត

លេខ ៦ មិថុនា ១៩៧៦

# បន្តសវនាការស្តីពីការសួរដេញដោល និងពិនិត្យភស្តុតាងក្នុងសំណុំរឿង០០២
## ថ្ងៃទី១០-១២ ខែមករា ឆ្នាំ២០១២

*ដោយ លុនលី, ឌី សុជាតា, ចាន់ ប្រាថ្នា និង លីម ជ័យទ័ត្ត*

### សេចក្តីផ្តើម

នៅថ្ងៃទី១០-១២ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តសវនាការសួរដេញដោលចំពោះជនជាប់ចោទ នួន ជា និងដើមបណ្តឹងរដ្ឋប្បវេណីពីររូប ដែលមិនទាន់បានបញ្ចប់ការធ្វើសក្ខីកម្មនៅឡើយកាលពីសវនាការខែធ្នូ ឆ្នាំ២០១១ កន្លងមក ។ នៅក្នុងសវនាការទាំងបីថ្ងៃនេះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាបន្តធ្វើការសាកសួរទៅលើជនជាប់ចោទ នួន ជា និងផ្តល់ឱកាសជូនក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងបីរូបបន្តធ្វើការសាកសួរទៅដើមបណ្តឹងរដ្ឋប្បវេណី រ៉ោម យុន និង ក្លាន វិត ។

### ១) ការឆ្លើយតបរបស់ នួន ជា

ថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ មុនពេលចាប់ផ្តើមសួរសំណួរដោយសហព្រះរាជអាជ្ញាលើជនជាប់ចោទ នួន ជា មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា គឺលោក ម៉ៃឃើល ជេស្តមេន បានលើកឡើងអំពីសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងសន្និសីទកាសែតមួយនៅប្រទេសវៀតណាមដោយបានថ្លែងចោទប្រកាន់ថា នួន ជា ជា "ឃាតករ" និងជា "ចារីនៃបទប្រល័យពូជសាសន៍" ។ លោកមេធាវីបានស្នើសុំឲ្យតុលាការសម្រេចច្រានចោលសេចក្តីថ្លែងការណ៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសារការធ្វើបែបនេះនឹងនាំឲ្យប៉ះពាល់ដល់គោលការណ៍ច្បាប់ដែលចែងអំពីការសន្មតថាគ្មានទោសរហូតដល់ពេលត្រូវបានរកឃើញថាមានពិរុទ្ធភាព ។ លោកមេធាវីបានបន្តទៀតថា វានឹងធ្វើឲ្យប៉ះពាល់ដល់កិច្ចការរដ្ឋបាល និងឯករាជ្យភាពរបស់តុលាការ ព្រមទាំងធ្វើឲ្យមានការលម្អៀងដល់ការជម្រះក្តីប្រកបដោយយុត្តិធម៌ ។ ប៉ុន្តែការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា មិនត្រូវបានឆ្លើយតបដោយអង្គជំនុំជម្រះឡើយ ។ មុនពេលការចាប់ផ្តើមសំណួរ ជនជាប់ចោទ នួន ជា បានស្នើសុំទៅអង្គជំនុំជម្រះអនុញ្ញាតឲ្យខ្លួនធ្វើសក្ខីកម្មត្រឹមតែពេលព្រឹក ហើយសុំសម្រាកនៅពេលរសៀលដោយលើកឡើងពីបញ្ហាសុខភាព ។ បន្ទាប់មកអង្គជំនុំជម្រះក៏បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាចាប់ផ្តើមសួរសំណួរទៅលើជនជាប់ចោទ នួន ជា ។ សំណួរដែលចោទសួរទៅជនជាប់ចោទ នួន ជា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ឌេល លីសាក់ បានផ្តោតជាសំខាន់ទៅលើទស្សនាវដ្តីទង់បដិវត្ត និងការធ្វើមហាសន្និបាតទាំងពីរលើករបស់បក្សកុម្មុយនីស្តកម្ពុជា ដែលក្នុងនោះរួមមានការអនុម័តមាគ៌ានយោបាយរបស់បក្ស និងសមាសភាពអ្នកចូលរួមនៅក្នុងមហាសន្និបាត ។

#### ក) ទស្សនាវដ្តីទង់បដិវត្ត

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក ឌេល លីសាក់ បានអានសេចក្តីដកស្រង់ខ្លឹមសារមួយចំនួនចេញពីទស្សនាវដ្តីទង់បដិវត្តដើម្បីឲ្យជនជាប់ចោទ នួន ជា ធ្វើការឆ្លើយតប ឬអត្ថាធិប្បាយលើខ្លឹមសារនោះ ។ ជាការឆ្លើយតប ជនជាប់ចោទ នួន ជា ស្នើឲ្យព្រះរាជអាជ្ញាធ្វើការបង្ហាញនូវឯកសារទាំងនោះដោយផ្ទាល់ដើម្បីឲ្យខ្លួនបានពិនិត្យនិងឆ្លើយតបបាន ។ តំណាងសហព្រះរាជអាជ្ញាបានយល់ព្រមទៅនឹងការស្នើសុំ និងបានប្រគល់ឯកសារថតចម្លងនៃទស្សនាវដ្តីទង់បដិវត្តទៅឲ្យជនជាប់ចោទ នួន ជា ដើម្បីពិនិត្យ ប៉ុន្តែជនជាប់ចោទ នួន ជា បដិសេធឯកសារថតចម្លងទាំងនោះ ដោយទាមទារឲ្យសហព្រះរាជអាជ្ញាធ្វើការបង្ហាញនូវទស្សនាវដ្តីទង់បដិវត្តជាច្បាប់ដើម ដើម្បីឲ្យប្រាដកថាជាទស្សនាវដ្តីដែលបោះពុម្ពនោះ គឺធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា កត់សម្គាល់បន្ថែមថា ទស្សនាវដ្តីទង់បដិវត្តដែលបក្សបានធ្វើគឺសរសេរដោយដៃនៅលើក្រដាសក្រមួនមិនមែនបោះជាអក្សរ

ពុម្ពឡើយ ហើយទំហំអក្សរធំៗ គឺមិនមែនតូចដូចដែលបង្ហាញនៅក្នុងឯកសារដែលខ្លួនកំពុងមើលនោះឡើយ ។ បន្ថែមលើកូនក្ដីរបស់ខ្លួនលោក មេធាវី សុន អារុណ បានលើកឡើងថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវអនុវត្តតាមច្បាប់កម្ពុជា ពោលគឺតុលាការត្រូវបង្ហាញឯកសារដើមនៅចំពោះមុខភាគី ។ ភ្លាមៗនោះ ប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម និល ណុន បានបដិសេធលើសំណើខាងលើ ដោយលោកបានផ្ដល់ការណែនាំថា សំណុំរឿង ០០២ គឺជាសំណុំរឿងដែលមានទំហំធំ ហើយមានឯកសារជាងកន្លះលានទំព័រ ដូច្នេះតុលាការមិនអាចយកឯកសារទាំងនោះមកដាក់នៅចំពោះមុខភាគីទាំងអស់បានទេ ។ តែទោះជាយ៉ាងណាឯកសារទាំងនោះត្រូវបានថតចម្លងចូលក្នុងប្រព័ន្ធឯកសារអេឡិចត្រូនិចរួចរាល់ហើយ និងបានយកទៅរក្សាទុកនៅកន្លែងដើមវិញ ។ ដូច្នេះរាល់ការបង្ហាញឯកសារណាមួយនៅចំពោះមុខគូភាគីនឹងត្រូវធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដែលការធ្វើបែបនេះត្រូវបានអនុវត្តនៅក្នុងសំណុំរឿង០០១រួចមកហើយ ហើយការអនុវត្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀតក៏មានលក្ខណៈដូចគ្នានេះដែរ ។ ម៉្យាងវិញទៀត ក្នុងករណីជនជាប់ចោទ នួន ជា មិនព្រមឆ្លើយនឹងសំណួរ ដោយមូលហេតុទាមទាររកឯកសារច្បាប់ដើម ត្រូវចាត់ទុកថាជនជាប់ចោទរក្សាសិទ្ធិមិនឆ្លើយតប និងអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាចសួរសំណួរបន្ទាប់លើខ្លឹមសាររបស់ឯកសារ ។

បន្ទាប់ពីទទួលបានការណែនាំរបស់ប្រធានអង្គជំនុំជម្រះ ជនជាប់ចោទ នួន ជា ឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងគោលបំណងនៃការបង្កើតទស្សនាវដ្ដីទង់បដិវត្តថា ទង់បដិវត្តត្រូវបានបង្កើតឡើងដោយគណៈអចិន្ត្រៃយ៍ នៅមុនកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ។ គោលបំណងនៃការបង្កើតទង់បដិវត្ត គឺដើម្បីអប់រំដល់កម្មាភិបាលរបស់បក្ស ដោយសារពេលនោះមានភាពច្របូកច្របល់ជាច្រើន ពោលគឺមានកម្មាភិបាលមួយចំនួនបានរត់ចោលជួរ និងមានមួយចំនួនបានទៅសារភាព និងរត់ចូលខ្មាំងរបស់បក្សជាដើម ។ នួន ជា បានបញ្ជាក់ថា នៅក្នុងកំឡុងពេលនោះ ទង់បដិវត្តត្រូវបានសរសេរដោយដៃនៅលើក្រដាសក្រមួន តែមកដល់របបកម្ពុជាប្រជាធិបតេយ្យ ទង់នេះត្រូវបានបោះជាអក្សរពុម្ព ដោយសារពេលនោះបក្សមានរោងពុម្ពត្រឹមត្រូវហើយ ។ ចាប់ពីពេលនោះមក ទង់បដិវត្តត្រូវបានជំនួសដោយទង់ក្រហមវិញ ។ ទស្សនាវដ្ដីទាំងពីរមានខ្លឹមសារប្រហាក់ប្រហែលគ្នា តែខុសគ្នាត្រង់ទស្សនាវដ្ដីទង់ក្រហមមានទង់ក្រហមចំនួនប្រាំរីឯទស្សនាវដ្ដីទង់បដិវត្តមានទង់តែមួយ ។

## ១) មហាសន្និបាតបក្សប្រជាជនបដិវត្តន៍ខ្មែរលើកទី១

ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា ក្រោយពីការចុះចូលរបស់ ស៊ីវ ហេង ជាមួយនឹងរដ្ឋាភិបាល លន់នល់ នៅក្នុងឆ្នាំ១៩៥៩ សមាជិកបក្សនៅសល់តែបុគ្គលប៉ុន្មាននាក់តែប៉ុណ្ណោះ នៅក្នុងនោះរួមមាន ទូ សាមុត សាឡុត ស មី ម៉ាន់ និង នួន ជា ខ្លួនឯងផ្ទាល់ ។ ទូ សាមុត មានតួនាទីជាប្រធានបក្ស នួន ជា មាននាទីជាអ្នកទទួលខុសត្រូវ និងក្ដាប់សភាពការណ៍នៅជនបទ រីឯ ប៉ុល ពត និង មី ម៉ាន់ ត្រូវបានចាត់តាំងឲ្យក្ដាប់សភាពការណ៍នៅទីក្រុងដើម្បីរៀបចំមាគ៌ានយោបាយជាយុទ្ធសាស្ត្រ និងយុទ្ធវិធី ។ នៅមហាសន្និបាតបក្សលើកទី១ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ទូ សាមុត ត្រូវបានជ្រើសតាំងជាលេខាបក្ស នួន ជា ជាអនុលេខាបក្សទទួលភារកិច្ចខាងអប់រំ និងទាក់ទងជាមួយប្រទេសវៀតណាម ចំណែកឯ សាឡុត ស ត្រូវបានជ្រើសតាំងឲ្យទទួលបន្ទុកខាងទាក់ទងក្រុមបញ្ញាជន ហើយ មី ម៉ាន់ បានដកខ្លួនចេញពីបក្សដោយសារតែស្ថានភាពគ្រួសារ ។ ក្រោយមកមានតែសមាជិកបីនាក់ប៉ុណ្ណោះ ដែលនៅបន្តធ្វើការ និងពង្រីកសមាជិកបក្សតាមរយៈការទាក់ទងជាមួយកម្មាភិបាលចាស់ៗ ដូចជានៅភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរជាដើម ។

ជនជាប់ចោទ នួន ជា បានបន្តបញ្ជាក់ទៅអង្គជំនុំជម្រះទៀតថា សន្និបាតលើកទី១របស់បក្សកុម្មុយនីស្តកម្ពុជាបានធ្វើឡើងមានរយៈពេលបីថ្ងៃ នៅខែកញ្ញា ឆ្នាំ១៩៦០ ដោយការប្រជុំនោះត្រូវបានរៀបចំឡើងនៅក្នុងផ្ទះរបស់លោក អ៊ុក សុគន្ធ ដែលមានទីតាំងនៅម្ដុំរ៉ារទេះភ្លើង ដោយអ្នកចូលរួមទាំងអស់បានស្នាក់នៅទីកន្លែងប្រជុំនោះ ហើយធ្វើឡើងជាសម្ងាត់ ។ ការប្រជុំនេះគឺជ្រើសរើសយកតែប្រធានភូមិភាគប្រហែល៦ទៅ៧នាក់ ដែលតំណាងឲ្យភូមិភាគនីមួយៗឲ្យមកចូលរួមប្រជុំតែប៉ុណ្ណោះ ។ ជនជាប់ចោទ នួន ជា បានអះអាងថា រាល់ការកែប្រែគោលនយោបាយរបស់បក្សគឺមាន

តែមហាសន្និបាតបក្សទូទាំងប្រទេសប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើការកែប្រែបាន ។ ក្រៅពីមហាសន្និបាត គណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ គឺមិនមានសិទ្ធិក្នុងការសម្រេចកែប្រែគោលនយោបាយបក្សបានឡើយ ។

### ក) មាគ៌ាបក្សដែលសម្រេចនៅក្នុងមហាសន្និបាតលើកទី១

ដោយសារតែជនជាប់ចោទ នួន ជា បានបដិសេធមិនព្រមពិនិត្យមើលទៅលើឯកសារដែលសហព្រះរាជអាជ្ញាបង្ហាញពាក់ព័ន្ធនឹងគោលនយោបាយរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរដែលត្រូវបានសម្រេចនៅក្នុងមហាសន្និបាតលើកទី១ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានបង្គាប់ឲ្យក្រឡាបញ្ជី អានឯកសារស្តីពីទង់បដិវត្តទាក់ទងនឹងមហាសន្និបាតលើកដំបូងរបស់បក្សដែលបានបែងចែកប្រភេទជនដែលត្រូវបានបក្សចាត់ទុកថាជាខ្មាំង ។ បន្ទាប់ពីបានស្តាប់ការអានរបស់ក្រឡាបញ្ជី ជនជាប់ចោទ នួន ជា បានបញ្ចេញប្រតិកម្មខ្លាំងៗ ទៅលើពាក្យថា សក្តិភូមិ ដោយបញ្ជាក់ថាៈ

*«មិនមែនមនុស្សសក្តិភូមិទេ គឺរបបសក្តិភូមិប្រតិកិរិយា បរិវារចក្រពត្តិឃោរឃៅ មិនមែនរបបសក្តិភូមិទទេៗ ទេ ។ ដូច្នេះនិយាយមិនអស់សេចក្តី ធ្វើឲ្យតុលាការអាចនឹងភាន់ច្រឡំ ។ និយាយឲ្យអស់សេចក្តីក្នុងឯកសារខ្វាចមិនមែនឯកសារខ្ញុំ ។ សត្រូវវាមានពីរ ទីមួយគឺពួកចក្រពត្តិឈ្លានពាន វាគទី លេបទឹកដី បំបាត់ពូជសាសន៍ ឯមួយទៀតគឺបរិវាររបស់វា ។ ឯសក្តិភូមិនោះ គឺមិនមែនមនុស្សសក្តិភូមិទេ គឺរបបសក្តិភូមិដែលយើងត្រូវតស៊ូបំបាត់ ដូចជាខ្ញុំបាននិយាយហើយ របបសក្តិភូមិនេះ គឺរឿងខ្ទីបុលបណ្តាក់អីអស់នេះ មិនបាច់និយាយទៀតទេ ។ វានៅក្នុងមាគ៌ាអស់ហើយ» ។*

ជនជាប់ចោទ នួន ជា ក៏បានធ្វើការកត់សម្គាល់ចំពោះសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសួរទាក់ទងនឹងពាក្យថា «ពួកខ្ញុំបម្រើចក្រពត្តិ» ដោយបញ្ជាក់ថាៈ

*«ពួកខ្ញុំបម្រើចក្រពត្តិ មានន័យថាក្បត់ជាតិឯង ចូលជាមួយចក្រពត្តិ ធ្វើខ្ញុំបម្រើចក្រពត្តិ ។ ឯពួកប្រតិកិរិយា គឺពួកដែលប្រឆាំង ប៉ុន្តែវាមានច្រើនប្រភេទ ប្រតិកិរិយាឃោរឃៅ ប្រតិកិរិយាដោយចាំបាច់ ប្រតិកិរិយាដោយគេបង្ខំ វាត្រូវបែងចែកច្រើនទៅទៀត ។ ព្រះរាជអាជ្ញាយកតែមួយម៉ាត់មកសួរ ខ្ញុំឆ្លើយមិនអស់ទេ ហើយវាមិនត្រឹមត្រូវផង» ។*



ជនជាប់ចោទ នួន ជា បានធ្វើការបដិសេធទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលថា របបកម្ពុជាប្រជាធិបតេយ្យចាត់ទុកមន្ត្រីនៃរបប លន់ នល់ ជាផ្នែកនៃពួកចក្រពត្តិនិយម និងជាសត្រូវ និងបានស្នើឲ្យសហព្រះរាជអាជ្ញាត្រូវតែធ្វើការបែងចែកឲ្យបានច្បាស់លាស់ «គឺមិនមែនឲ្យតែពួកអភិជន ឬពួកសក្តិភូមិទាំងអស់សុទ្ធតែជាសត្រូវទាំងអស់ទេមានអ្នកខ្លះល្អអ្នកខ្លះស្នេហាជាតិដែរ ។ បើចាត់ទុកពួកនេះជាសត្រូវទាំងអស់នោះ ជាតិយើងបែកបាក់ខ្ទេចខ្ទីអស់ហើយ ។ បើលោកលើកយកតែមួយចំណុចមកសួរខ្ញុំដូចនេះវាពិបាកឆ្លើយណាស់ ព្រោះក្នុងមាគ៌ាបាននិយាយលម្អិត» ។ នួន ជា បានបន្តទៀតថា :

«មិនមែនឲ្យតែតាំងពីនាម៉ឺន កុងសី ចៅហ្វាយស្រុក រហូតដល់មេភូមិ មេឃុំ ជិទប់ ស្មៀន នោះសុទ្ធតែជាសត្រូវនោះទេ ។ សត្រូវគឺពួកសក្តិភូមិ ប្រតិកិរិយាឃោរឃៅផុតលេខ បើម៉ោទាំងអស់ថាជាសត្រូវនោះ អស់អ្នកធ្វើបដិវត្តហើយ ។ គោលការណ៍បក្សនោះគឺបន្ថយសត្រូវបន្ថែមមិត្តជាអតិបរមា និងប្រមូលអ្នកស្នេហាជាតិឲ្យបានច្រើន ទោះបីជាវណ្ណៈអ្វីក៏ដោយឲ្យតែមានស្មារតីស្នេហាជាតិ ។ ប្រមូលគ្រប់កម្លាំងស្នេហាជាតិ ឬកម្លាំងអព្យាក្រឹត្យដែលមិនចូលបក្សខាងណានោះក៏ប្រមូលដែរ» ។

សហព្រះរាជអាជ្ញាបានស្នើសុំឲ្យជនជាប់ចោទ នួន ជា ធ្វើការបញ្ជាក់អំពីទំនាស់រវាងក្រុមអភិជន និងក្រុមម្ចាស់ដីដែលបក្សយល់ថាជាទំនាស់មួយស្រួចស្រាល់ និងបានកំណត់នៅក្នុងមហាសន្និបាតលើក ទី១ ។ ប៉ុន្តែ នួន ជា បានបដិសេធសំណើនេះដោយអះអាងថា គោលការណ៍បក្សមិនដែលចាត់ទុកពួកសក្តិភូមិ ឬអភិជនជាសត្រូវនោះទេ ហើយថែមទាំងបានឆ្លើយតបទៅកាន់សហព្រះរាជអាជ្ញាអន្តរជាតិដែលកំពុងសួរដេញដោលមកលើខ្លួនថា «លោកមិនដែលស្គាល់អ្នកក្រទេ លោកទៅមើលអ្នកក្រនៅ[ស្រុក]អមលាំងឯណោះ នៅប្រាំបីម៉ុងឯណោះយ៉ាងម៉េចខ្លះ» ។ តែការលើកឡើងនេះត្រូវបានលោកប្រធានអង្គជំនុំជម្រះសាលាដំបូងរំពុកដាស់តឿនឲ្យជនជាប់ចោទ នួន ជា ឆ្លើយតែសំណួរដែលសហព្រះរាជអាជ្ញាសួរប៉ុណ្ណោះ ចំពោះសំណួរណាដែលជនជាប់ចោទមិនមានបំណងឆ្លើយ ខ្លួនអាចបដិសេធនឹងសំណួរនោះបាន ។ ឆ្លើយតបទៅលោកប្រធានអង្គជំនុំជម្រះវិញ ជនជាប់ចោទ នួន ជា លើកឡើងថា ខ្លួនគ្រាន់តែលើកជាឧទាហរណ៍តែប៉ុណ្ណោះ ព្រោះការរស់នៅរបស់អ្នកក្រ និងអ្នកមាន គឺមានទស្សនៈផ្សេងគ្នា ។

ជនជាប់ចោទ នួន ជា បានព្យាយាមបដិសេធមិនឆ្លើយតបទៅនឹងសំណួរដែលសហព្រះរាជអាជ្ញាបានចោទសួរទាក់ទងទៅនឹងការកាន់ដំណែងជំនួស ប៉ុល ពត ក្នុងករណីដែល ប៉ុល ពត មានជំងឺ ដូចជាតំណែងនាយករដ្ឋមន្ត្រីស្តីទី និងតួនាទីក្នុងការថ្លែងសុន្ទរកថានៅក្នុងពិធីរំពុកខួបកងទ័ពប្រជាជនបដិវត្តន៍ជាដើម ។ នួន ជា បញ្ជាក់ថាខ្លួនមិនដែលធ្លាប់បានធ្វើជានាយករដ្ឋមន្ត្រីជំនួស ប៉ុល ពត នៅពេលដែល ប៉ុល ពត មានជំងឺឡើយ ។ ការពិតខ្លួន និង ប៉ុល ពត មានគោលបំណងបណ្តុះបណ្តាល សុន សេន ដើម្បីបន្តតំណែងពី ប៉ុល ពត ដោយសារនៅពេលនោះ សុន សេន ជាប្រធានសេនាធិការមានភារកិច្ចខាងយោធាស្រាប់ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ឌេល លីសាក់ បានអានឯកសារទាក់ទងនឹងមហាសន្និបាតក្នុងឆ្នាំ១៩៦០ដែលមានសរសេរនៅក្នុងទង់បដិវត្ត និងដាក់បញ្ចាំងរូបភាពនៃឯកសារទាំងនោះនៅលើអេក្រង់កុំព្យូទ័រដែលមាននៅចំពោះមុខជនជាប់ចោទ ប៉ុន្តែ នួន ជា បានបដិសេធនូវរាល់ឯកសារដែលបានដាក់បញ្ចាំង ហើយទាមទាររកឯកសារដើមដែលសហព្រះរាជអាជ្ញាបានបង្ហាញនោះ ។ បន្ទាប់មកជនជាប់ចោទ នួន ជា បានបញ្ជាក់ពីគោលជំហររបស់ខ្លួនក្នុងការមិន ឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទង់បដិវត្ត ដោយបានប្រើប្រាស់សិទ្ធនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួររបស់ភាគី ។ អង្គជំនុំជម្រះបានបញ្ជាក់ទៅជនជាប់ចោទ នួន ជា ថាទោះបីជាជនជាប់ចោទប្រើប្រាស់សិទ្ធិមិនឆ្លើយតបទៅនឹងឯកសារទង់បដិវត្តក៏ដោយ ឯកសារនេះត្រូវបានសម្រេចដាក់ឲ្យដេញដោលនៅចំពោះមុខអង្គជំនុំជម្រះរួចរាល់ហើយ ។

## ឃ) មហាសន្និបាតលើកទី២

នួន ជា បានឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលបានសួរទាក់ទងនឹងមហាសន្និបាតលើកទី២ថា មហាសន្និបាតបក្សលើកទី២បានរៀបចំធ្វើឡើងនៅក្នុងឆ្នាំ១៩៦៣ ក្នុងផ្ទះល្វែងមួយនៅមុំផ្លូវសាលដឺហ្គោល ដោយចំនួនអ្នកចូលរួមនៅ

ក្នុងមហាសន្និបាតបក្សលើកទី២នេះ មានចំនួនច្រើនជាងអ្នកចូលរួមនៅក្នុងមហាសន្និបាតលើកទី១ ។ ជនជាប់ចោទ នួន ជា បានពន្យល់ថា តួនាទី និងដំណែងរបស់សមាជិកនៅក្នុងបក្ស គឺធ្វើឡើងដោយការជ្រើសតាំង ការតែងតាំង និងការបោះឆ្នោត ។

បញ្ហាសំខាន់ដែលបានសម្រេចនៅក្នុងមហាសន្និបាតលើកទី២នេះ គឺការជ្រើសតាំងសមាជិកគណៈមជ្ឈិម និងសមាជិកគណៈអចិន្ត្រៃយ៍ថ្មី ដោយពេលនោះ ប៉ុល ពត ត្រូវបានជ្រើសតាំងជាលេខាបក្ស នួន ជា ត្រូវបានជ្រើសតាំងជាអនុលេខាបក្ស និង អៀង សារី ត្រូវបានដាក់បញ្ចូលជាសមាជិក នៃគណៈអចិន្ត្រៃយ៍ ដោយមហាសន្និបាតលើកទី២នេះ ។ ជនជាប់ចោទ នួន ជា បានឆ្លើយតបទៅនឹង សំណួររបស់លោកសហព្រះរាជអាជ្ញា ខេល លីសាក់ ទាក់ទងនឹងមូលហេតុនាំឲ្យបក្សមិនជ្រើសយកខ្លួនធ្វើជាលេខាបក្សថា ដោយសារតែ នួន ជា មានជាប់សាច់ញាតិជាមួយនឹង ស៊ីវ ហេង ដែលត្រូវបានចោទប្រកាន់ថាជាជនក្បត់បក្ស ហើយម្យ៉ាងទៀតគឺដោយសារ ប៉ុល ពត មានសមត្ថភាពជាងខ្លួន ទើបធ្វើឲ្យបក្សសម្រេចជ្រើសរើស ប៉ុល ពត ធ្វើជាលេខាបក្ស ។

នៅមុនពេលបញ្ចប់នៃការសាកសួរ ភាគច្រើននៃចម្លើយដែលជនជាប់ចោទ នួន ជា បានឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា គឺពាក្យថាមិនបានចងចាំពីព្រឹត្តិការណ៍ទាំងឡាយដែលចោទសួរ ដោយសហព្រះរាជអាជ្ញាឡើយ ។ ជនជាប់ចោទ នួន ជា ក៏បានស្នើទៅសហព្រះរាជអាជ្ញាឲ្យធ្វើការកំណត់ពីពេលវេលា និងព្រឹត្តិការណ៍ឲ្យបានច្បាស់លាស់នៅក្នុងសំណួររបស់ខ្លួន ។

## ២) អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសាកសួរដើមបណ្តឹងរដ្ឋប្បវេណី

នៅពេលរសៀលថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណីពីររូប គឺលោក ក្លាន វិត និងលោក រម៉ាម យុន ដែលត្រូវបានតុលាការផ្អាកកិច្ចដំណើរការសាកសួរកាលពីសវនាការថ្ងៃទី៩ ដល់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដោយសារតែបញ្ហាសុខភាពរបស់អ្នកទាំងពីរ ។ ដំបូងអង្គជំនុំជម្រះបានកោះហៅលោក រម៉ាម យុន ដើម្បីផ្តល់សក្ខីកម្ម និងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងបីរូប បន្តធ្វើការសួរដេញដោល ។

មេធាវីការពារក្តីជនជាប់ចោទ នួន ជា បានក្រោកឈរបញ្ជាក់ប្រាប់ទៅអង្គជំនុំជម្រះថាខ្លួនមិន មានសំណួរសួរទៅលោក រម៉ាម យុន ឡើយ ដោយសារតែសក្ខីកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានធ្វើកាលពីខែធ្នូកន្លងទៅ មិនមានតំលៃជាភស្តុតាងចោទប្រកាន់ចំពោះកូនក្តីរបស់ខ្លួននោះទេ ។ ឆ្លើយតបនឹងការលើកឡើងរបស់មេធាវីការពារក្តី នួន ជា មេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វត បានលើកឡើងថា ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺធ្វើឡើងមិនត្រឹមតែមានគោលបំណងក្នុងការទាមទារសំណងនោះទេ ប៉ុន្តែថែមទាំងបានលាតត្រដាងនូវការពិតរបស់ជនរងគ្រោះផងដែរ ។

ទាក់ទងនឹងបញ្ហាដដែលនេះ លោក អាង ឧត្តម មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី បានកត់សម្គាល់ថា អង្គជំនុំជម្រះគួរតែធ្វើការបែកចែកតួនាទីឲ្យច្បាស់រវាងដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ និងស្នើសុំឲ្យអង្គជំនុំជម្រះធ្វើមោឃៈភាពរាល់សក្ខីកម្មរបស់លោក រម៉ាម យុន ។ ប៉ុន្តែសំណើនេះត្រូវបានជំទាស់ដោយលោក ពេជ អង្គ មេធាវីនាំមុខជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយលោកបានលើកឡើងថា បើយោងតាមវិធាន២៣[១] នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

[១] វិធាន២៣(១) ៖ គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី៖

ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញដោយគាំទ្រដល់ការចោទប្រកាន់ និង

ខ) ទាមទារសំណងផ្លូវចិត្ត និងសមូហភាពដូចមានចែងនៅក្នុងវិធាន២៣ស្ទួនបួន» ។

គឺគាត់មានសិទ្ធិរៀបរាប់រាល់អង្គហេតុ ដែលគាត់បានទទួលរងនិងអង្គហេតុដែលគាត់បានដឹង ។ តំណាងសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ទៅសំណើរបស់ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទថា សវនាការនាពេលនេះគឺធ្វើឡើងដើម្បីទុកពេលឲ្យក្រុមមេធាវីការពារក្តីធ្វើការសាកសួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីមិនមែនសម្រាប់ធ្វើការបង្ហាញពីការយល់ឃើញរបស់ខ្លួនទាក់ទងនឹងសមត្ថភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ដើម្បីដោះស្រាយបញ្ហានេះ ប្រធានអង្គជំនុំជម្រះលោកចៅក្រម និល ណុន បានសួរទៅក្រុមមេធាវីការពារក្តីថា តើខ្លួនមានសំណួរសួរទៅដើមបណ្តឹងរដ្ឋប្បវេណីដែលឬទេ ដើម្បីកុំឲ្យមានការចំណាយពេលវេលាដោយឥតប្រយោជន៍ ។ បន្ទាប់មកលោកប្រធានចៅក្រមក៏បានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ធ្វើការសាកសួរដេញដោលទៅលើដើមបណ្តឹងរដ្ឋប្បវេណី លោក រម៉ាម យុន ។

***ក) ការបន្តកិច្ចសាកសួរទៅលើដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន***

មេធាវីការពារក្តី អៀង សារី បានសួរសំណួរទៅកាន់លោក រម៉ាម យុន តាមរយៈការបង្ហាញឯកសារដែលមាននៅក្នុងសំណុំរឿងដូចជា ឯកសារស្តីពីបទសម្ភាសន៍រវាងមន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតជាមួយនឹងលោក រម៉ាម យុន ដើម្បីប្រៀបធៀបចម្លើយដែលមានក្នុងឯកសារបទសម្ភាសន៍ទាំងនោះជាមួយនឹងចម្លើយដែលធ្វើឡើងផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះ ។ ភាគច្រើននៃចម្លើយដែលឆ្លើយតបទៅក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ហាក់បីដូចជាមានសភាពច្របូកច្របល់ដោយសារតែគាត់មិនចាំពីព្រឹត្តិការណ៍ និងមិនសូវយល់ពីសំណួរដែលចោទឡើង ។ នៅពេលការសួរសំណួរកំពុងតែបន្តមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រោកឈរជំទាស់ទៅនឹងការសួរសំណួររបស់មេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ដោយបានលើកឡើងថា មេធាវីការពារក្តី អៀង សារី កំពុងតែទាញយកផលប្រយោជន៍ពីការបាត់បង់ការចងចាំរបស់លោក រម៉ាម យុន ដោយព្យាយាមសួរសំណួរដើម្បីបំបាត់តំលៃដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទោះបីជាខ្លួនបានដឹងហើយថាលោក រម៉ាម យុន មានវ័យចាស់ជរានិងបាត់បង់ការចងចាំ ។ ប៉ុន្តែការជំទាស់នេះត្រូវបានអង្គជំនុំជម្រះបដិសេធ ដោយបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺត្រូវបានអង្គជំនុំជម្រះជ្រើសរើសចេញពីបញ្ជីឈ្មោះដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូនមកអង្គជំនុំជម្រះ ហេតុនេះអង្គជំនុំជម្រះចាត់ទុកថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះនៅក្នុងបញ្ជីនោះគឺមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការផ្តល់សក្ខីកម្ម ។

បន្ទាប់ពីក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី អង្គជំនុំជម្រះបានផ្តល់វេទិកាសួរដេញដោលនេះទៅក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ប៉ុន្តែក្រុមមេធាវី ខៀវ សំផន បានបញ្ជាក់ថាខ្លួនមិនមានសំណួរសួរទៅកាន់លោក រម៉ាម យុន នោះទេ ដោយសារសក្ខីកម្មរបស់គាត់មិនមានចំណុចពាក់ព័ន្ធនឹងកូនក្តីខ្លួន ។ បន្ទាប់មកលោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រគល់វេទិកា ទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺញ (Jean-Marc LAVERGNE) សួរសំណួរមួយចំនួនទាក់ទងនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងអ្វីដែលគាត់ដឹងទាក់ទងនឹងការជួលរលំនៃទីក្រុងភ្នំពេញ ប៉ុន្តែភាគច្រើននៃសំណួរទាំងអស់នោះត្រូវបានលោក រម៉ាម យុន ឆ្លើយតបទៅវិញថា គាត់មិនចាំព្រឹត្តិការណ៍ទាំងអស់នោះទេ ។ បន្ទាប់ពីបញ្ចប់ការសាកសួរដេញដោលទៅលើដើមបណ្តឹងរដ្ឋប្បវេណីលោក រម៉ាម យុន អង្គជំនុំជម្រះបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតគឺលោក ក្លាន វ៉ិត ដើម្បីបន្តកិច្ចដំណើរការសាកសួរដេញដោល ។

***ខ) ការបន្តកិច្ចសាកសួរទៅលើដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត***

ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត ត្រូវបានបន្តសួរដេញដោលបន្ទាប់ពីការផ្អាកដំណើរការសាកសួរកាលពីសវនាការនាអំឡុងពេលខែធ្នូកន្លងមក ។

***១) សហព្រះរាជអាជ្ញាសាកសួរដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត***

ដើមបណ្តឹងរដ្ឋប្បវេណី លោក ក្លាន វ៉ិត បានរៀបរាប់ប្រាប់សហព្រះរាជអាជ្ញាថា នៅឆ្នាំ១៩៧៥មុនពេលទីក្រុងភ្នំពេញត្រូវបានរំដោះជនជាប់ចោទ អៀង សារី បានហៅលោកឲ្យទៅប្រជុំនៅ

មន្ទីរក-៥ ។ ពេលទៅដល់ទីនោះ អៀង សារី បាននិយាយមកកាន់លោកថា «តើឯងចូលបដិវត្តន៍ទេ មនុស្ស៩០នាក់គេចាំឯងតែមួយថ្ងៃស្មើនឹង៩០ថ្ងៃ តើជាការត្រឹមត្រូវទេ?» លោក ក្វាន វ៉ិត បានបន្តថា ចាប់តាំងពីពេលនោះមក គាត់មានអារម្មណ៍ថាខ្លាចជនជាប់ចោទ អៀង សារី រហូត សូម្បីតែបច្ចុប្បន្ននេះក៏លោកនៅតែខ្លាចដដែល ។ លោក ក្វាន វ៉ិត បានបន្តថា ខ្លួនធ្លាប់បានចូលរួមប្រជុំជាមួយ អៀង សារី ចំនួនពីរលើក លើកទី១គឺនៅភូមិចាយ និងលើកទី២គឺនៅមន្ទីរក-៥ ដោយការប្រជុំនោះមិនមានវត្តមានរបស់មេដឹកនាំផ្សេងទៀតនោះទេ ។

ទាក់ទងទៅនឹងជនជាប់ចោទ នួន ជា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់ប្រាប់ទៅសហព្រះរាជអាជ្ញាថា នៅចន្លោះខែកក្កដា ដល់តុលា ឆ្នាំ១៩៧៥ លោកបានជួបជាមួយនឹងជនជាប់ចោទ នួន ជា ចំនួនពីរលើក នៅពេលដែលលោកចូលរួមនៅក្នុងវគ្គរៀនសូត្រនយោបាយដែលមានអ្នកចូលរួមប្រហែល៤០០នាក់ ។ ពេលនោះលោកមិនដឹងថា នួន ជា មានឋានៈជាអ្វីនោះទេ គ្រាន់តែដឹងថា ពេលខ្លួនមកប្រជុំនោះមានសមាជិកគណៈមជ្ឈិមបានចូលរួមដែលក្នុងនោះរួមមាន ប៉ុល ពត នួន ជា អៀង សារី និងកម្មាភិបាលខ្មែរក្រហមមួយចំនួនទៀត ។ ដែលនៅក្នុងវគ្គរៀនសូត្រនោះមាន នួន ជា គឺជាអ្នកបង្ហឹកដោយបាននិយាយពីគោលការណ៍ និងវិន័យរបស់បក្សកុម្មុយនីស្តកម្ពុជា ។ បក្សក៏បានរៀបចំឲ្យមានការបែងចែកឈ្លបទៅតាមភូមិ ដោយមួយភូមិមាន២០ និងមានកាំភ្លើង២០ដើម ដើម្បីការពារកុំឲ្យខ្មាំងបង្កសង្គ្រាម ។ នៅពេលដែលសហព្រះរាជអាជ្ញាសួរសំណួរទាក់ទងទៅនឹងជនជាប់ចោទ ខៀវ សំផន ដើមបណ្តឹងរដ្ឋប្បវេណី លោក ក្វាន វ៉ិត បានឆ្លើយថា មុនពេលរំដោះទីក្រុងភ្នំពេញខ្លួនមិនដែលបានជួប ខៀវ សំផន នោះទេ គឺគ្រាន់តែធ្លាប់ឮឈ្មោះប៉ុណ្ណោះនៅពេលទៅប្រជុំនៅមន្ទីរក-៥ នៅក្នុងព្រៃ ។ ក្រោយមកពេលទៅប្រជុំនៅភ្នំពេញ លោកបានឃើញខ្មែរក្រហមដឹកប្រជាជនទាំងឡានៗមកពីខេត្តព្រៃវែង និងតាកែវដោយសារតែខ្មែរក្រហមយល់ថាប្រជាជនទាំងនោះរស់នៅជិតព្រំប្រទល់យួន ។ ប្រជាជនដែលជម្លៀសមកពីទីក្រុងភ្នំពេញមានជួបការលំបាកច្រើន ពីព្រោះសូម្បីតែប្រជាជននៅក្នុងភូមិខ្លួនក៏ពិបាកដែរ ពេលមានការប្តូរទីតាំងពីភូមិមួយទៅភូមិមួយទៀត ។

**២) មេធាវីការពារក្តីរបស់ជនជាប់ចោទសាកសួរដើមបណ្តឹងរដ្ឋប្បវេណី ក្វាន វ៉ិត**

**◆ មេធាវីការពារក្តី នួន ជា**

ក្រោយពេលបានស្តាប់ការឆ្លើយសក្ខីកម្មរបស់ដើមបណ្តឹង



រដ្ឋប្បវេណីទាក់ទងនឹងកូនក្ដីរបស់ខ្លួនគឺជនជាប់ចោទ នួន ជា រួចមក មេធាវីការពារក្ដី លោក សុន អារុណ បានសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី លោក ក្វាន វ៉ិត ទាក់ទងនឹងកិនភាគរបស់ជនជាប់ចោទ នួន ជា ដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អះអាងថាបានជួបនៅអំឡុងពេលនៃវគ្គរៀនសូត្រនយោបាយ និងទិដ្ឋភាពនៃការជម្លៀសប្រជាជនដែលលោកបានឃើញ ។ លោក ក្វាន វ៉ិត ឆ្លើយតបទៅនឹងសំណួរទាំងនេះថា ដោយប្រាកដក្នុងចិត្តថា គាត់ពិតជាបានឃើញ នួន ជា នៅក្នុងកិច្ចប្រជុំនោះរៀនសូត្រនោះមែន ។ ទាក់ទងនឹងការជម្លៀសប្រជាជនវិញ នៅពេលលោកទៅប្រជុំនៅភូមិស្រែគរ ខេត្តស្ទឹងត្រែង លោក ក្វាន វ៉ិត បានឃើញគេយក ប្រជាជនដែលមកពីភ្នំពេញប្រហែល៨០០ទៅ៩០០នាក់ ឲ្យទៅលើកទំនប់ទាំងយប់ទាំងថ្ងៃ ដោយសារតែនៅក្នុងភូមិខ្វះកម្លាំងធ្វើការ ។ ពេលដែលគាត់ត្រូវបានគេហៅឲ្យទៅភ្នំពេញនៅឆ្នាំ១៩៧៨ លោក ក្វាន វ៉ិត និយាយថាគាត់បានឃើញទីក្រុងភ្នំពេញមានសភាពស្ងាត់ជ្រងំ មិនមានឡានម៉ូតូអ្វីទេ ។ ឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវី សុន អារុណ ដែលសួរថាតើហេតុអ្វីបានជាលោកសម្រេចចិត្តដាក់ពាក្យបណ្ដឹង លោក ក្វាន វ៉ិត បានឆ្លើយថា ការសម្រេចដាក់ពាក្យបណ្ដឹងដោយសារលោកខឹងនឹងក្រុមមេដឹកនាំខ្មែរក្រហម ។ ដោយលោកបានអះអាងថា «*ឧទាហរណ៍ដូចខ្ញុំឈប់ ខ្ញុំចង់បានរស់ បើថាការអាក្រក់ ការស្អីដូចធ្វើមិនមែនដោយខ្លួនឯង ធ្វើដោយសារអ៊ីៗ តាៗហ្នឹងហើយនាំខ្ញុំធ្វើ ។ ដល់ចុងបំផុតថាមិនល្អទៀត ។ អាហ្នឹងខ្ញុំខឹង ។*»

### ◆ មេធាវីការពារក្ដី អៀង សារី

បន្ទាប់ពីក្រុមមេធាវីការពារក្ដីរបស់ជនជាប់ចោទ នួន ជា មេធាវីការពារក្ដីរបស់ជនជាប់ចោទ អៀង សារី គឺលោក អាង ឧត្ដម បានផ្ដើមសួរសំណួរមួយចំនួនទាក់ទងនឹងដំណើរការនៃការដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក ក្វាន វ៉ិត ។ លោកមេធាវីបានធ្វើការកត់សម្គាល់ថា ឯកសារពាក្យបណ្ដឹងរបស់លោក ក្វាន វ៉ិត និងលោក រម៉ាម យុន ការសរសេរគឺមានកាលបរិច្ឆេទ និងព័ត៌មានដូចគ្នាស្ទើរតែទាំងស្រុង ខុសតែឈ្មោះប៉ុណ្ណោះ ។ បើមើលទៅសភាពជាក់ស្ដែង ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរមិនចេះអក្សរនោះទេ ដូច្នេះខ្លួនមានការព្រួយបារម្ភថាឯកសារនេះមិនចេញពីឆន្ទៈរបស់អ្នកឆ្លើយ ទោះបីជាមានការផ្ដិតមេដៃពីសំណាក់អ្នកទាំងពីរក៏ដោយ ។ ការកត់សម្គាល់នេះត្រូវបានសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការជំទាស់ ប៉ុន្ដែលោកប្រធានអង្គជំនុំជម្រះ និល ណុន ច្រានចោលចំពោះការជំទាស់នេះ ។


អាង ឧត្ដម មេធាវីជាតិរបស់ អៀង សារី

បន្ទាប់មកអង្គជំនុំជម្រះបានផ្ដល់វេទិការដល់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ដើម្បីធ្វើការសាកសួរបន្ដ ប៉ុន្ដែមេធាវីការពារក្ដីបានលើកឡើងថាខ្លួនមិនមានសំណួរសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីឡើយ ដោយសារការឆ្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានការពាក់ព័ន្ធនឹងកូនក្ដីរបស់ខ្លួន ។

### ៣) ខៀវ សំផន បញ្ជាក់ជូនចៅក្រមសារជាថ្មីពីគោលជំហរមិនឆ្លើយតបនឹងសំណួរ


ខៀវ សំផន ក្នុងបន្ទប់សវនាការ

នៅពេលចាប់ផ្តើមនៃសវនាការពេលរសៀលនៃសវនាការថ្ងៃទីបី គឺថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ លោកប្រធានអង្គជំនុំជម្រះ និល ណុន បានកោះហៅជនជាប់ចោទ ខៀវ សំផន មកកាន់វេទិកាក្រចកសេះដើម្បីធ្វើការសាកសួរ ។ ភ្លាមៗនោះ លោកមេធាវី គង់ សំអុន មេធាវីការពារក្តីរបស់ ខៀវ សំផន បានក្រោកឈរឡើង និងសួរទៅលោកប្រធានអង្គជំនុំជម្រះថា តើអង្គជំនុំជម្រះនឹងសួរពីអ្វីទៅលើកូនក្តីរបស់ខ្លួន តើសួរពីប្រវត្តិសាវតាររបស់ ខៀវ សំផន ឬសួរពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា ។ ដោយមិនទាន់ឆ្លើយតបនឹងសំណួររបស់លោកមេធាវី សំអុន លោកប្រធានចៅក្រម និល ណុន បានបញ្ជាឲ្យអនុរក្ស ពន្ធនាគារនាំយកជនជាប់ចោទ ខៀវ សំផន មកកាន់វេទិកាក្រចកសេះ ។


គង់ សំអុន មេធាវីជាតិរបស់ ខៀវ សំផន

លោកប្រធានអង្គជំនុំជម្រះបានបញ្ជាក់ទៅកាន់លោកមេធាវី គង់ សំអុន ថា ការកោះហៅជនជាប់ចោទ ខៀវ សំផន មកកាន់វេទិកាក្រចកសេះ គឺដើម្បីសួរបញ្ជាក់ឲ្យបានច្បាស់ពីជំហររបស់ជនជាប់ចោទក្នុងការឆ្លើយតបទៅនឹងសំណួររបស់ភាគី ។ ជនជាប់ចោទ ខៀវ សំផន បានក្រោកឈរបញ្ជាក់ជូនអង្គជំនុំជម្រះថា បើអង្គជំនុំជម្រះកោះហៅរូបខ្លួនឲ្យចូលវេទិកាក្រចកសេះដើម្បីគ្រាន់តែសាកសួរដេញដោលអំពីប្រវត្តិបក្សកុម្មុយនីស្ត ខ្លួននឹងមិនមានអ្វីត្រូវឆ្លើយតបទៀតឡើយ ព្រោះក្នុងសេចក្តីថ្លែងការណ៍កាលពីសវនាការថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ កន្លងមក ខ្លួនធ្លាប់បានបញ្ជាក់ម្តងរួចទៅហើយពីបញ្ហានេះ រីឯបញ្ហាទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា មិនទាន់ដល់ពេលដែលខ្លួនត្រូវឆ្លើយតបនៅឡើយទេ ។ ទីបំផុត ខៀវ សំផន បានមកកាន់កន្លែងវេទិកាក្រចកសេះតាមការបញ្ជារបស់ចៅក្រម ។

ដើម្បីឲ្យកាន់តែច្បាស់បន្ថែមទៀត ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ ដើម្បីសួរបញ្ជាក់ពីគោលជំហររបស់ជនជាប់ចោទ ខៀវ សំផន ។ លោកចៅក្រម ឡាវ៉ែញ បានបញ្ជាក់ទៅកាន់ជនជាប់ចោទ ខៀវ សំផន ថា សវនាការនាពេល នេះគឺជាការផ្តល់ឱកាសឲ្យជនជាប់ចោទ ខៀវ សំផន ឆ្លើយតប ឬធ្វើការកត់សម្គាល់ទៅនឹងការដាក់ភស្តុតាងរបស់ភាគីផ្សេងៗ ។ លោកមេធាវីជាតិ គង់ សំអុន បានក្រោកឈរឡើងបញ្ជាក់ជូនទៅអង្គជំនុំជម្រះសាជាថ្មីថាកូនក្តីរបស់ខ្លួននៅតែប្រកាន់ជំហរមិនឆ្លើយតបទៅនឹងការចោទសួរណាមួយរបស់ភាគី ព្រោះ ខៀវ សំផន ធ្លាប់បានបញ្ជាក់ច្បាស់ៗជូនអង្គជំនុំជម្រះរួចហើយពីបញ្ហានេះ ហើយអង្គជំនុំជម្រះក៏បានយល់ស្របផងដែរ ។ បន្ថែមទៅលើការលើកឡើងរបស់មេធាវីរបស់ខ្លួន ជនជាប់ចោទ ខៀវ សំផន ថាខ្លួននឹងមិនផ្លាស់ប្តូរជំហរឡើយ និងបានស្នើឲ្យចៅក្រម ឡាវ៉ែញ មិនចាំបាច់សាកសួរមកលើខ្លួនដើម្បីកុំឲ្យខាតពេលវេលា ។

ទោះបីជាមានការបដិសេធពីសំណាក់ជនជាប់ចោទ ខៀវ សំផន យ៉ាងណាក៏ដោយ លោកប្រធានចៅក្រម និល ណុន នៅតែបានអនុញ្ញាតឲ្យលោកចៅក្រម ឡាវ៉ែញ ធ្វើការបំភ្លឺជនជាប់ចោទ ខៀវ សំផន ពីបញ្ហាពាក់ព័ន្ធនឹងការដាក់ឯកសារ និងអនុញ្ញាតឲ្យធ្វើការកត់សម្គាល់ ឬប្រតិកម្មឆ្លើយតបទៅនឹងឯកសារទាំងនោះ និង


ប្រធានអង្គជំនុំជម្រះចៅក្រម និល ណុន

ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថាតើឯកសារដែលដាក់នៅនឹងចំពោះមុខជនជាប់ចោទ ខៀវ សំផន អាចទទួលយកបានដែរឬទេ ។ ឯកសារដែលដាក់ចូលទៅក្នុងសំណុំរឿងទាំងអស់នោះក៏មានសៀវភៅដែលនិពន្ធដោយជនជាប់ចោទ ខៀវ សំផន ខ្លួនឯងផងដែរ ។ បន្ទាប់មកលោក ចៅក្រម ឡាវីញ បានអានចម្លើយរបស់ជនជាប់ចោទ ខៀវ សំផន ដែលបានឆ្លើយតបទៅសហចៅក្រមស៊ើបអង្កេត និងសួរទៅ ខៀវ សំផន ថា តើមានប្រតិកម្មអ្វីចំពោះឃ្លាទាំងឡាយដែលលោកចៅក្រមបានអានដែរឬទេ ។ ជនជាប់ចោទ ខៀវ សំផន នៅតែបន្តលើកឡើងពីសេចក្តីថ្លែងការណ៍របស់ខ្លួនកាលពីសវនាការថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ និងបដិសេធចំពោះសំណើដែលលោកចៅក្រម ឡាវីញ ស្នើឲ្យធ្វើការបញ្ជាក់ ។

លោកមេធាវី សំអុន បានក្រោកឈរជំទាស់ទៅនឹងការសួរសំណួររបស់លោកចៅក្រម ឡាវីញ មកលើកូនក្តីរបស់ខ្លួនសាជាថ្មីដោយអះអាងថា ប្រសិនបើលោកចៅក្រម ឡាវីញ នៅតែបន្តសួរសំណួរមកលើកូនក្តីរបស់ខ្លួនដែលប្រកាន់ជំហរមិនឆ្លើយតប វានឹងក្លាយទៅជាការរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទ ដែលសិទ្ធិទាំងនោះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជានិងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។


ចៅក្រម ឡាវីញ

លោកចៅក្រម ឡាវីញ បានបន្តស្នើឲ្យជនជាប់ចោទ ខៀវ សំផន ធ្វើការបញ្ជាក់ទៅលើសៀវភៅ ដែលជាស្នាដៃនិពន្ធដោយជនជាប់ចោទខ្លួនឯង ប៉ុន្តែ ខៀវ សំផន មិនបានឆ្លើយតបចំពោះសំណើនេះឡើយ ។ មេធាវីការពារក្តី ខៀវ សំផន នៅតែព្យាយាមជំទាស់ចំពោះការព្យាយាមធ្វើឲ្យកូនក្តីរបស់ខ្លួន ឆ្លើយ លោកមេធាវី សំអុន បានផ្តល់អំណះអំណាងទៅលោកប្រធានអង្គជំនុំជម្រះ និល ណុន ចំពោះការជំទាស់នេះថាលោកចៅក្រម ឡាវីញ គ្រាន់តែផ្លាស់ប្តូរវិធីសាស្ត្រពីការចោទសួរមកជាការឲ្យកូនក្តីរបស់ខ្លួនធ្វើការបកស្រាយប៉ុណ្ណោះ កត្តានេះបង្ហាញថាកូនក្តីរបស់ខ្លួននឹងមិនអាចអនុវត្តសិទ្ធិក្នុងការមិនឆ្លើយតបបានឡើយ ហើយវាគឺជាការរំលោភមកលើសិទ្ធិរបស់ជនជាប់ចោទ ។

ការជំទាស់របស់លោកមេធាវី គង់ សំអុន បានធ្វើឲ្យលោកប្រធានចៅក្រម និល ណុន ស្នើឲ្យលោកចៅក្រម ឡាវីញ បញ្ជាក់តែអំពីឯកសារដែលទាក់ទងនឹងជនជាប់ចោទ ខៀវ សំផន តែប៉ុណ្ណោះ ។

មុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការ សហព្រះរាជអាជ្ញាបានស្នើសុំទៅអង្គជំនុំជម្រះឲ្យសាកសួរពីចេតនារបស់ជនជាប់ចោទ ខៀវ សំផនចំពោះការឆ្លើយតបទៅនឹងអង្គហេតុពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់របបកម្ពុជាប្រជាធិបតេយ្យនៅពេលណាដែលការសួរដេញដោលទៅលើអង្គហេតុពាក់ព័ន្ធទៅនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាត្រូវបានបញ្ចប់ ។

មុនដំបូងលោកមេធាវី គង់ សំអុន បានបញ្ជាក់ចំពោះបញ្ហានេះថា កូនក្តីរបស់ខ្លួននឹងធ្វើសេចក្តីថ្លែងការណ៍ដូចជាសវនាការសម្រាប់វគ្គទីមួយ ។ ប៉ុន្តែក្រោយមក លោកមេធាវីបានស្នើសុំពិភាក្សាជាមួយនឹងកូនក្តីរបស់ខ្លួនជាមុនសិន ។ ក្រោយពីការពិភាក្សា ជនជាប់ចោទ ខៀវ សំផន បានបញ្ជាក់ថា ខ្លួនមិនទាន់អាចឆ្លើយតបបានទេ ដោយរង់ចាំការពិចារណា ។

មុនបញ្ចប់កិច្ចដំណើរការនីតិវិធី លោកប្រធានអង្គជំនុំជម្រះ និល ណុន បានជូនដំណឹងថា សវនាការពីថ្ងៃទី១៦ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងបន្តកិច្ចដំណើរការនីតិវិធីទាញហេតុផលផ្ទាល់មាត់ទៅលើឯកសារនានា ។ នៅក្នុងសវនាការនេះនឹងមិនមានវត្តមានលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយត៍ ឡើយ ដោយសារលោកស្រីជាប់រវល់ជាមួយនឹងកិច្ចការផ្ទាល់ខ្លួន ហើយលោកស្រីចៅក្រម ក្លាឌៀ ហ្វេន ដែលជាចៅក្រមបម្រុងខាងភាគីបរទេស នឹងចូលមកជំនួសក្នុងអំឡុងពេលនៃការអវត្តមានរបស់លោកស្រីចៅក្រម ខាតវ៉ាយត៍ ។

## ■សវនាការលើសំណុំរឿង០០២: ការជំទាស់លើឯកសារពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង

**ថ្ងៃទី១៦-១៩ ខែមករា ឆ្នាំ២០១២**

### សេចក្តីផ្តើម

នៅថ្ងៃទី១៦-១៩ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការស្តីពីការជំទាស់លើឯកសារនានាដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងក្នុងសំណុំរឿង០០២ ។ អង្គជំនុំជម្រះបានកំណត់យកថ្ងៃទី១៦ មករា ឆ្នាំ២០១២ សម្រាប់សវនាការដេញដោលអំពីភស្តុតាងទូទៅដែលពាក់ព័ន្ធ និងការជំទាស់ផ្សេងៗលើឯកសារទាំងឡាយដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់ចំណាត់ថ្នាក់ E3 ជាបណ្តោះអាសន្ន ។ សវនាការពីថ្ងៃទី១៧ដល់ ១៩ ខែមករាឆ្នាំ២០១២ គឺធ្វើឡើងដើម្បីពិភាក្សាផ្ទាល់មាត់ស្តីពីការជំទាស់នឹងប្រភេទឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1 ដល់ A5 នៃបញ្ជីឯកសារដែលដាក់បញ្ចូលក្នុងសំណុំរឿងដោយសហព្រះរាជអាជ្ញា ។

ឧបសម្ព័ន្ធ A1 ឯកសារទាក់ទងនឹងសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ ។

◆ ឧបសម្ព័ន្ធ A2 ឯកសារទាក់ទងនឹងអត្ថបទបោះពុម្ពផ្សាយ និងសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ។



សហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត

◆ ឧបសម្ព័ន្ធ A3 ឯកសារទាក់ទងនឹងកំណត់ហេតុអង្គប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា ។

◆ ឧបសម្ព័ន្ធ A4 ឯកសារទាក់ទងនឹងឯកសារទំនាក់ទំនងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

◆ ឧបសម្ព័ន្ធ A5 ឯកសារទាក់ទងនឹងសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីថ្លែងការណ៍ជាសាធារណៈ ។

មុននឹងចូលដល់សវនាការស្តីពីការជំទាស់ទៅនឹងឯកសារខាងលើ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការកត់សម្គាល់លើឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងដោយផ្តើមដំបូងដោយសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រោយគេគឺក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងបីរូប នួន ជា អៀង សារី និង ខៀវ សំផន ។

**១) កំណត់សម្គាល់របស់ភាគីចំពោះបញ្ហាទូទៅនៃឯកសារពាក់ព័ន្ធនឹងសវនាការ**

***ក) ការកត់សម្គាល់របស់សហព្រះរាជអាជ្ញា***

សហព្រះរាជអាជ្ញារងអន្តរជាតិ លោក វីល្លៀម ស្មីត (William SMITH) បានធ្វើការកត់សម្គាល់ ៤ចំណុចទាក់ទងនឹងសារៈសំខាន់នៃឯកសារ លក្ខណគតិយុត្តិនៃឯកសារ ភាពអាចជឿជាក់បាន និងភាពអាចទទួលយកបាន និងទម្ងន់នៃភស្តុតាង ។

***◆ សារសំខាន់នៃឯកសារភស្តុតាងដែលដាក់ក្នុងសំណុំរឿង***

លោកសហព្រះរាជអាជ្ញា វីល្លៀម ស្មីត បានបញ្ជាក់ថាឯកសារដែលដាក់ជូនអង្គជំនុំជម្រះគឺមានសារសំខាន់ ដោយសារឯកសារទាំងអស់នោះមានការជាប់ពាក់ព័ន្ធនឹងបទល្មើសដែលមានទំហំធំ និងមានការពាក់ព័ន្ធជាមួយជនជាប់ចោទ ។ ឯកសារទាំងនោះក៏មានការផ្តល់សក្ខីកម្មពីសាក្សីទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងសម្រាប់អង្គជំនុំជម្រះពិនិត្យពីភាពពិតនៃឯកសារ ។ លោកបានលើកឡើងថានៅក្នុងរឿងក្តីរបស់ ឌុច មានការទទួលយកឯកសារជាងមួយពាន់ ដោយសារឯកសារទាំងនោះមានការពាក់ព័ន្ធជាមួយអង្គហេតុផ្សេងៗទៀត ។ ការអនុវត្តនៅក្នុងតុលាការអន្តរជាតិ គឺមានភស្តុតាងជាច្រើនដែលចៅក្រមទទួលយកដោយមានការថ្លឹងថ្លែងពីទម្ងន់នៃឯកសារដើម្បីធានាឲ្យមានភាពយុត្តិធម៌ចំពោះជនជាប់ចោទ និងជនរងគ្រោះ ។

### ◆ លក្ខខណ្ឌគតិយុត្តិដែលត្រូវយកមកអនុវត្ត

លោក វីល្លៀម ស្មីត សហព្រះរាជអាជ្ញាអន្តរជាតិ បាន ធ្វើការបង្ហាញទាក់ទងនឹងលក្ខខណ្ឌគតិយុត្តិ នៃឯកសារ ដោយយោងវិធាន៨៧(១) នៃវិធានផ្ទៃក្នុងដែលចែងថា "លើកលែងតែមានវិធានផ្សេងទៀតក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក ។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវតែមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ" ។ លោកបានបន្តថាអត្ថន័យនៃវិធាននេះបានបញ្ជាក់ឲ្យឃើញថាអង្គជំនុំជម្រះធ្វើការវាយតម្លៃទៅលើភស្តុតាងដោយសេរីដែលស្រដៀងគ្នាទៅនឹងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដែលដាក់ចេញនូវវិធានមួយស្តីពីភាពអាចទទួលយកបាននៃឯកសារដើម្បីឲ្យអង្គជំនុំជម្រះធ្វើការសម្រេចដោយមិនមានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

### ◆ ភាពអាចជឿជាក់បាននៃឯកសារ

ចំពោះភាពអាចជឿជាក់បាននៃឯកសារ គឺតុលាការត្រូវធ្វើការពិនិត្យទៅលើចំណុចពីរដែលទាក់ទងនឹងចរិតលក្ខណៈខាងក្រៅ និងចរិតលក្ខណៈខាងក្នុងនៃឯកសារ ។

ចរិតលក្ខណៈខាងក្រៅនៃឯកសារមានដូចជាប្រភពស្ថាប័នជាអ្នកចេញឯកសារ ការធ្វើកំណត់ ចំណាំនៅលើឯកសារ ទម្រង់ជាឯកសារសរសេរដោយដៃ ឬអក្សរបោះពុម្ព កាលបរិច្ឆេទនៃឯកសារនិងអ្នកនិពន្ធ ។ ចរិតលក្ខណៈខាងក្នុងវិញ គឺត្រូវពិនិត្យទៅលើគោលបំណងនៃឯកសារនោះពាក់ព័ន្ធនឹងគោលនយោបាយជាក់លាក់ ភាពស៊ីសង្វាក់គ្នាជាមួយឯកសារផ្សេងទៀត និងការធ្វើសក្ខីកម្មរបស់សាក្សី ។ នៅតុលាការអន្តរជាតិផ្សេងៗទៀតក៏មានប្រើឯកសារថតចម្លងផងដែរ ពីព្រោះឯកសារដើមមិនមែនជាកត្តាតែមួយគត់ដែលអាចបញ្ជាក់ពីយថាភាពនៃឯកសារនោះទេ ។

### ◆ ភាពអាចទទួលយកបាន និងទម្ងន់នៃភស្តុតាង

លោក វីល្លៀម ស្មីត បានបញ្ជាក់ថា តម្លៃនៃភស្តុតាងគឺអាចធ្វើការបញ្ជាក់បាននៅពេលដែលមានការបង្ហាញថាឯកសារនោះមានភាពពាក់ព័ន្ធហើយអាចទទួលយកបាន ។ បន្ទុកនៃការបង្ហាញពីតម្លៃនៃភស្តុតាងនោះគឺជាបន្ទុករបស់ភាគីដែលចង់បញ្ជាក់ដោយមិនមានវិធានណាមួយតម្រូវឲ្យភាគីមួយទៀតជាអ្នកបង្ហាញនោះទេ ហើយអង្គជំនុំជម្រះគឺមានសិទ្ធិក្នុងក្នុងការសម្រេច និងដកចេញនូវរាល់ភស្តុតាងទាំងឡាយណាដែលមិនមានតម្លៃនៅក្នុងសំណុំរឿង ។

### ១) ការកត់សម្គាល់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី



លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វត

លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហ្វត ( Elisabeth SIMONNEAU-FORD) បានធ្វើការកត់សម្គាល់មួយចំនួនដោយបានអះអាងថា មេធាវីការពារក្តីបានធ្វើការតវ៉ាដោយបំពានទៅលើច្បាប់ និងយុត្តិសាស្ត្រអន្តរជាតិ និងបានព្យាយាមពន្យារនីតិវិធីនៃសវនាការ ។ ការជំទាស់របស់មេធាវីការពារក្តី គឺជាការមិនគោរពចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេត ដោយសារថារាល់ឯកសារជាភស្តុតាងត្រូវបានបញ្ជាក់ពីយថាភាពរួចទៅហើយដោយសហចៅក្រមស៊ើបអង្កេត ចំពោះតម្លៃនៃភស្តុតាង គឺមានតែចៅក្រមជំនុំជម្រះប៉ុណ្ណោះដែលជាអ្នកមានសិទ្ធិសម្រេច ។ ចៅក្រមស៊ើបអង្កេត គឺជាអ្នកធ្វើការស្រាវជ្រាវរកភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ហើយរាល់ឯកសារដែលដាក់ចូលទៅក្នុងសំណុំរឿង គឺសុទ្ធតែមានតម្លៃគ្រប់គ្រាន់ក្នុងការគាំទ្រចំពោះការចោទប្រកាន់ ។ លោកស្រីមេធាវីបានបន្ថែមថា ដោយសារតែតុលាការនេះអនុវត្តតាមប្រព័ន្ធច្បាប់រ៉ូម៉ាំងអាល្លឺម៉ង់ ដូច្នេះរាល់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតគឺមិនអាចធ្វើការជំទាស់បានឡើយ លុះត្រាតែមានការប្តឹងជំទាស់ទៅអង្គបុរេជំនុំជម្រះ ។

លោកស្រីមេធាវីបានធ្វើការកត់សម្គាល់ពីរចំណុចបន្ថែម

ទៀត ។ ទីមួយគឺទាក់ទងនឹងភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីដោយបានអះអាងថា រាល់ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវបានសម្រេចដោយសហចៅក្រមស៊ើបអង្កេត ។ ដូច្នេះរាល់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវតែទទួលយកបាន ។ ចំណុចទីពីរគឺទាក់ទងនឹងការធ្វើសេចក្តីសម្រេចលើការជំទាស់របស់ភាគី ដោយអង្គជំនុំជម្រះត្រូវតែធ្វើការពិចារណាទៅលើសេចក្តីសម្រេចពីមុនៗដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង០០១ដែលវាជាយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះក្នុងការសម្រេចលើការជំទាស់របស់ភាគី ។

**ក) ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី**

បន្ទាប់ពីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការធ្វើកំណត់សម្គាល់របស់ខ្លួនរួចមក ប្រធានអង្គជំនុំជម្រះបានផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តីម្តង ។

**១) មេធាវីការពារក្តី នួន ជា**

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា គឺ លោក អេនឌ្រូ អ៊ីនូហ្ស៊ី បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិក្នុងការពិនិត្យទៅលើភាពអាចទទួលយកបាននៃឯកសារ មុនពេលដែលខ្លួនធ្វើការវាយតម្លៃពីទម្ងន់នៃភស្តុតាង ។ លោកមេធាវីបានបន្ថែមថាខ្លួនគាំទ្រចំពោះជំហររបស់អង្គជំនុំជម្រះដែលថា អង្គជំនុំជម្រះនឹងធ្វើការពិនិត្យទៅលើភាពអាចទទួលយកបាននៃឯកសារទៅតាមស្តង់ដារនៃតុលាការអន្តរជាតិ ។ លោកមេធាវីបានលើកឡើងពីបទដ្ឋានច្បាប់ខ្មែរដែលបញ្ជាក់ថា ឯកសារជាភស្តុតាងត្រូវតែមានការបញ្ជាក់អំពីយថាភាព ឬទាល់តែជាប្រភេទឯកសារដើម ដោយសារវាមានសារសំខាន់ចំពោះការធានាសិទ្ធិរបស់ជនជាប់ចោទ ។ ការបង្ហាញពីយថាភាពនេះ គឺជាបន្ទុករបស់ព្រះរាជអាជ្ញាដែលត្រូវលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារដើមមួយចំនួន ។ លោកបានធ្វើការជំទាស់ទៅនឹងការលើកឡើងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើការបដិសេធមិនឲ្យមានការជំទាស់ទៅលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដោយលោកអះអាងថា បញ្ហាយថាភាពនៃឯកសារនេះត្រូវតែអាចពិភាក្សាដេញដោលក្នុងរយៈពេលនៃសវនាការទាំងមូល ប្រសិនបើមិនមានភាពច្បាស់លាស់ ។ លោកមេធាវី អ៊ីនូហ្ស៊ី បានបង្ហាញពីជំហររបស់ខ្លួនឲ្យមានការកោះអញ្ជើញមន្ត្រីពីមជ្ឈមណ្ឌលឯកសារកម្ពុជាមកធ្វើការបំភ្លឺដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងរក្សាទុកឯកសារដើមជាច្រើន ។ លោកក៏បានស្នើសុំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចទាក់ទងនឹងការស្នើសុំរបស់ នួន ជា ឲ្យមានការបង្ហាញឯកសារដើមចំពោះឯកសារដែលបានបង្ហាញដោយសហព្រះរាជអាជ្ញា ។

**២) មេធាវីការពារក្តី អៀង សារី**



ម៉ៃឃើល ខាណាវ៉ាស
មេធាវីអន្តរជាតិរបស់ អៀង សារី

សហមេធាវីការពារក្តីអន្តរជាតិរបស់ជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ខាណាវ៉ាស (Michael KARNAVAS) បានធ្វើការកត់សម្គាល់ជាដំបូងដោយបដិសេធចំពោះការលើកឡើងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលចោទថាមេធាវីការពារក្តីបានធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីរបស់តុលាការ ។ លោកបានអះអាងថា ការយឺតយ៉ាវនេះគឺបណ្តាលមកពីមិនមានការដោះស្រាយចំពោះសំណើសុំរបស់ក្រុមមេធាវីការពារក្តី ។ លោកមេធាវីបានជំទាស់ទៅនឹងការលើកឡើងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលហាមឃាត់មិនឲ្យភាគីតវ៉ាចំពោះឯកសារដែលត្រូវបានពិនិត្យដោយសហចៅក្រមស៊ើបអង្កេត ។ ដោយហេតុថាកន្លងមកខ្លួនមិនដែលទទួលបានការឆ្លើយតបពីសហចៅក្រមស៊ើបអង្កេតអំពីការស្នើសុំឲ្យពិចារណាទៅលើឯកសារដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីឲ្យដឹងច្បាស់ថា ឯកសារទាំងនោះត្រូវបានប្រមូលដោយរបៀបណាហើយមានប្រភពមកពីណានៅឡើយ ។ លោកមេធាវីយល់ស្រប

នឹងការលើកឡើងរបស់ព្រះរាជអាជ្ញាដែលថាឯកសារដែលបានមកពីការធ្វើទារុណកម្មនោះមិនអាចទទួលយកបាន ហើយរាល់ការសម្រេចទៅលើភាពអាចទទួលយកបាននេះគឺជាការសម្រេចរបស់អង្គជំនុំជម្រះ ប៉ុន្តែត្រូវមានការពិនិត្យពីភាពពិតនៃឯកសារ ។ លោកបានបញ្ជាក់បន្ថែមថា យថាភាពនៃឯកសារ គឺខុសពីភាពអាចទទួលយកបាននៃឯកសារ ដោយសារតែឯកសារខ្លះមានយថាភាព ប៉ុន្តែនៅតែមិនអាចទទួលយកបាន ។ បន្ទាប់ពីមានការពិនិត្យទៅលើចំណុចទាំងពីរនេះចៅក្រមត្រូវតែពិចារណាទៅលើភាពពាក់ព័ន្ធគ្នានៃឯកសារបន្ថែមទៀតដើម្បីកុំឲ្យមានវិមតិសង្ស័យដែលនឹងជាប្រយោជន៍របស់ជនជាប់ចោទ ។ លោកមេធាវី ខាណាវ៉ាស បានធ្វើការបង្ហាញបន្តពីគោលការណ៍នៃភាពអាចទទួលយកបាននៃភស្តុតាងដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង និងលើកយកនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានធ្វើឡើងនៅក្នុងសំណុំរឿង០០១ ទាក់ទងនឹងភាពពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាននៃភស្តុតាង ។

### ៣) មេធាវីការពារក្តី ខៀវ សំផន

មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន គឺលោក គង់ សំអុន បានលើកឡើងថា ភាគីកំពុងមានការភាន់ច្រឡំទៅលើវិធាន៨៧(១)ពាក់ព័ន្ធនឹងពាក្យ“*អាចទទួលយកបាន*” ។ លោកបានអះអាងថា ពាក្យ *អាចទទួលយកបាន* គឺមានន័យថា អាចទទួលយកមកដេញដោលតែប៉ុណ្ណោះ មិនមែនមានតម្លៃដែលអាចឲ្យអង្គជំនុំជម្រះយកមកសម្រេចនោះឡើយ ។ លោកបានបង្ហាញពីជំហរដូចក្រុមមេធាវីការពារក្តីរបស់ នួន ជា និង អៀង សារី ដែរទាក់ទងនឹងបន្ទុករបស់សហព្រះរាជអាជ្ញាក្នុងការបង្ហាញពីភាពអាចទទួលយកបាននៃឯកសារមុននឹងយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវបង្ហាញឲ្យលើសពីវិមតិសង្ស័យដែលវាជាខ្នាតសម្រាប់វាស់នូវតម្លៃនៃភស្តុតាង ។ លោកមេធាវី សំអុន ក៏បានបដិសេធការលើកឡើងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលចោទថាមេធាវីការពារក្តីធ្វើឲ្យខាតបង់ពេលវេលា ។ លោកអះអាងថាការខាតពេលវេលានេះ គឺបណ្តាលមកពីសហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញពីភាពពាក់ព័ន្ធនៃឯកសារឲ្យបានច្បាស់លាស់ ។

## ២) ការជំទាស់ទៅនឹងប្រភេទឯកសារ E3

### ក) ការជំទាស់របស់ក្រុមមេធាវីការពារក្តី

### ១) មេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា គឺលោក ហ្សាស្ពើ ប៉ៅ (Jasper PAUW) បានធ្វើការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយលើកឡើងថាមជ្ឈមណ្ឌលឯកសារកម្ពុជាបំពេញការងារដោយមិនឯករាជ្យ ហើយមានបំណងចោទប្រកាន់ទៅលើកូនក្តីខ្លួន ។ លោកមេធាវីបានប្រកាន់ជំហររបស់ខ្លួនដោយស្នើសុំឲ្យតុលាការត្រូវតែកោះហៅលោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាមកធ្វើសក្ខីកម្មទាក់ទងនឹងការប្រមូលចងក្រងឯកសារ និងដើម្បីបញ្ជាក់ពីគោលជំហររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបំពេញការងាររបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៩៥ ។ មេធាវីអន្តរជាតិការពារក្តីរបស់ នួន ជា មួយរូបទៀត គឺលោក ម៉ៃឃើល ផេស្តមេន (Michiel PESTMAN) ក៏បានជំទាស់ទៅនឹងឯកសារទស្សនាវដ្តីទង់បដិវត្ត ដែលបានដាក់បង្ហាញដល់កូនក្តីខ្លួន និងឯកសារកិច្ចសម្ភាសន៍ជាមួយ នួន ជា ដែលធ្វើឡើងដោយលោក ខឹម ផុន ដោយស្នើសុំឲ្យមានការបញ្ជាក់ពីសាក្សីរូបនេះ ។

### ២) មេធាវីការពារក្តី អៀង សារី

លោក ខាណាវ៉ាស បានគាំទ្រការលើកឡើងដោយមេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការកោះហៅ លោក ឆាំង យុ ឬអ្នកតំណាងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានជំទាស់នឹងឯកសារមួយចំនួនដែលដាក់ដោយសហព្រះរាជអាជ្ញាដូចជាសារព័ត៌មានដែលប្រកាសជាសាធារណៈ ឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយគិញសម្ងាត់សហរដ្ឋអាមេរិកទាក់ទងនឹងការទម្លាក់គ្រាប់បែកនៅវៀតណាមនិងកម្ពុជា អត្ថបទសៀវភៅរបស់អ្នកស្រាវជ្រាវឯកសារដែលបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្ត កំណត់ហេតុនៅក្នុងកិច្ចប្រជុំ ឯកសារជាសាទូរលេខ កំណត់ហេតុសួរចម្លើយលើសាក្សី ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតទៅលើជនមួយចំនួន ចម្លើយសារភាពរបស់ អៀង សារី ដែលផ្តល់ឲ្យអ្នកសារព័ត៌មានវីដេអូរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌ប៊ីប៊ីស៊ី(B.B.C) ស្តីពីការសម្ភាសន៍របស់ នួន ជា ប្រវត្តិរូបរបស់ អៀង សារី និងឯកសារស្តីពីប្រវត្តិរបស់ នួន ជា កាលពីវ័យក្មេង ។ លោកមេធាវី

នៅតែប្រកាន់ជំហររបស់ខ្លួនឲ្យមានការផ្ទៀងផ្ទាត់ភាព ដើម្បីឲ្យឯកសារទាំងនោះអាចទទួលយកបានតាមរយៈការផ្តល់សក្ខីកម្មរបស់សាក្សី ការបញ្ជាក់កាលបរិច្ឆេទ និងឈ្មោះអ្នកនិពន្ធជាដើម ។

### ៣) មេធាវីការពារក្តី ខៀវ សំផន

ចំណែកឯក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏បានបង្ហាញពីគោលជំហររបស់ខ្លួនមិនខុសពីមេធាវីពីរក្រុមផ្សេងទៀត ដែលទាមទារឲ្យមានការកោះហៅមន្ត្រីពីមជ្ឈមណ្ឌលឯកសារកម្ពុជាមកធ្វើសក្ខីកម្ម អំពីការចងក្រងឯកសារ និងប្រភេទឯកសារនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅចំពោះមុខអង្គជំនុំជម្រះ ។ លោកមេធាវី គង់ សំអុន បានបង្ហាញនូវប្រភេទឯកសារមួយចំនួនដែលបានលើកឡើងដោយមេធាវីការពារក្តី អៀង សារី ដែលទាមទារឲ្យមានការបញ្ជាក់អំពីយថាភាព និងភាពអាចទទួលយកបាន ។

### ខ) ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី

សហព្រះរាជអាជ្ញាអន្តរជាតិ លោក វីល្លៀម ស្មីត បានធ្វើការឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវី ខៀវ សំផន ដែលបានដាក់បន្ទុកមកលើភាគីខ្លួនក្នុងការផ្តល់ភស្តុតាងឲ្យលើសពីវិមតិសង្ស័យថាគឺជាដាក់បន្ទុកធ្ងន់ធ្ងរ ពីព្រោះថានៅក្នុងដំណាក់កាលនេះច្បាប់អនុញ្ញាតឲ្យតុលាការទទួលយកភស្តុតាងមកពិនិត្យជាបឋមសម្រាប់យកមកធ្វើការដេញដោលតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀតការកំណត់ពីភាពអាចទទួលយកបាននៃឯកសារនោះគឺធ្វើឡើងតាមរយៈការធ្វើតេស្តលើឯកសារជាជាងការកោះហៅម្ចាស់ឯកសារមកធ្វើការសាកសួរដេញដោលដែលវាជាលក្ខខណ្ឌមួយខ្ពស់ពេក ។ ឆ្លើយតបទៅនឹងមេធាវី ការពារក្តីរបស់ជនជាប់ចោទ នួន ជា លោកបានអះអាងថា បទល្មើសដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាជាបទល្មើសដែលមានទ្រង់ទ្រាយធំ ។ ដូច្នេះរាល់ការពិនិត្យទៅលើភស្តុតាង គឺតុលាការមិនអាចពិនិត្យមើលលក្ខណៈមួយៗនៃភស្តុតាងដូចជាការកាន់កាប់ឯកសារ ការរក្សាទុកឯកសារដូចដែលបានទាមទារដោយក្រុមមេធាវីការពារក្តីឡើយ ដោយសារតែអង្គជំនុំជម្រះគឺជាអ្នកសម្រេច និងជ្រើសរើសភស្តុតាងទៅតាមអង្គហេតុនីមួយៗ ហើយអង្គជំនុំជម្រះក៏អាចសម្រេចដកចេញភស្តុតាងទាំងឡាយណាដែលខ្លួនយល់ថាមិនពាក់ព័ន្ធ ។ លោកនៅតែប្រកាន់ជំហរថា ការបញ្ជាក់ពីយថាភាព និងភាពអាចទទួលយកបាននៃឯកសារនោះគឺជាការសម្រេចរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះ ។

ទាក់ទងនឹងការកោះហៅមន្ត្រីពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលក្រុមមេធាវីទាំងបីក្រុមបានទាមទារ លោក ស្មីត បានអះអាងថាលោកអាចធ្វើការកោះហៅមន្ត្រីពីមជ្ឈមណ្ឌលឯកសារកម្ពុជាមកសាកសួរតែទៅលើការកាន់កាប់ឯកសារ ការផ្លាស់ប្តូរការកាន់កាប់ឯកសារតែប៉ុណ្ណោះ ។ ចំណែកឯយថាភាពនៃឯកសារ គឺមានតែតុលាការប៉ុណ្ណោះដែលអាចសម្រេច ពីព្រោះមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអង្គការមួយដែលធ្វើការប្រមូលឯកសារប្រវត្តិសាស្ត្រដោយឯករាជ្យ និងមិនលម្អៀង ។

សហព្រះរាជអាជ្ញារងជាតិ លោក ច័ន្ទ តារាស្មី បានបដិសេធចំពោះការជំទាស់របស់ អៀង សារី ទៅលើវីដេអូចំនួនពីរ គឺ "ស្រមោល ប៉ុល ពត" ដែលមេធាវីអះអាងថាមិនជាប់ពាក់ព័ន្ធក្នុងសំណុំរឿង០០២ គឺមិនត្រឹមត្រូវទេ ដោយសារតែវីដេអូនោះធ្លាប់បានប្រើនៅក្នុងសំណុំរឿង០០១ម្តងរួចមកហើយ ។ ចំពោះវីដេអូទីពីរដែលជាបទសម្ភាសន៍ជាមួយ នួន ជា ដែលមេធាវីលើកឡើងថាបទសម្ភាសន៍នោះខ្វះមិនមានភាសាដើមរបស់ នួន ជា ដែលអាចមានការបកប្រែខុស សហព្រះរាជអាជ្ញា យល់ថា ប៊ី ប៊ី ស៊ី ជាស្ថាប័នព័ត៌មានដ៏ធំមានឈ្មោះល្បី ដូច្នេះមិនអាចមានការបកប្រែភាសាខុសនោះឡើយ ។

សហព្រះរាជអាជ្ញាបានលើកឡើងថាឯកសារដែលត្រូវបានជំទាស់ដោយ អៀង សារី នោះពិតជាឯកសារដែលត្រូវបានបោះពុម្ពដោយបក្សកុម្មុនីស្តកម្ពុជា ដោយសម្អាងទៅលើការរៀបរាប់នៅក្នុងឯកសារនោះទាក់ទងនឹងរចនាសម្ព័ន្ធនយោបាយរបស់បក្ស ពាក្យពេចន៍ដែលប្រើនៅសម័យនោះព្រមទាំងមាននិយាយពីតួនាទីរបស់ជនជាប់ចោទ ។ លោក តារាស្មី បានលើកឡើងទាក់ទងនឹងឯកសារទង់បដិវត្ត ដែល នួន ជា បានបញ្ជាក់ថាជាឯកសារដែលបោះពុម្ពដោយបក្សកុម្មុនីស្តកម្ពុជា ដែល នួន ជា ខ្លួនឯងក៏បានចូលរួមសរសេរដែរ ។ លោកបានលើកឡើងនូវជំហររបស់ខ្លួនថា របាយការណ៍សារព័ត៌មានត្រូវតែមានតម្លៃជាងការកោះហៅសាក្សីមកផ្តល់សក្ខីកម្មដោយសម្អាងទៅលើស្តង់ដារនៅ

ក្នុងតុលាការអន្តរជាតិនានា ។

### ក) ចម្លើយតបរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី



ពេជ អង្គ មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកមេធាវី ពេជ អង្គ នៅតែប្រកាន់ជំហរគាំទ្រចំពោះឯកសារ ដែលបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីការដំណោះស្រាយ ហើយខ្លួនក៏គាំទ្រចំពោះការលើកឡើងរបស់ភាគីសហព្រះរាជអាជ្ញាដែលថាមេធាវីការពារក្តីត្រូវតែបង្ហាញនូវឯកសារណាមួយជាក់លាក់ដែលខ្លួនយល់ថាឯកសារនោះមិនអាចទទួលយកបាន ។ ទាក់ទងនឹងយថាភាពនៃឯកសារ លោកមេធាវីបានបញ្ជាក់ថា ការបញ្ជាក់យថាភាពនៃឯកសារគឺមិនប្រាកដថាត្រូវតែពឹងផ្អែកទៅលើឯកសារដើមនោះទេ គឺវាអាស្រ័យលើភាពត្រឹមត្រូវរបស់វាតែប៉ុណ្ណោះ ។ បញ្ហាសំខាន់មួយទៀតគឺតុលាការមិនចាំបាច់កោះហៅសាក្សីមកបញ្ជាក់លើឯកសារនោះទេ ពីព្រោះវាអាចជាការបន្ទាយពេលវេលានៃនីតិវិធី ។ លោកស្រី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វូត បានធ្វើការឆ្លើយតបបន្ថែមថាការកោះហៅលោក ឆាំង យុ មកធ្វើសក្ខីកម្មគឺជាការគ្រប់គ្រាន់ដើម្បីកុំឲ្យការពិភាក្សានេះនៅតែបន្តទៀត ។ លោកស្រីមេធាវីក៏លើកឡើងថាមេធាវីការពារក្តី ខកខានមិនបានលើកយកចំណុចណាមួយមកធ្វើការជំទាស់ឡើយ ហើយបានស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យទៅលើប្រភេទឯកសារពីរគឺឯកសារដែលបានពិនិត្យដោយសហចៅក្រមស៊ើបអង្កេត និងឯកសារដែលដាក់ដោយភាគីហើយចៅក្រមស៊ើបអង្កេតមិនបានទទួលស្គាល់ ។

### ឃ) ចម្លើយតបរបស់មេធាវីការពារក្តីទាំងបីក្រុម

អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីការពារក្តីទាំងបីក្រុមដើម្បីឆ្លើយតបនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញានិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

សហមេធាវីអន្តរជាតិ ហ្សាស្តើ ប៉ៅ បានប្រកាន់នូវជំហររបស់ខ្លួនក្នុងការស្នើសុំឲ្យលោក ឆាំង យុ មកផ្តល់សក្ខីកម្មអំពីការចងក្រងឯកសារទាក់ទងនឹងការផ្ទេរឯកសារ ការកាន់កាប់ឯកសារ និងបញ្ជាក់អំពីភាពមិនលម្អៀងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ បើមិនដូច្នោះទេខ្លួននឹងមិនទទួលស្គាល់ពីយថាភាពនៃឯកសារដែលចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជាឡើយ ។

លោក ម៉ៃឃើល ខណាវ៉ាស បានធ្វើការបដិសេធចំពោះការអះអាងរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការសំអាងទៅលើយថាភាពនិងភាពអាចទទួលយកបាននៃឯកសារដែលប្រើដោយសហចៅក្រមស៊ើបអង្កេត ។ លោកបានអះអាងថាសហចៅក្រមស៊ើបអង្កេតមានការខកខានមិនបានបញ្ជាក់ពីយថាភាព និងភាពអាចទទួលយកបានតាមការស្នើសុំរបស់ខ្លួននោះទេ ។ លោកមេធាវីក៏បានធ្វើការបដិសេធចំពោះការអះអាងរបស់សហព្រះរាជអាជ្ញាចំពោះឯកសារដែលមានប្រើប្រាស់ឃ្លាឃ្លោង ការប្រើប្រាស់ឯកសារសារព័ត៌មាន និងឯកសារដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង០០១ ហើយមេធាវីនៅតែគាំទ្រឲ្យមានការបញ្ជាក់ពីសាក្សី ។

មេធាវីរបស់ជនជាប់ចោទ ខៀវ សំផន បានធ្វើការឆ្លើយតបមិនខុសពីមេធាវីការពារក្តីទាំងពីរក្រុមផ្សេងទៀតនោះទេ ដោយស្នើសុំឲ្យមានការកោះហៅសាក្សីមកបញ្ជាក់ពីប្រភពមធ្យោបាយនៃការថែរក្សា និងខ្លឹមសារនៅក្នុងអត្ថបទទាំងឡាយដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ លោកមេធាវីបានអះអាងថា ការណ៍ដែលសហព្រះរាជអាជ្ញាមិនគាំទ្រឲ្យមានការកោះហៅសាក្សីមកបញ្ជាក់នោះគឺជាការនាំឲ្យនីតិវិធីតុលាការនឹងចំណាយពេលវេលាកាន់តែច្រើន ។

### ៣) ការជំទាស់របស់ក្រុមមេធាវីការពារក្តីទៅនឹងឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5

នៅក្នុងសវនាការស្តីពីការជំទាស់របស់ក្រុមមេធាវីការពារ

ក្តីទៅនឹងឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5 អង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ឡើងធ្វើការជំទាស់មុនគេ បន្ទាប់មកបន្តទៅក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី និង ជនជាប់ចោទខៀវ សំផន ។

### ១) ការជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា លោក អេនឌ្រូ អ៊ីនូហ្វ៊ី បានឡើងធ្វើការជំទាស់ទៅនឹងឯកសាររបស់សហព្រះរាជអាជ្ញាដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយបានអះអាងថា ក្រុមមេធាវីការពារក្តី នួន ជា នឹងធ្វើការជំទាស់ជាទូទៅចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5 និងគ្រប់ឯកសារដែលដាក់ជូនទៅអង្គជំនុំជម្រះ ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1 (ឯកសារទាក់ទងនឹងសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ) លោកមេធាវីបានលើកឡើងថា ក្រុមមេធាវីការពារក្តី នួន ជា សុំធ្វើការជំទាស់ជាក់លាក់ទៅនឹងឯកសារចំនួន១៩ក្នុងចំណោមឯកសារចំនួន២០០ដែលមាននៅក្នុងឧបសម្ព័ន្ធ A1 ។ ឯកសារ ទាំងនោះរួមមានសេចក្តីថ្លែងការណ៍ និងសន្ទរកថារបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យសំបុត្រមួយចំនួន ឯកសារបទសម្ភាសន៍របស់ នួន ជា ឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត រួមទាំងឯកសារដែលនិយាយពីឈ្មោះ ខឹម ង៉ុន ដែលត្រូវបាន នួន ជា ចាត់ទុកថាជាចារបុរសរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

លោកមេធាវី អ៊ីនូហ្វ៊ី បានស្នើសុំទៅអង្គជំនុំជម្រះបង្គាប់ឲ្យមានការបង្ហាញឯកសារពិតដល់ជនជាប់ចោទ នួន ជា ដើម្បីបញ្ជាក់ ។ ប្រសិនបើជនជាប់ចោទយល់ថា ឯកសារនោះជាឯកសារមិនមានភាពគួរឲ្យជឿជាក់បាន ត្រូវកោះហៅអ្នកដែលធ្វើបទសម្ភាសន៍ ឬអ្នកនិពន្ធទាំងអស់នោះមកសាកសួរដេញដោលដោយផ្ទាល់នៅចំពោះអង្គជំនុំជម្រះ ។ រីឯឯកសារទាក់ទងនឹងចម្លើយរបស់ជនជាប់ចោទ នួន ជា នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះគួរតែពិចារណាចំពោះឯកសារទាំងនោះឡើងវិញ ដោយសារតែនៅពេលនោះជនជាប់ចោទ នួន ជា មិនទាន់មានមេធាវីការពារក្តីនៅឡើយ ហើយជនជាប់ចោទ នួន ជា មិនបានបោះបង់សិទ្ធិក្នុងការមានមេធាវីដូចជាការលើកឡើងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ ។

ទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធA2 (ឯកសារទាក់ទងនឹងអត្ថបទបោះពុម្ពផ្សាយ និងសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា) លោកមេធាវី អ៊ីនូហ្វ៊ី បានបញ្ជាក់ថាភាគច្រើននៃឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនេះ គឺទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អង្គជំនុំជម្រះមិនគួរពឹងផ្អែកខ្លាំងទៅលើឯកសារទាំងនោះឡើយ គឺចាំបាច់ត្រូវតែអញ្ជើញលោក ឆាំង យុ ដែលជាប្រធាននៃមជ្ឈមណ្ឌលនេះមកធ្វើការសាកសួរដេញដោលនៅក្នុងសវនាការជាមុនសិន បើមិនដូច្នេះទេ ក្រុមមេធាវីការពារក្តីរបស់ នួន ជា មិនអាចទទួលស្គាល់ឯកសារទាំងនោះបានទេ ។ ម្យ៉ាងវិញទៀត មានភាពច្របូកច្របល់មួយចំនួនដែលកើតមាននៅក្នុងបញ្ជីឯកសារ ដែលធ្វើឲ្យក្រុមមេធាវីការពារក្តីមានមន្ទិលថាតើឯកសារទាំងនោះជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឬក៏អត់នោះទេ ។ ចំពោះឯកសារទាក់ទងនឹងសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងមន្ទីរ៨៧០ ដែលត្រូវបានផ្តល់ចម្លើយដោយឈ្មោះ សេង ម៉ុន ក្រុមមេធាវីការពារក្តីយល់ថា ឯកសារនេះហាក់ដូចជាមានការព្យាយាមធ្វើឲ្យមានយថាភាពទៅលើឯកសារនោះ ។ ដូច្នេះអង្គជំនុំជម្រះគួរតែកោះហៅឈ្មោះ សេង ម៉ុន មកធ្វើការតទល់ចំពោះមុខកូនក្តីរបស់ខ្លួន ។

ពាក់ព័ន្ធទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A3 (ឯកសារទាក់ទងនឹងកំណត់ហេតុអង្គប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា) លោកមេធាវីជាតិការពារក្តីឲ្យ នួន ជា គឺ លោកមេធាវី សុន អារុណ បានបញ្ជាក់ជូនទៅអង្គជំនុំជម្រះថា ខ្លួនសុំធ្វើការជំទាស់ទៅនឹងឯកសារដើមជាភាសាខ្មែរដែលមានចំណារនៅលើឯកសារទាំងអស់នោះជាភាសាខ្មែរ ភាសាវៀតណាម និងជាភាសាអង់គ្លេស ។ ម្យ៉ាងទៀតនៅលើឯកសារទាំងអស់នោះក៏មានការលុប និងសរសេរបន្ថែមផងដែរ ដែលការណ៍នេះធ្វើឲ្យក្រុមមេធាវីការពារក្តីមានការសង្ស័យចំពោះភាពពិតប្រាកដនៃឯកសារទាំងអស់នោះ ។ ដូច្នេះចាំបាច់ត្រូវតែមានការបញ្ជាក់ឲ្យច្បាស់ថា តើការសរសេរបន្ថែមទាំងអស់នោះធ្វើឡើងនៅក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យ

ឬជាសំណៅដើមនៃឯកសារនោះ ។ ហេតុនេះអង្គជំនុំជម្រះត្រូវតែកោះអញ្ជើញអ្នកទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីមកធ្វើការបញ្ជាក់អំពីបញ្ហានេះ និងផ្តល់ឯកសារច្បាប់ដើមមកដល់អង្គជំនុំជម្រះ បើមិនដូច្នេះទេ ក្រុមមេធាវីការពារក្តីរបស់ នួន ជា នៅតែប្រកាន់ជំហររបស់ខ្លួនក្នុងការជំទាស់ទៅនឹងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលដាក់ដោយសហព្រះរាជអាជ្ញា ។ លោកមេធាវី អារុណ បានបន្តទៀតថា ការអញ្ជើញមកចំពោះមុខតុលាការរបស់អ្នកដឹកនាំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនមានបញ្ហាអ្វីដែលគាត់មិនអាចធ្វើបាននោះទេ ។ ជាងនេះទៅទៀត លោក ឆាំង យុ ក៏បានបញ្ជាក់នៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ដែលថា លោករង់ចាំស្តាប់បញ្ហាពីតុលាការចំពោះវត្តមានរបស់លោកនៅក្នុងតុលាការនេះ ។ លោកមេធាវីបានសន្និដ្ឋានថាឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A3 គឺមើលមិនច្បាស់ មិនដឹងពីអត្ថន័យនៃឯកសារទាំងអស់នោះ ដូច្នេះមេធាវីមិនអាចធ្វើសេចក្តីសន្និដ្ឋានទៅលើឯកសារទាំងអស់នោះបាន ។ លោកមេធាវីបានបញ្ជាក់ពីគោលបំណងរបស់កូនក្តីរបស់ខ្លួនថា នួន ជា គឺនៅតែទទូចស្នើសុំឲ្យផ្តល់ឯកសារដើមដើម្បីធ្វើការផ្ទៀងផ្ទាត់ទៅនឹងឯកសារថតចម្លងដែលតុលាការបានយកមកប្រើប្រាស់ធ្វើយ៉ាងណាឲ្យឯកសារទាំងអស់នោះមានយថាភាព ។

មេធាវីអន្តរជាតិការពារក្តីឲ្យ នួន ជា លោក ម៉ៃឃើល ផេស្តមេន បានបញ្ជាក់បន្ថែមទៅលើការលើកឡើងរបស់លោកមេធាវី សុន អារុណ ដែលជាសហសេវិករបស់ខ្លួនថា ក្រុមមេធាវីការពារក្តីនឹងទទួលស្គាល់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រសិនបើមានការបញ្ជាក់អំពីការផ្ទេរបង្គរ ឬខ្សែចង្វាក់នៃការកាន់កាប់ឯកសារទាំងអស់នោះ ។ ឯកសារដែលសហព្រះរាជអាជ្ញាបានដាក់នៅចំពោះអង្គជំនុំជម្រះទាក់ទងនឹងសវនាការដំណាក់កាលទីមួយនេះ គឺមានតែឯកសារមួយចំនួនប៉ុណ្ណោះដែលជាប់ពាក់ព័ន្ធរីឯឯកសារផ្សេងទៀតមិនមានទាក់ទងនឹងអង្គហេតុនៃសវនាការដំណាក់កាលទី១ នេះឡើយ ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A4 (ឯកសារទាក់ទងនឹងឯកសារទំនាក់ទំនងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) លោកមេធាវី សុន អារុណ បានបញ្ជាក់ថា លោកនៅតែប្រកាន់ជំហរសង្ស័យចំពោះយថាភាពនៃឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A4 ដូចជាការជំទាស់ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A3 ដែរ ។ លោកមេធាវីក៏បានស្នើសុំទៅអង្គជំនុំជម្រះឲ្យកោះហៅសាក្សីដែលមានការពាក់ព័ន្ធនឹងការផ្ញើឯកសារទំនាក់ទំនងជាផ្លូវការរវាងថ្នាក់ក្រោម និងថ្នាក់លើដូចជាឯកសារ ជាសារទូរសារដើម្បីដឹងថាតើឯកសារទាំងនោះពិតជាឯកសារទំនាក់ទំនងរបស់របបកម្ពុជាប្រជាធិបតេយ្យមែនដែរឬទេ ។ បន្ទាប់ពីលោកមេធាវីជាតិ សុន អារុណ មេធាវីអន្តរជាតិលោក ម៉ៃឃើល ផេស្តមេន បានឡើងធ្វើការបញ្ជាក់បន្ថែមទៅលើឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនោះថា ជាថ្មីម្តងទៀតក្រុមមេធាវីការពាររបស់ នួន ជា នៅរក្សាជំហរបដិសេធចំពោះឯកសារទាំងឡាយដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយចាំបាច់ត្រូវតែស្តាប់សក្ខីកម្មរបស់លោក ឆាំង យុ ដើម្បីដឹងថា តើឯកសារទាំងអស់ដែលសហព្រះរាជអាជ្ញាទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះ គឺធ្វើឡើងដោយរបៀបណា ។ លោកមេធាវីក៏បានស្នើសុំបញ្ជីឯកសារដែលសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្នើទៅអង្គជំនុំជម្រះឲ្យធ្វើការពិនិត្យឯកសារទាំងអស់ឲ្យបានល្អិតល្អន់ និងច្រានចោលឯកសារទាំងឡាយដែលមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃសវនាការដំណាក់កាលដំបូង ។

ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន A5 (ឯកសារទាក់ទងនឹងសារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីថ្លែងការណ៍ជាសាធារណៈ) លោកមេធាវី ផេស្តមេន បានបង្ហាញពីគោលជំហរដដែលក្នុងការជំទាស់ទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A5 ដូចគ្នាទៅនឹងឧបសម្ព័ន្ធមុនៗ ។ រីឯមេធាវី ជាតិ សុន អារុណ បានធ្វើការរៀបរាប់ពីឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធនេះ និងអះអាងថាសហព្រះរាជអាជ្ញាបានយកឯកសារដែលមិនទាន់ធ្វើការបញ្ជាក់អំពីយថាភាពមកចោទប្រកាន់ចំពោះកូនក្តីរបស់ខ្លួនដោយមិនសមហេតុផល ។ លោកមេធាវីបានបន្តថា កូនក្តីរបស់ខ្លួននឹងធ្វើការឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាដោយម៉ត់ចត់ ក្លាហាន និងមិនរារែក ប្រសិនបើឯកសារទាំងអស់ត្រូវបានបញ្ជាក់ពីភាពគួរឲ្យទុកចិត្តបាន និងប្រភពច្បាស់លាស់ ។ ម៉្យាងទៀត នួន ជា នឹងពុំរារែកចំពោះការចោទប្រកាន់របស់ខ្លួន

នោះទេ ប្រសិនបើ នួន ជា ជឿជាក់ថាឯកសារទាំងនោះពិតជាឯកសារ ដែលធ្វើឡើងកាលពីសម័យរបស់ខ្លួនពិតមែន ។ ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានផ្តល់សក្ខីកម្មច្បាស់លាស់ថាតើខ្លួនបានទទួលឯកសាររាប់ពាន់នោះមកពីទីណា និងដោយរបៀបណានោះទេ ។ លោកមេធាវីបានបន្តថា សហព្រះរាជអាជ្ញាបានចុះលេខឯកសារដោយខ្លួនឯង បោះត្រាដោយខ្លួនឯង សម្រាប់តែ




ដាក់បន្ទុកមកលើកូនក្តីរបស់ខ្លួន នួន ជា និងជនជាប់ចោទដទៃទៀតតែប៉ុណ្ណោះ ។ ឯកសារដែលសហព្រះរាជអាជ្ញាមានស្ទើរតែទាំងអស់ពុំមានអ្នកទទួលខុសត្រូវ គឺគ្មានហត្ថលេខា ស្នាមមេដៃ និងចុះថ្ងៃខែឆ្នាំ ហើយឯកសារទាំងអស់នៅវិលវល់ពេញប្រទេសដោយពុំមានយថាភាព និងប្រាកដប្រជា ។ លោកមេធាវីក៏បានចោទជាសំណួរទៅសហព្រះរាជអាជ្ញាថា "តើព្រះរាជអាជ្ញាអាចយល់បានទេថា ឯកសារទាំងអស់នេះមានអ្នកដទៃ មានក្រុមបច្ចាមិត្តរបស់កម្ពុជាប្រជាធិបតេយ្យអាចធ្វើអ្វី ឬបង្កើតដោយចេតនាដើម្បីជាផលប្រយោជន៍របស់គេ របស់ក្រុមគេនោះបានដែរឬទេ?" ។ ជាចុងក្រោយ លោកមេធាវីបានស្នើសុំឲ្យអង្គជំនុំជម្រះច្រានចោលនូវឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A5 និងទទូចឲ្យសហព្រះរាជអាជ្ញាបង្ហាញនូវឯកសារដើមដែលមានយថាភាពប្រាកដប្រជាដើម្បីឲ្យជនជាប់ចោទ នួន ជា អាចឆ្លើយតបដោយសុទ្ធចិត្តចំពោះសំណួររបស់សហព្រះរាជអាជ្ញា ។

## ២) ការជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារី

ពាក់ព័ន្ធទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5 ក្រុមមេធាវីការពារក្តីឲ្យជនជាប់ ចោទ អៀង សារី បានលើកឡើងនូវការជំទាស់ស្រដៀងគ្នាទៅនឹងក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា ។ ក្រុមមេធាវីការពារក្តី អៀង សារី បានលើកឡើងពីយថាភាព ភាពគួរឲ្យទុកចិត្តបាន និងភាពជាប់ពាក់ព័ន្ធនៃឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ធ្វើជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ និងស្នើឲ្យអ្នកតំណាង ឬនាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាមកផ្តល់ចម្លើយទាក់ទងនឹងឯកសារដែលខ្លួនទទួលបាន និងសង្វាក់នៃការរក្សាទុកឯកសារ ។ នៅក្នុងក្រុមមេធាវីការពារក្តីក៏បានស្នើសុំឲ្យតុលាការកោះហៅអ្នកនិពន្ធ ឬអ្នកសរសេរអត្ថបទដែលទាក់ទងនឹងកូនក្តីរបស់ខ្លួន គឺជនជាប់ចោទ អៀង សារី ឲ្យមកធ្វើការឆ្លើយតទល់នៅចំពោះមុខអង្គជំនុំជម្រះ ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1 ដែលទាក់ទងនឹងឯកសារសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ មេធាវីអន្តរជាតិការពារក្តី អៀង សារី លោក ម៉ៃឃើល ខាណាវ៉ាស បានលើកឡើង ការជំទាស់របស់ខ្លួនថា លោកនឹងធ្វើការជំទាស់ដោយសង្ខេបទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ នេះដោយសារតែនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ ក្រុមមេធាវីរបស់លោកបានដាក់សំណើជូនទៅអង្គជំនុំជម្រះដើម្បីធ្វើការជំទាស់ដោយដាក់លាក់និងលម្អិតទៅនឹងឯកសារឧបសម្ព័ន្ធ ដោយធ្វើការឆ្លើយតបដោយបញ្ជាក់ច្បាស់ពីប្រភេទឯកសារដែលខ្លួនបានជំទាស់ ។ ប៉ុន្តែដោយសារសហព្រះរាជអាជ្ញាបានដាក់ឯកសារទាំងអស់ចូលទៅក្នុងប្រភេទតែមួយ ដោយចាត់ទុកថាអត្ថបទទាំងនោះជាសេចក្តីថ្លែងការណ៍ដែលធ្វើដោយ អៀង សារី ដូចជាទស្សនាវដ្តី អត្ថបទសារព័ត៌មានកាសែត និងសន្ទរកថា មេធាវីការពារក្តី អៀង សារី

នឹងធ្វើការជំទាស់ជាទូទៅចំពោះឯកសារទាំងនេះ ។ ការជំទាស់នេះត្រូវបានលោកមេធាវី ខាណាវ៉ាស អះអាងថា ដោយសារតែសហព្រះរាជអាជ្ញាមិនបានធ្វើការបញ្ជាក់ឲ្យបានច្បាស់ថា តើឯកសារទាំងអស់នោះមានភាពគួរឲ្យទុកចិត្តបានដែរឬទេ ។ លោក ខាណាវ៉ាស បានបង្ហាញនូវអត្ថបទសារព័ត៌មាន និងកាសែតមួយចំនួនដែលលោកចាត់ទុកថាជាអត្ថបទដែលមិនអាចគួរឲ្យទុកចិត្តបាន និងមិនមានយថាភាព ដូចជាអត្ថបទដែលសរសេរដោយលោកស្រី អេលីហ្សាបិត បេកយ័រ ដែលបានដកស្រង់សម្ដីរបស់ អៀង សារី ហើយសហព្រះរាជអាជ្ញាចាត់ទុកការដកស្រង់នោះថាជាសេចក្ដីថ្លែងការណ៍របស់ អៀង សារី ។ ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាចំពោះបញ្ហានេះ គឺជារឿងដែលមិនអាចទទួលយកបានដោយក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ។ លោក ខាណាវ៉ាស ក៏បានស្នើទៅអង្គជំនុំជម្រះឲ្យកោះហៅលោកស្រី អេលីហ្សាបិត បេកយ័រ ដែលជាអ្នកសរសេរអត្ថបទសារព័ត៌មាន ទាក់ទងនឹងកូនក្ដីរបស់ខ្លួនឲ្យមកសាកសួរតទល់នៅចំពោះមុខអង្គជំនុំជម្រះដើម្បីបញ្ជាក់ថា តើការសរសេររបស់លោកស្រីធ្វើឡើងដោយរបៀបណា ។ ការធ្វើបែបនេះគឺដើម្បីបង្ហាញថាអត្ថបទទាំងអស់ដែលតុលាការយកមកប្រើប្រាស់គឺមានភាពគួរឲ្យទុកចិត្តបាន ។

ទាក់ទងនឹងឯកសារដែលទទួលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកមេធាវី ខាណាវ៉ាស បានធ្វើការជំទាស់ថា សហព្រះរាជអាជ្ញាបានពឹងផ្អែកទាំងស្រុងទៅលើលោក ឆាំង យុ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សហព្រះរាជអាជ្ញាមិនបានធ្វើការពិនិត្យពីភាពត្រឹមត្រូវនៃឯកសារទាំងអស់នោះទេ ហើយក៏មិនបានធ្វើការបញ្ជាក់ពីប្រភពឯកសារទាំងនោះឲ្យបានច្បាស់លាស់ដែរ ព្រោះឯកសារដែលមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជាចេញមកពីបណ្ណសារដ្ឋានជាតិ ។ ដូច្នេះឯកសារដែលចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាមិនទាន់មានភាពគួរឲ្យទុកចិត្តបាននៅឡើយទេ លុះត្រាតែមានការបញ្ជាក់ពីបណ្ណសារដ្ឋានជាតិថា ឯកសារទាំងនោះពិតជាមានយថាភាព ។ លើសពីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវតែបង្ហាញឲ្យបានថាតើអត្ថបទទាំងនោះមានប្រភពមកពីទីណា សេចក្ដីថ្លែងការណ៍របស់ អៀង សារី យកចេញមកពីទីកន្លែងណា ហើយថាតើឃ្លាឃ្លាដែល អៀង សារី បាននិយាយនោះមានការកែប្រែ ឬកែសម្រួលបន្ថែមពីលើដែរឬទេ នៅត្រង់ចំណុចនេះត្រូវតែមានការបញ្ជាក់ឲ្យបានច្បាស់ ។ បើមិនមានការបញ្ជាក់ឯករាជ្យពីបញ្ហានេះទេ ឯកសារដែលចោទប្រកាន់មកលើកូនក្ដីរបស់ខ្លួននឹងមិនមានទម្ងន់ជាភស្តុតាងឡើយ ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A2 លោកមេធាវី ខាណាវ៉ាស បានលើកឡើងថា រាល់ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ A2 គួរតែត្រូវបានបដិសេធចោល លុះត្រាតែសហព្រះរាជអាជ្ញាបានបង្ហាញអំពីយថាភាពភាពគួរឲ្យទុកចិត្តបាន និងភាពជាប់ពាក់ព័ន្ធនៃឯកសារ ហើយបង្ហាញថាតើអ្នកណាជាអ្នករៀបរៀងឯកសារទាំងអស់នោះឡើង ។ ប្រសិនបើសហព្រះរាជអាជ្ញាអាចបំពេញនូវលក្ខខណ្ឌទាំងអស់នេះបាន ក្រុមមេធាវីការពារក្ដីនឹងយល់ព្រមទទួលស្គាល់ឯកសារទាំងនោះ ។

ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធA3 លោកមេធាវី ខាណាវ៉ាស បានធ្វើការកត់សម្គាល់ដូចគ្នាទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1 និងឧបសម្ព័ន្ធ A2 ដែរ ។ ប៉ុន្តែលោកមេធាវីបានបន្ថែមថា សហព្រះរាជអាជ្ញាគួរតែជាអ្នកដែលត្រូវប្រឹងប្រែងក្នុងការបង្ហាញថា តើឯកសារដែលខ្លួនដាក់នៅចំពោះមុខអង្គជំនុំជម្រះមានប្រភពមកពីណា ហើយទទួលបានយ៉ាងដូចម្ដេច និងដោយរបៀបណា តើអ្នកណាជាអ្នកធ្វើឯកសារនោះ និងថាតើឯកសារទាំងនោះរក្សាទុកដោយរបៀបណា ។ ឆ្លើយតបទៅនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលលើកឡើងថាក្រុមមេធាវីការពារក្ដីបានធ្វើការជំទាស់ជាទូទៅ ដោយមិនបង្ហាញពីឯកសារណាមួយជាក់លាក់ដែលខ្លួនមានបំណងចង់ជំទាស់ លោកមេធាវី ខាណាវ៉ាស អះអាងថា “តុលាការមិនអាចឲ្យយើងចុចរកឯកសារក្នុងមួយជង្រុកធំដូចជាស្រូវអញ្ចឹង ហើយទៅរកឯកសារណាមួយលម្អិតដើម្បីយកមកធ្វើជំទាស់បាននោះទេ វាមិនច្បាស់នេះហើយជាករណីដែលយើងបានជួបប្រទះនៅថ្ងៃនេះ” ។ លោកមេធាវីបានបន្តទៀតថា ការណ៍ដែលសហព្រះរាជអាជ្ញាព្យាយាមបង្ហាញថាឯកសារដែលខ្លួនបានដាក់ជូនអង្គជំនុំជម្រះមានយថាភាពគួរឲ្យទុកចិត្តបាន និងមានភាពពាក់ព័ន្ធនោះ គឺជារឿងមិនត្រឹមត្រូវ ។ លុះបំផុតសហព្រះរាជអាជ្ញាត្រូវតែបង្ហាញតាមរយៈសាក្សី មិនមែន

ធ្វើសក្ខីកម្មខ្លួនឯងជំនួសសាក្សីនោះទេ ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះមិនអាចប្រើឯកសារដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង ០០១ ករណីរបស់ ឌុច មកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង០០២ នោះទេ ។ តុលាការត្រូវតែសួរដេញដោលសាជាថ្មីទៅលើឯកសារទាំងអស់នោះដើម្បីអាចដឹងពីយថាភាព គេមិនអាចគ្រាន់តែលើកឡើងថា ឯកសារនោះធ្លាប់ត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿង ០០១ ដូច្នេះអង្គជំនុំជម្រះអាចយកមកប្រើប្រាស់បាននៅក្នុងរឿង០០២ម្តងទៀតឡើយ ដោយលោកមេធាវីបានលើកឧទាហរណ៍ពីរឿងក្តី ប្រលីក ខេស ដែលជាយុត្តិសាស្ត្រនៅក្នុងតុលាការអន្តរជាតិ ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A4 លោកមេធាវី ខាណាវ៉ាស បានលើកឡើងនូវការជំទាស់របស់ខ្លួនគឺមានលក្ខណៈស្រដៀងគ្នាទៅនឹងការជំទាស់ចំពោះឯកសារដែលមានឧបសម្ព័ន្ធពី A1-A3 ។ ប៉ុន្តែលោកមេធាវីបានស្នើសុំឲ្យអង្គជំនុំជម្រះឲ្យពិនិត្យមើលឲ្យបានច្បាស់លាស់អំពីបញ្ហាសារទូរលេខដែលមានឈ្មោះកូនក្តីរបស់ខ្លួននៅលើឯកសារនោះដោយបញ្ជាក់ថា ការដែលមានឈ្មោះ កូនក្តី របស់ខ្លួននៅលើនោះមិនអាចចាត់ទុកថាកូនក្តីរបស់ខ្លួនបានទទួលសារទូរលេខទាំងអស់នោះឡើយ ។ ការដាក់ឈ្មោះកូនក្តីរបស់ខ្លួននៅលើសារទូរលេខទាំងនោះគឺគ្រាន់តែជាការចម្លងជូន ហើយវាជាបែបបទដែល គេបានប្រើនៅពេលនោះតែប៉ុណ្ណោះ ដូច្នេះមិនដឹងថាតើកូនក្តីរបស់ខ្លួនបានទទួល ឬមិនបានទទួលសារទូរលេខទាំងអស់នោះឡើយ ។ សហព្រះរាជអាជ្ញាត្រូវតែធ្វើការបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់អំពីយថាភាពនៃឯកសារទាំងអស់នោះគឺយ៉ាងហោចណាស់ត្រូវបង្ហាញថាតើអ្នកណាជាអ្នកធ្វើឯកសាររបាយការណ៍ទូរលេខ និងមានអត្តសញ្ញាណយ៉ាងដូចម្តេច ។

ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធA5 លោកមេធាវីខាណាវ៉ាស នៅតែប្រកាន់ជំហរក្នុងការជំទាស់ដាច់ទៅចំពោះឯកសារទាំងនោះ ដោយលើកឡើងថា របាយការណ៍ជាច្រើននៅតែមិនបានបង្ហាញពីភាពគួរឲ្យទុកចិត្តបាន ។ លោកមេធាវីក៏បានស្នើសាជាថ្មីទៀតទៅអង្គជំនុំជម្រះឲ្យកោះហៅលោកស្រី អេលីហ្សាបេត បេកឃ័រ ដើម្បីធ្វើការសាកសួរទាក់ទងនឹងអត្ថបទដែលលោកស្រីបានសរសេរទាក់ទងនឹងព្រឹត្តិការណ៍នៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ។ រីឯព័ត៌មានដែលមាននៅក្នុងដីកាបញ្ជូនរឿងនៅជំនុំជម្រះ ដែលសហព្រះរាជអាជ្ញាបានយកមកប្រើប្រាស់គឺគ្រាន់តែជាផ្នែកមួយនៃការពិចារណាទៅលើឯកសារតែប៉ុណ្ណោះមិនមែនមានន័យថា ព័ត៌មានដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះត្រូវតែទទួលយកនោះទេ ។ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញពីមូលដ្ឋានឲ្យបានច្បាស់លាស់ ហើយអង្គជំនុំជម្រះត្រូវតែពិចារណាថាតើព័ត៌មានទាំងអស់នោះទទួលយកបានឬក៏អត់ និងថាតើព័ត៌មានទាំងនោះមានភស្តុតាងដាក់បន្ទុកប៉ុនណា ។

### ៣) ការជំទាស់របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន

ទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5 ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន បានលើកឡើងនូវការជំទាស់របស់ខ្លួនដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការជំទាស់របស់ក្រុមមេធាវីរបស់ នួន ជា និង អៀង សារី ។ មេធាវីជាតិការពារក្តីឲ្យ ខៀវ សំផន គឺលោកមេធាវី គង់ សំអុន បានអះអាងនៅក្នុងមតិជំទាស់របស់ខ្លួនថា សហព្រះរាជអាជ្ញាបានដាក់ឯកសារជាច្រើនចូលទៅក្នុងសំណុំរឿងដោយមិនបានធ្វើការបញ្ជាក់ឲ្យបានដាក់លាក់ទៅលើឯកសារទាំងអស់នោះ គឺគ្រាន់តែធ្វើការបង្ហាញជាទូទៅប៉ុណ្ណោះ ។

ទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1 លោកមេធាវី គង់ សំអុន បានលើកឡើងថា ក្នុងចំណោមឯកសារចំនួន ២៣៣ នៅក្នុងឧបសម្ព័ន្ធ A1 មានឯកសារមិនដល់៧០ផង បានផ្តល់តម្រុយពីភាពគួរឲ្យជឿជាក់ ហើយតម្រុយទាំងអស់នោះក៏នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយដែរ ។ រីឯឯកសារដែលជាអត្ថបទ ទស្សនាវដ្តី សារព័ត៌មាន ដែលសហព្រះរាជអាជ្ញាបានយកមកប្រើប្រាស់ជាភស្តុតាងដើម្បីធ្វើការចោទប្រកាន់មកលើកូនក្តីរបស់ខ្លួនដូចជាទស្សនាវដ្តី ញូវីក (Newsweek) កាសែតញូវយ៉កថាម៍ (New York Times) ឬកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ (Washington Post) គឺមិនទាន់ត្រូវបានធ្វើការបញ្ជាក់ពីយថាភាពនៃអត្ថបទទាំងអស់នោះនៅឡើយទេ ។ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញថា តើអត្ថបទទាំងនោះមានភាពពាក់ព័ន្ធនឹងសំណុំរឿងដែរឬទេ ហើយថាតើអត្ថបទកាសែតសារព័ត៌មានទាំងអស់នោះមានភាពគួរឲ្យជឿជាក់ប៉ុនណា

និងមានប្រយោជន៍សម្រាប់ជាការដាក់បន្ទុកឬទេ ។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាត្រូវតែបង្ហាញឲ្យបានច្បាស់លាស់ថាតើអត្ថន័យនៃអត្ថបទសារព័ត៌មានទាំងអស់នោះពិតប្រាកដ ឬក្លែងក្លាយ ។ លោកមេធាវី សំអុន ក៏បានធ្វើលើកឡើងនូវការគាំទ្ររបស់ខ្លួនចំពោះការជំទាស់របស់លោកមេធាវីការពារក្តីអន្តរជាតិឲ្យជនជាប់ចោទ អៀង សារី ទាក់ទងនឹងការប្រើប្រាស់ឯកសារភស្តុតាងនៃសំណុំរឿង០០១ នៅក្នុងសំណុំរឿង០០២ ។ លោកបានបញ្ជាក់ថាប្រសិនបើសហព្រះរាជអាជ្ញាចង់យកភស្តុតាងទាំងអស់នោះមកប្រើប្រាស់សារជាថ្មីសម្រាប់សំណុំរឿង០០២ សហព្រះរាជអាជ្ញាត្រូវតែដាក់ភស្តុតាងទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះដើម្បីធ្វើការដេញដោលសារជាថ្មីពីយថាភាពនៃឯកសារទាំងអស់នោះ ។ លោកមេធាវីបានធ្វើការជំទាស់ទៅនឹងការសន្មតរបស់អង្គជំនុំជម្រះចំពោះភាពជឿជាក់ទៅលើឯកសារ និងផ្តល់តម្លៃទុកចិត្តទៅលើឯកសារដោយពុំមានការសួរដេញដោល ។ លោកបានលើកឡើងពីភាពដែលមិនគួរឲ្យជឿជាក់បានទាក់ទងនឹងការចុះផ្សាយរបស់អត្ថបទកាសែតមួយដែលលើកឡើងពីបទសម្ភាសន៍ជាមួយនឹង ខៀវ សំផន តែកាលបរិច្ឆេទនៃការចុះផ្សាយអត្ថបទសម្ភាសន៍ជាមួយនឹង ខៀវ សំផន នោះ គឺធ្វើឡើងមុនពេលនៃការសម្ភាសន៍ពិតប្រាកដទៅទៀត គឺមានន័យថា កាសែតបានចុះផ្សាយពីបទសម្ភាសន៍នោះហើយ ទើបធ្វើការសម្ភាសន៍កូនក្តីរបស់ខ្លួនជាក្រោយ ។ រីឯករណីផ្សេងទៀត មានអ្នកកាសែតបានចុះផ្សាយនៅក្នុងទំព័រកាសែតថា ធ្លាប់បានធ្វើសម្ភាសន៍ជាមួយនឹងកូនក្តីរបស់ខ្លួននៅអំឡុងពេលសន្និសីទនៅទីក្រុងកូឡុំបូ ប៉ុន្តែជាក់ស្តែងគ្មានអ្នកកាសែតណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចូលជួបធ្វើសម្ភាសន៍ជាមួយនឹង ខៀវ សំផន នៅក្នុងសន្និសីទនោះឡើយ ។ ដូច្នេះមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ស្នើសុំឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ចំពោះភាពគួរឲ្យទុកចិត្តបាននៃឯកសារអត្ថបទសារព័ត៌មានដែលមាននៅក្នុងឧបសម្ព័ន្ធ A1 ។

ពាក់ព័ន្ធទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A2 លោកមេធាវី គង់ សំអុន នៅតែលើកឡើងពីការមន្ទិលសង្ស័យរបស់ខ្លួនទាក់ទងនឹងខ្សែចង្វាក់នៃការរក្សាទុក និងការថែរក្សាឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ចូលទៅក្នុងឧបសម្ព័ន្ធនេះ ។ លោកមេធាវីបានបញ្ជាក់ថា ឯកសារចំនួន៨៣ដែលមាននៅក្នុងឧបសម្ព័ន្ធ A2 ទាក់ទងនឹងការបោះពុម្ពផ្សាយរបស់របបកម្ពុជាប្រជាធិបតេយ្យ មិនទាន់ត្រូវបានបង្ហាញឲ្យច្បាស់លាស់ដោយសហព្រះរាជអាជ្ញានៅឡើយទេ ។ ឯកសារដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមានចំនួន៥៤ឯកសារ ក្នុងនោះមានទស្សនាវដ្តីទង់បដិវត្តចំនួន២៤លេខ ទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ ចំនួន២៨លេខ និងសេចក្តីសង្ខេបនៃទស្សនាវដ្តីទាំងពីរមានចំនួន២លេខផ្សេងទៀត ។ សេចក្តីសង្ខេបនៃទស្សនាវដ្តី



ហ្សាក់ វែរហ្សេ មេធាវីអន្តរជាតិ របស់ ខៀវ សំផន

ទាំងពីរ សហព្រះរាជអាជ្ញាមិនបានផ្តល់ព័ត៌មានណាមួយដែលគួរឲ្យជឿជាក់ថាឯកសារទាំងនោះពិតជាត្រូវបានចម្លងត្រឹមត្រូវតាមច្បាប់ដើមនោះទេ ។ រីឯការបញ្ជាក់របស់សហព្រះរាជអាជ្ញាដែលថាឯកសារទស្សនាវដ្តីចំនួន៤៨ក្នុងចំណោម៥២ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបានពីបណ្ណសារដ្ឋានទួលស្លែងនៅឆ្នាំ១៩៩៩នោះ ព័ត៌មានទាំងអស់នេះមិនគ្រប់គ្រាន់នៅឡើយទេ ដោយបន្ថែមថា ឯកសារទាំងនោះអាចចេញមកពីប្រភពផ្សេង ទីកន្លែងផ្សេង ឬពេលវេលាផ្សេង ។ ទាក់ទងនឹងឯកសារសេចក្តី

សម្រេចរបស់បក្សកុម្មុយនិស្តកម្ពុជា លោកមេធាវីបានអះអាងថា សហព្រះរាជអាជ្ញាគ្រាន់តែបានបង្ហាញថាមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលពីលោក ប៊ែន ឃៀរនិន (BEN Kiernan) តាមរយៈលោក ដាវីត ហក (DAVID Hawk) ប៉ុន្តែមានព័ត៌មានខុសគ្នាចំពោះកាលៈទេសៈនៃការរកឃើញឯកសារទាំងអស់នោះ ។ ទាក់ទងនឹងឯកសារផ្សេងទៀតបើតាមលោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបានអះអាងថា ឯកសារនោះទំនងជារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានប្រគល់ឲ្យលោក ខៀវ កាញ៉ារិទ្ធ បន្ទាប់ពីតុលាការ




បដិវត្តឆ្នាំ១៩៧៩ បានកាត់ទោស ប៉ុល ពត និង អៀង សារី រួចរាល់ ។ ប៉ុន្តែលោក ខៀវ កាញ៉ារិទ្ធ បានអះអាងថា គាត់បានឃើញឯកសារទាំងនោះជាមួយនឹងកំណត់ហេតុប្រជុំនានារបស់គណៈអចិន្ត្រៃយ៍ នៅក្នុងផ្ទះរបស់មេដឹកនាំខ្មែរក្រហមនៅតាមបណ្តោយផ្លូវកម្ពុជាក្រោមទីក្រុងភ្នំពេញ ។ លោកមេធាវីអះអាងថាខ្លួននៅតែមានមន្ទិលសង្ស័យចំពោះប្រភពនៃការទទួលបានឯកសារទាំងនោះដោយសារតែសហព្រះរាជអាជ្ញា មិនបានបង្ហាញថាតើឯកសារទាំងនោះទទួលបានដោយពុំមានការកែច្នៃ ឬយ៉ាងណានោះទេ ។ ចំពោះឯកសារពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ លោកមេធាវីយល់ថា ឯកសារទាំងនោះសុទ្ធតែមានចំណុចគួរឲ្យសង្ស័យ ដោយសារព័ត៌មានដែលទទួលបានគឺចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រោះសហព្រះរាជអាជ្ញាមិនបានបង្ហាញពីការរក្សាទុកឯកសារ និងភាពគួរឲ្យជឿជាក់នៃឯកសារទាំងអស់នោះឡើយ ។

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងខបសម្ព័ន្ធ A3 លោកមេធាវីមេធាវី សំអុន បានលើកឡើងថា ក្នុងចំណោមឯកសារដែលមាននៅក្នុងខបសម្ព័ន្ធ A3 ទាំងអស់គឺមានតែឯកសារចំនួន២៧ប៉ុណ្ណោះដែលសហព្រះរាជអាជ្ញាបានធ្វើការបង្ហាញព័ត៌មាន ។ ដូច្នេះលោកនៅតែរក្សាការជំទាស់របស់ខ្លួនដូចគ្នាទៅនឹងការជំទាស់ទៅលើឯកសារដែលមាននៅក្នុងខបសម្ព័ន្ធ A2 ដែរ ដោយសារតែសហព្រះ រាជអាជ្ញាមិនបានបង្ហាញពីខ្សែចង្វាក់នៃការរក្សាទុក និងភាពត្រឹមត្រូវនៃឯកសារដែលបានបង្កឲ្យមានមន្ទិលសង្ស័យចំពោះឯកសារទាំងអស់នោះ ។ ក្រុមមេធាវីការពារក្តីឲ្យ ខៀវ សំផន នៅតែទទូចឲ្យអង្គជំនុំជម្រះកោះហៅអ្នកដែលជាប់ពាក់ព័ន្ធដើម្បីសួរដេញដោលពីភាពជឿជាក់នៃភស្តុតាង និងឯកសារទាំងអស់នោះ ។

ចំពោះឯកសារដែលមាននៅក្នុងខបសម្ព័ន្ធA4 លោកមេធាវី សំអុន បានលើកឡើងថា ក្នុងចំណោមឯកសារចំនួន៣៩៤ដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺមានតែឯកសារចំនួន៩៩ប៉ុណ្ណោះដែលមានការបង្ហាញពីភាពគួរឲ្យជឿជាក់បាន ប៉ុន្តែពុំទាន់មានការផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់នៅឡើយទេ ។

រីឯឯកសារនៅក្នុងខបសម្ព័ន្ធ A5 លោកមេធាវីបានបញ្ជាក់ថា នៅក្នុងខបសម្ព័ន្ធនេះសហព្រះរាជអាជ្ញាបានដាក់ឯកសារចំនួន៣៤៣ ប៉ុន្តែឯកសារដែលត្រូវបានបង្ហាញពីភាពគួរជឿជាក់មានចំនួន៦០ឯកសារតែប៉ុណ្ណោះ ។ លោកបានបន្ថែមថា ឯកសារចំនួន៥៣ក្នុងចំណោមឯកសារទាំងអស់នោះ គឺបានមកពីប្រទេសស៊ុយអែត ប៉ុន្តែអ្វីដែលក្រុមមេធាវីការពារក្តីចង់ដឹងគឺថាតើប្រទេសស៊ុយអែតទទួលបានឯកសារទាំងនោះដោយរបៀបណា នៅពេលណា និងពីនរណា ។ សហព្រះរាជអាជ្ញាត្រូវតែបញ្ជាក់ឲ្យបានច្បាស់ពីភាពគួរឲ្យជឿជាក់នៃឯកសារទាំងអស់ ហើយក្រុមមេធាវីការពារក្តីនៅតែរក្សាជំហររបស់ខ្លួនក្នុងការជំទាស់ទៅនឹងឯកសារដែលមាន

នៅក្នុងឧបសម្ព័ន្ធ A5 ដូចជាការជំទាស់នៅក្នុងឧបសម្ព័ន្ធមុនៗដែរ ។

**៤) ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់មេធាវីការពារក្តី**

**ក) ឧបសម្ព័ន្ធ A1**

ឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុម ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1 តំណាងសហព្រះរាជអាជ្ញាជាតិ លោក សេង ប៊ុនឃាង បានកត់សម្គាល់ថា ក្នុងចំណោមមេធាវីការពារក្តីទាំងបីក្រុម គឺមានតែក្រុមមេធាវីការពារក្តីឲ្យ អៀង សារី មួយប៉ុណ្ណោះដែលបានដាក់ការជំទាស់របស់ខ្លួនចំពោះឧបសម្ព័ន្ធដែលណែនាំដោយអង្គជំនុំជម្រះសាលាដំបូង ។ ប៉ុន្តែទម្រង់នៃការជំទាស់នោះ គឺធ្វើឡើងដដែលៗដោយមិនមានការអត្ថាធិប្បាយឲ្យច្បាស់លាស់នូវមូលដ្ឋាននៃការជំទាស់ចំពោះឯកសារដើម្បីធ្វើឲ្យការជំទាស់របស់ខ្លួនអាចទទួលយកបាននោះឡើយ ។ លោកបានបន្ថែមដោយលើកជាឧទាហរណ៍ថា សូម្បីតែកំណត់ត្រាចម្លើយរបស់ជនជាប់ចោទ អៀង សារី ខ្លួនឯងដែលបានផ្តល់ចម្លើយ នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ អៀង សារី ធ្វើការជំទាស់ដែរ ។ ក្រុមមេធាវីការពារក្តីរបស់ អៀង សារី ក៏បានធ្វើការជំទាស់ផងដែរចំពោះកំណត់ត្រាចម្លើយរបស់ជនជាប់ចោទ ខៀវ សំផន ដែលធ្វើឡើងនៅចំពោះសហចៅក្រមស៊ើបអង្កេត ដែលបានផ្តល់ភស្តុតាងទាក់ទងនឹងប្រវត្តិសាវតាររបស់ ខៀវ សំផន ខ្លួនឯង រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ ខ្លួននៅក្នុងរបបនោះ ។ លោក ប៊ុនឃាង បានព្យាយាមបង្ហាញពីភាពជឿជាក់នៃឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ចូលទៅក្នុងឧបសម្ព័ន្ធ ដោយលើកជាឧទាហរណ៍ទាក់ទងនឹងរបាយការណ៍សារព័ត៌មានដែលបានចុះផ្សាយពីវត្តមានរបស់ជនជាប់ចោទ អៀង សារី នៅក្នុងកិច្ចប្រជុំនានានៅឯបរទេស ដែលនៅពេលនោះ អៀង សារី បានរៀបរាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុង ។ លោកបានបន្ថែមថា ឯកសារទាំងអស់នោះគឺមានព័ត៌មានគ្រប់គ្រាន់ និងគួរឲ្យជឿជាក់បាន ដោយមិនចាំបាច់កោះអញ្ជើញអ្នកនិពន្ធ ឬអ្នកសរសេរអត្ថបទទាំងអស់នោះដើម្បីមកបញ្ជាក់នៅក្នុងសវនាការបន្ថែមទៀតឡើយ ដោយសារតែ អៀង សារី ខ្លួនឯង ក៏ធ្លាប់បានធ្វើការបញ្ជាក់ច្បាស់ៗពីមូលហេតុនៃការជម្លៀសប្រជាជនចេញ ពីក្រុង ។ ការបញ្ជាក់របស់ជនជាប់ចោទ អៀង សារី គឺបានធ្វើឡើងនៅចំពោះមុខអ្នកកាសែតផ្សេងៗគ្នា នៅអំឡុងពេលដំណើរទស្សនកិច្ចរបស់ខ្លួននៅឯបរទេស និងបានផ្តល់បទសម្ភាសន៍ដល់សហគមន៍អន្តរជាតិថែមទៀតផង ។ លោកបានអះអាងថា ករណីដែលសហព្រះរាជអាជ្ញាបដិសេធការកោះហៅអ្នកនិពន្ធ និងអ្នកសរសេរអត្ថបទនៃអត្ថបទសារព័ត៌មានដែលសរសេរទាក់ទងនឹងជនជាប់ចោទមកសាកសួរ នៅក្នុងសវនាការដោយសារតែអ្នកទាំងនោះ គឺគ្រាន់តែជាអ្នករាយការណ៍ មិនមែនជាអ្នកធ្វើសេចក្តីថ្លែងការណ៍នោះទេ ។ អ្នកដែលបានធ្វើសេចក្តីថ្លែងការណ៍ គឺជាជនជាប់ចោទដែលកំពុងមានវត្តមាននៅក្នុងសវនាការ ។

បន្តពីសហការីជាតិរបស់ខ្លួន លោក ឌេល លីសាក់ ( Dale Lysak) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្តីចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1 ដោយស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបដិសេធចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្តីទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធដែលសហព្រះរាជអាជ្ញាបានដាក់ចូលទៅក្នុងសំណុំរឿង ។ លោកក៏បានបន្ថែមថា សហព្រះរាជអាជ្ញាមានវិធីសាស្ត្រច្រើនក្នុងការបង្ហាញអំពីភាពគួរឲ្យជឿជាក់បាននៃសន្ទរកថាទាំងឡាយរបស់ជនជាប់ចោទដោយមិនចាំបាច់កោះអញ្ជើញអ្នកនិពន្ធ ឬអ្នកសរសេរអត្ថបទមកធ្វើការសាកសួរដេញដោលបន្ថែមនៅក្នុងសវនាការដូចជាការលើកឡើងរបស់ក្រុមមេធាវីការពារក្តីនោះទេ ។

ទាក់ទងនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា ចំពោះឯកសារដែលជាកិច្ចសន្ទនារវាងជនជាប់ចោទ នួន ជា ជាមួយនឹងឈ្មោះ ទឹម ផុន តំណាងសហព្រះរាជអាជ្ញាសូមធ្វើការបង្ហាញអំពីភាពគួរឲ្យជឿជាក់បាននៃឯកសារនេះថា សូម្បីជនជាប់ចោទ នួន ជា ក៏បានទទួលស្គាល់ថាខ្លួនធ្លាប់បាននិយាយលេងជាមួយនឹងឈ្មោះ ទឹម ផុន នេះដែរ ។ សហព្រះរាជអាជ្ញាយល់ថា ការជជែករវាង នួន ជា និងឈ្មោះ ទឹម ផុន គឺមានន័យច្រើនជាងការជជែកលេងធម្មតា ព្រោះរៀបរាប់របស់ នួន ជា នៅពេលនោះ គឺស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងការរៀបរាប់របស់ខ្លួននៅក្នុងតុលាការ

នាពេលនេះ ។

ឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ដែល លើកឡើងថា សហព្រះរាជអាជ្ញាបានដាក់ឯកសារច្រើនលើសលុបចូលនៅក្នុងឧបសម្ព័ន្ធ A1 លោក ឌេល លីសាក់ បានបញ្ជាក់ថា ឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ចូលទៅក្នុងឧបសម្ព័ន្ធនីមួយៗ គឺមានអត្តសញ្ញាណច្បាស់លាស់ ។ ដូច្នេះសហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបដិសេធចំពោះវជំទាស់របស់ក្រុមមេធាវីការពារក្តីឲ្យ អៀង សារី ។

ឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ពាក់ព័ន្ធនឹង ភាពជឿជាក់បាននៃឯកសារ លោក ឌេល លីសាក់ បានអះអាងថា សហព្រះរាជអាជ្ញានឹងមិនផ្តល់ព័ត៌មានលម្អិតទៅលើឯកសារនីមួយៗនោះទេ ដោយសារឯកសារទាំងនោះជាឯកសារទូទៅ ។ លោកបានបន្តថា ព័ត៌មានលម្អិតដែលសហព្រះរាជអាជ្ញានឹងផ្តល់ជូននៅក្នុងឧបសម្ព័ន្ធរៀបរាប់ពីឯកសារនីមួយៗ ហើយក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន អាចស្វែងរកព័ត៌មាននៃឯកសារទាំងនោះបាននៅក្នុងសំណុំរឿង ។ ចំពោះការជំទាស់ថាមិនត្រូវប្រើប្រាស់ឯកសារនៃសំណុំរឿង០០១ នៅក្នុងសំណុំរឿង០០២ គឺមិនត្រឹមត្រូវនោះទេ ។

### ខ) ឧបសម្ព័ន្ធ A2

ឆ្លើយតបទៅនឹងការជំទាស់ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A2 របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុម តំណាងសហព្រះរាជអាជ្ញាអន្តរជាតិលោក វាំងសង់ វាយដ៍ ដេស្មាឯល បានធ្វើការកត់សម្គាល់ថា ក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ នួន ជា និង អៀង សារី មានការយល់ច្រឡំចំពោះលក្ខណៈវិនិច្ឆ័យដែលត្រូវអនុវត្តនៅក្នុងតុលាការនេះ ។ លោកបានបន្ថែមថា យថាភាពនៃឯកសារនឹងត្រូវកម្រិតត្រឹមតែឯកសារ ឬប្រភេទឯកសារដែលក្រុមមេធាវីការពារក្តីគិតថាមិនមានគួរឲ្យជឿជាក់បាន បើយោងតាមវិធាន៨៧(៣) ។ ប៉ុន្តែក្រុមមេធាវីការពារក្តីរបស់ នួន ជា និង អៀង សារី មិនបានធ្វើការបង្ហាញពីតម្លៃនៃការជំទាស់របស់ខ្លួនដើម្បីឲ្យសើរើពីយថាភាពបឋមនៃឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ជូនអង្គជំនុំជម្រះនោះទេ ។ ចំណែកឯក្រុមមេធាវីរបស់ ខៀវ សំផន បានលើកឡើងនូវការជំទាស់ដដែលដែលការជំទាស់នេះធ្លាប់ត្រូវបានអង្គជំនុំជម្រះធ្វើការហាមឃាត់ម្តងរួចមកហើយ ។

លោក ដេស្មាឯល ក៏បានបញ្ជាក់បន្ថែមថា រាល់ឯកសារដែលសហព្រះរាជអាជ្ញាដាក់ចូលទៅក្នុងឧបសម្ព័ន្ធ A2 គឺជាឯកសារដែលជាប់ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធរដ្ឋបាលមជ្ឈិម គណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ តួនាទីរបស់ជនជាប់ចោទ និងការជន្លៀសប្រជាជនដោយបង្ខំ ។ ដូច្នេះរាល់ឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ គឺសុទ្ធតែមានកាជាប់ពាក់ព័ន្ធទៅនឹងអង្គហេតុសម្រាប់សវនាការដំណាក់កាលដំបូងនេះ ។

លោក វេង ហ៊ិត់ តំណាងសហព្រះរាជអាជ្ញាជាតិ បានបន្តពីសហការីអន្តរជាតិរបស់ខ្លួន ដោយបានធ្វើការឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុមទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A2 ។ លោកបានឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវី ខៀវ សំផន ដែលបានអះអាងថា សហព្រះរាជអាជ្ញាមិនបានបង្ហាញពីប្រភព និងភាពគួរឲ្យជឿជាក់នៃឯកសារដែលខ្លួនបានដាក់ដូចជាឯកសារទាក់ទងនឹងការបោះពុម្ពផ្សាយរបស់បក្ស និងឯកសារទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជាដោយបានស្នើសុំទៅអង្គជំនុំជម្រះដើម្បីបង្ហាញទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍នៃរបបកម្ពុជាប្រជាធិបតេយ្យទៅគ្រប់ភាគី និងបានធ្វើការពន្យល់លម្អិតពីចំណុចនីមួយៗទៅដល់ក្រុមមេធាវីការពារក្តីដើម្បីបង្ហាញពីភាពគួរឲ្យជឿជាក់ និងពីយថាភាពនៃឯកសារទាំងនោះ ។

ឆ្លើយតបទៅនឹងការបដិសេធរបស់ជនជាប់ចោទ នួន ជា ទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្ត លោកតំណាងសហព្រះរាជអាជ្ញាជាតិបានអះអាងថា ការបដិសេធរបស់ជនជាប់ចោទ នួន ជា គឺជាការមិនត្រឹមត្រូវ ដោយសារទស្សនាវដ្តីទង់បដិវត្តត្រូវបានបោះពុម្ពផ្សាយយ៉ាងពិតប្រាកដ និងមិនមានទស្សនាវដ្តីទង់ក្រហមដូចជាការលើកឡើងរបស់ នួន ជា នោះទេ ។ ការណ៍ដែល នួន ជា យល់ថាមានទស្សនាវដ្តីទង់ក្រហមនោះ គឺដោយសារតែនៅលើក្របមុខនៃទស្សនាវដ្តីទង់បដិវត្តមានទង់ពណ៌ក្រហម និងមិនមែនមានទង់មួយ គឺមានទង់ចំនួនប្រាំ ។ លោកបានបន្តថា នៅក្នុងអំឡុងពេលនៃ

របបកម្ពុជាប្រជាធិបតេយ្យ ទស្សនាវដ្តីទង់បដិវត្តត្រូវបានបោះពុម្ពផ្សាយចំនួនត្រឹមតែប្រាំដងប៉ុណ្ណោះ ។ ចំពោះការលើកឡើងរបស់ នួន ជា ដែលថាទស្សនាវដ្តីនោះមានការផ្លាស់ប្តូរគឺត្រឹមត្រូវ ព្រោះនៅក្នុងឆ្នាំ១៩៧៧មានការផ្លាស់ប្តូរទម្រង់នៃទស្សនាវដ្តីពិតប្រាកដមែន ។ រីឯទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ ដែលបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជា គឺមានចំនួន២៨លេខ ដោយធ្វើឡើងចាប់តាំងពីឆ្នាំ១៩៧៤រហូតដល់លេខចុងក្រោយនៅឆ្នាំ១៩៧៨ និងមិនមានការផ្លាស់ប្តូរទ្រង់ទ្រាយនោះទេ ។ លោកបានបញ្ជាក់ថា ទស្សនាវដ្តីនេះមានទម្រង់ដូចជាទស្សនាវដ្តីទង់បដិវត្តដូច្នេះដែរ ចំណែកឯលេខពិសេសនៃទស្សនាវដ្តីនេះគឺមិនមានដាក់លេខនៅពីលើក្របនោះទេ ។ អ្នកដែលអាចទទួលបានទស្សនាវដ្តីទាំងអស់នោះ គឺមានតែសមាជិកបក្សកុម្មុយនីស្តប៉ុណ្ណោះ ។ ពាក្យដែលប្រើប្រាស់ជាញឹកញាប់នៅក្នុងទស្សនាវដ្តីទង់បដិវត្តនិងទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ មានដូចជា ពួកចក្រពត្តិ ខ្មាំងស៊ីរូងផ្ទៃក្នុង ពួកសក្តិភូមិជាដើម ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ដេស្មាឯល បានលើកឡើងថា ជាការពិតការស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញា អាចធ្វើទៅបានដោយសារមានឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកសារមួយចំនួនដែលបានមកពីសារមន្ទីរទួលស្លែង ។ លោកបានបញ្ជាក់បន្ថែមថា ឯកសារភាគច្រើនគឺមានភាពគួរឲ្យទុកចិត្តបាន ដោយសារតែឯកសារទាំងអស់នោះគឺមានទម្រង់ស្រដៀងៗគ្នា និងមានភាពស៊ីចង្វាក់គ្នា ហើយមានការបោះផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជាដូចគ្នា ដោយលើកឧទាហរណ៍ទាក់ទងនឹងកំណត់ហេតុរបស់ប្រធានភូមិភាគ សេចក្តីណែនាំ និងសេចក្តីសម្រេចរបស់គណៈមជ្ឈិម ទស្សនាវដ្តីទង់បដិវត្ត និងសេចក្តីប្រកាសសារព័ត៌មានរបស់បក្សកុម្មុយនីស្តកម្ពុជា ចុះឆ្នាំ១៩៧៦ ។

### ក) ឧបសម្ព័ន្ធ A3

ពាក់ព័ន្ធនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A3 តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក វ៉ាំងសង់ វ៉ាយន៍ ដេស្មាឯល បានឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុមថា ការលើកឡើងរបស់ក្រុមមេធាវីការពារក្តីដែលស្នើសុំឲ្យ



អ្នកចូលរួមកំពុងឈរមើលព័ត៌មានលើប៉ាណូខាងក្រៅបរិវេណអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

មានការផ្ទៀងផ្ទាត់ឯកសាររាប់ពាន់ឡើងវិញនោះ គឺជារឿងដែលមិនត្រឹមត្រូវ ។ នៅក្នុងយុត្តិសាស្ត្រអន្តរជាតិ មិនបានតម្រូវឲ្យមានការត្រួតពិនិត្យទៅលើខ្សែចង្វាក់នៃការកាន់កាប់ឯកសារនោះទេ ប៉ុន្តែគេត្រូវពិនិត្យមើលថាតើឯកសារដែលបានដាក់ជូនទៅអង្គជំនុំជម្រះគួរទុកចិត្តបានដែរឬទេ? មានភាពពាក់ព័ន្ធដែរឬទេ? ។ លោកបានអះអាងថា ការលើកឡើងរបស់លោក ម៉ៃឃើល ខារណាវ៉ាស ដែលចង់ឲ្យសហព្រះរាជអាជ្ញាបង្ហាញពីយថាភាព ភាពគួរឲ្យជឿជាក់នៃឯកសារ និងសុំឲ្យមានការផ្តល់សក្ខីកម្មគឺជាការចង់បំបិទមាត់របស់សហព្រះរាជអាជ្ញាតែម្តង ។ ចំពោះឯកសារជាច្រើនដែលមាននៅក្នុងឧបសម្ព័ន្ធ A3 សហព្រះរាជអាជ្ញាគឺបានធ្វើការបកស្រាយរួចមក ហើយ ។

រីឯការលើកឡើងរបស់លោក សុន អារុណ មេធាវីការពាររបស់ នួន ជា ដែលអះអាងថា ឯកសារដែលដាក់ចូលក្នុងឧបសម្ព័ន្ធដោយសហព្រះរាជអាជ្ញាមានភាពលំបាកអាន និងមិនមានភាពគួរឲ្យជឿជាក់បាន គឺជារឿងដែលមិនត្រឹមត្រូវ ព្រោះឯកសារដែលមាននៅក្នុងប្រព័ន្ធ ហ្សាយឡូប គឺគ្រប់ភាគីអាចអានស្រួលជាងឯកសារដែលបញ្ចាំងនៅលើអេក្រង់ដែលមេធាវីការពារក្តីបានធ្វើទៅទៀត ។ ឆ្លើយតបនឹងការលើកឡើងរបស់លោក គង់ សំអុន មេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានចោទជាសំណួរទៅវិញថាតើមេធាវី ខៀវ សំផន អាចមកសើរើភាពមិនអាចគួរឲ្យជឿជាក់បាននៃឯកសារទាំងអស់ដោគ្រាន់តែយកហេតុផលថាខ្សែសង្វាក់នៃការកាន់កាប់ឯកសារមានភាពមិនច្បាស់លាស់? លោកក៏បានលើកឡើងពីឯកសារជាច្រើន និងបាន ដកស្រង់សម្តីរបស់ជនជាប់ចោទ ខៀវ សំផន ដែលធ្វើសេចក្តីថ្លែងការណ៍បដិសេធថាខ្លួនមិនមានអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែនៅក្នុងការឆ្លើយតបទៅសំណួររបស់សហចៅក្រមស៊ើបអង្កេត ខៀវ សំផន បានទទួលស្គាល់ថាខ្លួនធ្លាប់បានចូលរួមនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ។

ទាក់ទងនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា និង អៀង សារី ចំពោះចង្វាក់នៃការរក្សាទុកឯកសារ លោក ដេស្មាឯល បានបញ្ជាក់ថា វាមិនមែនជាការចាំបាច់ឡើយដែលត្រូវបង្ហាញថាតើឯកសារទាំងនោះចេញមកពីទីណាឬប្រភពណា ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបានធ្វើការបង្ហាញជូនអង្គជំនុំជម្រះនូវអំណះអំណាងអំពីភាពគួរឲ្យជឿជាក់នៃឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A3 ដោយបានលើកឡើងនូវឯកសារមួយចំនួនដូចជា កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈមជ្ឈិមគណៈអចិន្ត្រៃយ៍ របាយការណ៍ដែលប្រធានកងពលនៃកងយោធារបស់ខ្មែរក្រហមផ្ញើជូន នួន ជា និង លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ជាដើម ។

## ៨) ឧបសម្ព័ន្ធ A4

ពាក់ព័ន្ធនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A4 សហព្រះរាជអាជ្ញារងជាតិ លោក ច័ន្ទ តារាវស្សី បានធ្វើការកត់សម្គាល់ថាក្រុមមេធាវីការពារក្តីបានធ្វើការជំទាស់ដដែលៗ ដោយមិនបានបង្ហាញអំពីបញ្ហាជាក់លាក់ណាមួយចំពោះឯកសារដែលខ្លួនមានបំណងចង់ជំទាស់នោះទេ ។ លោក តារាវស្សី បានធ្វើការបកស្រាយពីភាពពាក់ព័ន្ធ និងភាពគួរឲ្យទុកចិត្តបាននៃឯកសារ និងបានឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី ចំពោះបញ្ហាចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម ។ ការជំទាស់របស់ក្រុមមេធាវីការពារក្តីត្រូវបានលើកឡើងក្នុងទម្រង់ដែលមានលក្ខណៈទូទៅទាក់ទងនឹងសារទូរលេខរបស់កម្ពុជាប្រជាធិបតេយ្យ កំណត់សម្គាល់របស់កម្ពុជាប្រជាធិបតេយ្យ របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ និងលិខិតរបស់កម្ពុជាប្រជាធិបតេយ្យ ។ លោកបានបន្ថែមថា នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺមិនបានតម្រូវថាភស្តុតាងត្រូវតែបង្ហាញជូនតាមរយៈភស្តុតាងជាសាក្សីនោះទេ ហើយក៏មិនបានតម្រូវឲ្យធ្វើការបង្ហាញពីអ្នកនិពន្ធនៃឯកសារដែលជាការផ្ទុយទៅនឹងលក្ខណៈនៃការស្វែងរកភាពគួរឲ្យទុកចិត្ត និងយថាភាពនៃឯកសារក្នុងដំណាក់កាលនៃការទទួលយកភស្តុតាងនេះដែរ ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក អាប់ឌុលឡាក់ ថារីក បានឆ្លើយតបបន្ថែមទៅលើសហការីជាតិរបស់ខ្លួនដោយអះអាងថា ការជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា ដែលថាឯកសារដាក់ដោយសហព្រះរាជអាជ្ញាមិនពាក់ព័ន្ធនឹងសវនាការ

ដំណាក់កាលដំបូងនេះ គឺជាការមិនត្រឹមត្រូវ ។ រីឯការលើកឡើងរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលស្នើសុំអង្គជំនុំជម្រះឲ្យកោះហៅអ្នកដែលរៀបចំសារទូរលេខ និងលេខកូដប្រាស្រ័យទាក់ទងដើម្បីមកធ្វើជាសាក្សីនោះ អង្គជំនុំជម្រះធ្លាប់កោះហៅអ្នកទាំងនោះមួយចំនួនមកធ្វើជាសាក្សីរួចទៅហើយ ហើយអ្នករៀបចំសារទូរលេខផ្សេងទៀតសហព្រះរាជអាជ្ញានឹងព្យាយាមកោះហៅមកធ្វើជាសាក្សីនៅពេលក្រោយ ។ ចំពោះឯកសារទាំងឡាយដែលមាននៅក្នុងឧបសម្ព័ន្ធ A4 គឺសហព្រះរាជអាជ្ញាបានដាក់ចូលក្នុងសំណុំរឿង០០១ម្តងរួចហើយ  អង្គជំនុំជម្រះក៏បានទទួលយកផងដែរ មានន័យថាឯកសារទាំងនេះគឺជាឯកសារដែលមានភាពគួរឲ្យជឿជាក់ជាបឋម ។ ដូច្នេះសហព្រះរាជអាជ្ញាស្នើថា ប្រសិនបើអង្គជំនុំជម្រះនឹងយកឯកសារទាំងនោះទៅពិចារណា គឺស្នើសុំឲ្យពិចារណាទាំងមូលតែម្តង ហើយសហព្រះរាជអាជ្ញារីករាយនឹងធ្វើការបញ្ជាក់បន្ថែមប្រសិនបើអង្គជំនុំជម្រះត្រូវការព័ត៌មានបន្ថែម ។

### ៤) ឧបសម្ព័ន្ធ A5

តំណាងសហព្រះរាជអាជ្ញាជាតិ លោក សេង ប៊ុនឃាង បានធ្វើការឆ្លើយតបទៅនឹងជំទាស់របស់មេធាវីការពារក្តីទាំងបីក្រុមពាក់ព័ន្ធនឹងឧបសម្ព័ន្ធ A5 ដោយបានរៀបរាប់ពីខ្លឹមសារនៃអត្ថបទរបាយការណ៍សារព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ និងខ្លឹមសារដែលមាននៅក្នុងសេចក្តីថ្លែងការរបស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកបានបញ្ជាក់ថា ឯកសារអត្ថបទសារព័ត៌មានទាំងអស់នោះ គឺមានភាពស៊ីសង្វាក់គ្នាទៅនឹងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះមិនមានការចាំបាច់ណាមួយដែលតម្រូវឲ្យមានការធ្វើសក្ខីកម្មរបស់អ្នកនិពន្ធនៃអត្ថបទសារព័ត៌មានទៀតឡើយ ។ បន្ទាប់មកទៀតលោកស្រី ហ្វាល់ហ្គុនី ដេបណាត (Falguni DEBNAT) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានរៀបរាប់នូវឯកសារមួយចំនួន ដើម្បីធ្វើការបញ្ជាក់បន្ថែមទៅលើយថាភាពនៃឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធA5 ។

លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត (William SMITH) បានឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី ដោយបានព្យាយាមបង្ហាញនូវភាពគួរឲ្យជឿជាក់នៃឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A5 និងអះអាងថាមិនមានភាពចាំបាច់ណាមួយដែលត្រូវបង្ហាញនូវឯកសារដើមឡើយ ។ លោកសហព្រះរាជអាជ្ញាបានស្នើសុំដល់អង្គជំនុំជម្រះឲ្យធ្វើការពិនិត្យដោយទូលំទូលាយទៅលើឯកសារជាជាងការពិនិត្យលើឯកសារណាមួយជាក់លាក់ ។ សហព្រះរាជអាជ្ញាគាំទ្រឲ្យមានការកោះហៅតំណាងណាម្នាក់ពីមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីធ្វើការបញ្ជាក់ពីភាពអាចទទួលយកបាននៃឯកសារ ។ ចំពោះការលើកឡើងរបស់មេធាវីការពារក្តី ខៀវ សំផន ដែលទាមទារឲ្យសហព្រះរាជអាជ្ញាបង្ហាញពីយថាភាពនៃឯកសារឲ្យលើសពីមតិសង្ស័យ លោក ស្មីត បានបញ្ជាក់ ថាច្បាប់មិនបានតម្រូវឲ្យធ្វើដូច្នេះឡើយ ។ លោកបានស្នើសុំឲ្យអង្គជំនុំជម្រះច្រានចោលនូវការជំទាស់របស់មេធាវីការពារក្តីទាំងអស់ហើយទទួលយកឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធទាំង៥ដែលខ្លួនបានដាក់ជូននៅចំពោះមុខអង្គជំនុំជម្រះ ។

### ៥) កំណត់សម្គាល់តបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅលើឧបសម្ព័ន្ធ A1-A5

លោកមេធាវី បាណាបេ ណេគុី (Barnabé NEKUI) បានធ្វើការឆ្លើយតបនឹងការជំទាស់របស់ក្រុមមេធាវីការពារក្តីទាំងបីក្រុម ដោយបដិសេធចំពោះគោលជំហររបស់មេធាវីការពារក្តីទាំងបីក្រុម ដែលទាមទារឲ្យមានការបញ្ជាក់ពីភាពអាចទទួលយកបានពីអ្នកនិពន្ធអត្ថបទ និងអ្នកសរសេរសារព័ត៌មាន ។ លោកមេធាវីបានលើកឡើងពីវិធីសាស្ត្រដែលបានប្រើនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ថា ការសម្រេចទទួលយកឯកសារជាសេចក្តីថ្លែងការណ៍របស់ជនជាប់ចោទ គឺមិនចាំបាច់មានការកោះហៅអ្នកនិពន្ធអត្ថបទឲ្យមកធ្វើសក្ខីកម្មនៅក្នុងសវនាការឡើយ ។ ការសម្រេចបែបនេះ ដោយសារតែអង្គជំនុំជម្រះយល់ឃើញថា គឺជាឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិនិត្យលើភាពអាចទទួលយកបាននៃភស្តុតាង ។

ចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A2 រួមមានឯកសារទស្សនាវដ្តីទង់បដិវត្ត  និងទង់យុវជនយុវនារីបដិវត្តន៍ដែលបានបោះពុម្ពផ្សាយដោយបក្សកុម្មុយនីស្តកម្ពុជាត្រូវបាន

មេធាវីជាតិ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោក វ៉ែន ពៅ បានលើកឡើងថា ឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធនេះគឺពិតជាមានយថាភាព ពីព្រោះជាឯកសារសំខាន់របស់បក្សដែលនិយាយពីគោលនយោបាយ មាគ៌ាបក្ស សកម្មភាពរបស់កងទ័ព និងសកម្មភាពបង្កបង្កើនផលជាដើម ។ លោកមេធាវីបានបន្ថែមថា ទស្សនាវដ្ដីទាំងនោះត្រូវបានជនជាប់ចោទ នួន ជា ទទួលស្គាល់ថា ខ្លួនធ្លាប់បានចូលរួមសរសេរទស្សនាវដ្ដីទាំងនោះ និងបានធ្វើការចែកចាយដល់កម្មាភិបាលគ្រប់ជាន់ថ្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ចំពោះសេចក្ដីណែនាំផ្សេងៗរបស់បក្សកុម្មុយនីស្ដគឺសុទ្ធសឹងតែចេញមកពីមន្ទីរ៨៧០ដែលមានអានុភាពអនុវត្តជាទូទៅ ។ លោកមេធាវី វ៉ែន ពៅ បានបញ្ជាក់ថា លោកនៅតែប្រកាន់ជំហរស្នើឲ្យក្រុមមេធាវីការពារក្ដីបង្ហាញនូវឯកសារចម្លងទាំងឡាយដែលខ្លួនយល់ថា មិនបានចម្លងចេញពីឯកសារដើម និងបង្ហាញពីការជំទាស់ ជាក់លាក់របស់ខ្លួនទៅនឹងឯកសារនីមួយៗ ។

ពាក់ព័ន្ធនឹងការជំទាស់របស់ក្រុមមេធាវីការពារក្ដីចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A3 មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហ្វីលីពីន ស៊ុតហ្ស៍ (Philippine SUTZ) បានធ្វើការឆ្លើយតបដោយបានលើកឡើងពីគោលការណ៍នៃការដាក់ភស្តុតាង និងថាមានតែអង្គជំនុំជម្រះប៉ុណ្ណោះ ដែលមានសិទ្ធិសម្រេចលើភាពអាចទទួលយកបាន និងតម្លៃនៃភស្តុតាង ។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡ (Civil Law) មានការបកស្រាយតាមន័យចង្អៀតទៅលើភាពគួរឲ្យជឿជាក់ យថាភាព និងភាពពាក់ព័ន្ធចំពោះឯកសារជាភស្តុតាង ហើយឯកសារទាំងនោះនឹងត្រូវបានអង្គជំនុំជម្រះច្រានចោល ប្រសិនបើតុលាការយល់ឃើញថាមិនពាក់ព័ន្ធនឹងអង្គហេតុ ។

ពាក់ព័ន្ធនឹងប្រភេទឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A4 មេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោក ឡោ ជុនធី បានអះអាងថា លោកសុំគាំទ្រចំពោះឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកបានបញ្ជាក់ថា ក្រោយរបបខ្មែរក្រហមបានដួលរលំទៅប្រជាជនខ្មែរមិនបានយកចិត្តទុកដាក់ក្នុងការប្រមែប្រមូលឯកសារដែលសេសសល់នោះទេ ហេតុនេះការងារប្រមែប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺពិតជាមានសារសំខាន់ ហើយឯកសារទាំងនោះពិតជាបង្ហាញនូវភាពគួរឲ្យទុកចិត្តបាន ។

ចំពោះប្រភេទឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A5 លោកមេធាវី ហុង គឹមសួន បានធ្វើការឆ្លើយតបទៅក្រុមមេធាវីការពារក្ដីរបស់ជនជាប់ចោទទាំងបីក្រុម ដោយបានធ្វើការកត់សម្គាល់ថាក្រុមមេធាវីការពារក្ដីទាំងអស់នៅតែលើកឡើងដដែលៗពីការជំទាស់របស់ខ្លួន ហើយពុំមានការជំទាស់ជាក់លាក់ទៅលើឯកសារណាមួយពិតប្រាកដឡើយ ។ ក្រុមមេធាវីការពារក្ដីបានធ្វើការជំទាស់ជាទូទៅ ដោយគ្រាន់តែអះអាងថាឯកសារទាំងអស់នោះមើលមិនច្បាស់ និងមិនមានឯកសារដើម ។ លោកមេធាវីបានចោទជាសំណួរថាតើអ្វីទៅជាអត្ថន័យនៃពាក្យថាយថាភាពនៃឯកសារ? តើត្រូវយកឯកសារទាំងអស់មកបង្ហាញនៅក្នុងតុលាការ ឬទើបថាឯកសារនោះមានយថាភាព? ។ លោកមេធាវីបានស្នើសុំឲ្យក្រុមមេធាវីការពារក្ដីត្រូវបានបង្ហាញឲ្យបានច្បាស់ថាតើឯកសារណាមួយដែលខ្លួនចង់ជំទាស់ ដើម្បីឲ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាអាចធ្វើការបញ្ជាក់ជូនបាន ។ លោកមេធាវី ក៏បានទទួលស្គាល់ដែរថា ឯកសារទាំងអស់ដែលដាក់ចូលក្នុងឧបសម្ព័ន្ធនោះមិនមែនសុទ្ធតែអាចទទួលយកបាននោះទេ ហើយក៏មិនមែនសុទ្ធតែមិនអាចទទួលយកបាននោះដែរ ។ ដូច្នេះលោកមេធាវីស្នើសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារទាំងឡាយដែលបានដាក់ចូលក្នុងឧបសម្ព័ន្ធពីទី១រហូតដល់ទី៥ ។

លោកស្រីមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានអះអាងបន្ថែមលើសហការីរបស់ខ្លួនដោយសង្កត់ធ្ងន់ទៅលើការជំទាស់របស់មេធាវីការពារក្ដីដែលធ្វើការតវ៉ាដដែលៗទៅលើឯកសារ A5 គឺមានលក្ខណៈទូលំទូលាយហួសហេតុ ។ លោកស្រីមេធាវីបានចាត់ទុកការជំទាស់បែបនេះថាជាការមិនឲ្យតម្លៃចំពោះកំណត់ហេតុរបស់ចៅក្រមស៊ើបអង្កេតដែលមានសមត្ថកិច្ចសម្រេចលើភាពអាចទទួលយកបាននៃឯកសារនោះ ។

ជាងនេះទៅទៀតការជំទាស់របស់មេធាវីការពារក្ដីគឺមានគោលបំណងពីរ ទីមួយគឺធ្វើយ៉ាងណាខ្លួនត្រូវជំទាស់ឲ្យបាន និងទីពីរគឺមានបំណងឲ្យភាគីមានការភាន់ច្រឡំ មិនធ្វើការពិភាក្សាទៅលើ

ភាពអាចទទួលយកបាននៃឯកសារ ដោយផ្ដោកមកពិភាក្សាទៅលើតម្លៃនៃភស្តុតាងទៅវិញ ។

## ៦) សេចក្ដីសន្និដ្ឋានរួមរបស់ក្រុមមេធាវីការពារក្ដីចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5

បន្ទាប់ពីការដេញដោលទៅលើឯកសារដែលមានពីឧបសម្ព័ន្ធ A1 ដល់ឧបសម្ព័ន A5 ពីសំណាក់ភាគីទាំងអស់រួចរាល់ អង្គជំនុំជម្រះបានផ្ដល់ឱកាសឲ្យមេធាវីការពារក្ដីឲ្យជនជាប់ចោទទាំងបីក្រុមឡើងធ្វើសេចក្ដីសន្និដ្ឋានចំពោះឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធទាំង៥ ។ សេចក្ដីសន្និដ្ឋានបញ្ចប់ត្រូវចាប់ផ្ដើមពីក្រុម



មន្ត្រីកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែកសៀវភៅដល់អ្នកចូលរួម



មេធាវីការពារក្ដីរបស់ជនជាប់ចោទ នួន ជា និងបន្តទៅក្រុមមេធាវីការពារក្ដី អៀង សារី និងចុងក្រោយ គឺក្រុមមេធាវីរបស់ ខៀវ សំផន ។

### ក) សេចក្ដីសន្និដ្ឋានរបស់ក្រុមមេធាវី នួន ជា

លោកមេធាវីអន្តរជាតិការពារក្ដីឲ្យជនជាប់ចោទ នួន ជា គឺលោក អេនឌ្រូ អ៊ីនូហ៊្វី បានលើកឡើងនូវអំណះអំណាងពាចំណុចនៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួន ។ ទី១ អង្គជំនុំជម្រះត្រូវតែពិចារណាអំពីតុល្យភាពផលប្រយោជន៍រវាងភាគីទាំងអស់ មានន័យថា អង្គជំនុំជម្រះត្រូវតែគិតអំពីសិទ្ធិរបស់កូនក្ដីរបស់ខ្លួនក្នុងការតវ៉ាចំពោះភស្តុតាងដែលបានដាក់ជូនអង្គជំនុំជម្រះដោយសហព្រះរាជអាជ្ញា ។ ទី២ គឺពាក់ព័ន្ធនឹងទំហំ និងលក្ខណៈនៃឯកសារដែលដាក់ជូនអង្គជំនុំជម្រះដោយសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាបានដាក់ឯកសារជាច្រើនចូលក្នុងសំណុំរឿងនៅដំណាក់កាលដំបូង ប៉ុន្តែតាមការពិតមានឯកសារតិចតួចប៉ុណ្ណោះដែលទាក់ទងនឹងសវនាការវគ្គដំបូងនេះ ។ ដូច្នេះក្រុមមេធាវីការពារក្ដីស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការកម្រិតតែឯកសារណាដែលពាក់ព័ន្ធនឹងអង្គហេតុនៅក្នុងសវនាការដំណាក់ការដំបូងនេះ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការយកមកដេញដោលនៅក្នុងសវនាការ ។

ទី៣ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះត្រូវតែមានព្រះរាជវត្តមានរបស់សម្ដេច នរោត្ដម សីហនុ អង្គជំនុំជម្រះមិនអាចធ្វើឡើងដោយមិនមានវត្តមានរបស់ព្រះអង្គបានឡើយ ។ អង្គជំនុំជម្រះក៏ត្រូវកោះហៅលោក ឆាំង យុ មកធ្វើសក្ខីកម្មនៅក្នុងសវនាការផងដែរ ដោយសារតែលោកគឺជាមនុស្សម្នាក់ដែលមានសមត្ថភាពក្នុងការបញ្ជាក់ពីភាពពាក់ព័ន្ធនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

រីឯលោកមេធាវីជាតិ សុន អារុណ បានលើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋានថា កូនក្ដីរបស់ខ្លួនគឺជនជាប់ចោទ នួន ជា គ្រាន់តែ

ស្នើសុំឲ្យបង្ហាញពីច្បាប់ដើមនៃទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជននិងយុវនារីបដិវត្តន៍ប៉ុណ្ណោះ មិនបានស្នើសុំឲ្យមានការបង្ហាញឯកសារពាក់ព័ន្ធដូចជាការលើកឡើងរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ចំពោះចំណុចមួយទៀត មានឯកសារមួយចំនួន គឺលំបាកក្នុងការអាន និងលំបាកយល់ ដោយសារតែឯកសារទាំងអស់នោះមិនច្បាស់ ។ លោកបានបន្ថែមថា ការស្នើសុំឯកសារដើម និងការបញ្ជាក់ពីយថាភាពនៃឯកសារ គឺមិនមែនជាការព្យាយាមពន្យាពេលរបស់ក្រុមមេធាវីការពារក្តីនោះទេ ប៉ុន្តែគឺដើម្បីជាការស្វែងរកការពិត និងយុត្តិធម៌ដែលមានប្រយោជន៍ ។


អ្នកចូលរួមតម្រង់ជួរចូលបន្ទប់សវនាការ

## ខ) សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវី អៀង សារី

មេធាវីអន្តរជាតិលោក ម៉ៃឃើល ខាណាវ៉ាស បានធ្វើសេចក្តីសន្និដ្ឋានទាក់ទងនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធពីA1 ដល់ឧបសម្ព័ន្ធ A5 ថា លោកសុំធ្វើការបដិសេធចំពោះការចោទប្រកាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចោទប្រកាន់ក្រុមមេធាវីការពារក្តីថាជាអ្នករំលោភបំពានទៅលើកិច្ចដំណើរការនីតិវិធី ។ លោកបានអះអាងថា ការជំទាស់ទៅនឹងការដាក់ឯកសារដោយសហព្រះរាជអាជ្ញារបស់ក្រុមមេធាវីការពារក្តីគឺជារឿងត្រឹមត្រូវ ព្រោះមេធាវីការពារក្តីមានសិទ្ធិតវ៉ាចំពោះភាពទទួលយកបាននៃភស្តុតាងដោយលោកមេធាវីបានលើកឡើងពីយុត្តិសាស្ត្រអន្តរជាតិ ដែលមាននៅក្នុងរឿងក្តីប្រលឹក ។ លោកមេធាវីបានបន្ថែមថា ក្រុមមេធាវីការពារក្តីនឹងបាត់បង់នូវផលប្រយោជន៍ ប្រសិនបើមេធាវីការពារក្តីត្រូវបង្ខំឲ្យប្រើប្រាស់ពេលវេលាដែលអង្គជំនុំជម្រះផ្តល់ឲ្យសម្រាប់ដេញដោលធ្វើការបង្ហាញពីយថាភាព ឬភាពគួរឲ្យជឿជាក់បាននៃឯកសារដែលខ្លួនបានជំទាស់នោះ ។ ការបង្ហាញពីយថាភាព ភាពគួរឲ្យជឿជាក់ និងតម្លៃនៃភស្តុតាង គឺជាភារកិច្ចរបស់សហព្រះរាជអាជ្ញា ដើម្បីបញ្ជាក់ជូនអង្គជំនុំជម្រះ និងកោះហៅសាក្សីដែលពាក់ព័ន្ធមកធ្វើការបញ្ជាក់បន្ថែម ។

## គ) សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវី ខៀវ សំផន

លោកមេធាវីជាតិគង់ សំអុន បានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនថា លោកមិនបដិសេធចំពោះឯកសារទាំងអស់ដែលចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ ប៉ុន្តែលោកស្នើសុំឲ្យអង្គជំនុំជម្រះពិនិត្យដោយយកចិត្តទុកដាក់ និងដាក់លាក់ទៅលើឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក មេធាវី សំអុន ក៏បានបញ្ជាក់ថា ជំហររបស់លោកគឺមិនចង់ឲ្យឯកសារដែលដាក់ចូលក្នុងសំណុំរឿងមិន ឆ្លងកាត់ការផ្ទៀងផ្ទាត់នោះទេ គឺចាំបាច់ត្រូវតែមានការត្រួតពិនិត្យ និងវាយតម្លៃចំពោះឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាត្រូវតែបង្ហាញឲ្យលើសពីវិមតិសង្ស័យ ចំពោះឯកសារទាំងឡាយដែលមានភាពមិនច្បាស់លាស់ ហើយមិនអាចលើកឡើងថា ដោយសារតែឯកសារច្រើនមិនចាំបាច់បង្ហាញភស្តុតាងឲ្យលើសពីវិមតិសង្ស័យនោះទេ ។ សហព្រះរាជអាជ្ញាគួរតែបង្ហាញពីភាពគួរឲ្យជឿជាក់ និងភាពជាប់ពាក់ព័ន្ធដើម្បីជាប្រយោជន៍ដល់ការស្វែងរកការពិត ។

ក្រោយពីក្រុមមេធាវីការពារបានបញ្ចប់សេចក្តីសន្និដ្ឋានលើឯកសារដែលមានក្នុងឧបសម្ព័ន្ធ A1-A5 លោកប្រធានអង្គជំនុំជម្រះ និល ណុន បានប្រកាសជូនដំណឹងទៅដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងធ្វើការសាកសួរដេញដោលទៅលើសាក្សីពីររូប នៅថ្ងៃទី២៣ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ ។

## ■ សវនាការលើសំណុំរឿង០០២ ៖ សក្ខីកម្មរបស់លោកនាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា

### ថ្ងៃទី ២៣-២៥ ខែមករា ឆ្នាំ២០១២

### សេចក្តីផ្តើម

នៅថ្ងៃទី២៣-២៥ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការស្តីពីការសួរដេញដោលពីយថាភាពនៃឯកសារ និងអនុញ្ញាតឲ្យភាគី ទាំងអស់សួរដេញដោលលោក វ៉ាន់ថាន់ ពៅដារ៉ា ដែលមានតួនាទីជានាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គោលបំណងនៃការសាកសួរដេញដោល គឺផ្តោតលើការប្រមូលចងក្រងឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។

ភាគីទាំងអស់ត្រូវបានអនុញ្ញាតឲ្យធ្វើការសាកសួរសាក្សីដែលជានាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីបញ្ជាក់ពីឯករាជ្យភាព និងភាពមិនលម្អៀងរបស់ស្ថាប័ននេះ ។ ភាគីបានសួរដេញដោលដោយផ្តោតសំខាន់ទៅលើប្រវត្តិសាវតាររបស់លោកនាយករង ភាពឯករាជ្យ កម្មវត្ថុក្នុងការប្រមូលចងក្រងឯកសារ ការធ្វើយថាភាពនៃឯកសារ វិធីសាស្ត្រក្នុងការរៀបចំ និងថែរក្សាឯកសារ និងភាពមិនលម្អៀងក្នុងការផ្តល់ឯកសាររបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា ។



វ៉ាន់ថាន់ ពៅដារ៉ា

### ១) ការសួរដេញដោលពីប្រវត្តិសាវតាររបស់សាក្សីដោយអង្គជំនុំជម្រះ

មុនការចាប់ផ្តើមនីតិវិធីសួរដេញដោលទៅលើសាក្សី លោកប្រធានអង្គជំនុំជម្រះ និល ណុន បាន សួរទៅលោក វ៉ាន់ថាន់ ពៅដារ៉ា ពីប្រវត្តិសាវតា និងបទពិសោធន៍ការងាររបស់លោកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានបញ្ជាក់ជូនទៅអង្គជំនុំជម្រះថា លោកមានតួនាទីជានាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដោយទទួលបន្ទុកផ្នែកការងារទូទៅ ជាពិសេសក្នុងការប្រមូលចងក្រង រៀបចំ និងគ្រប់គ្រងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាអស់រយៈពេល១៧ឆ្នាំ ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានបន្ថែមថា បន្ទាប់ពីបានចូលបម្រើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការគ្រប់គ្រង និងថែរក្សារចងក្រងឯកសារនៅសាកលវិទ្យាល័យ«ញូវសៅវែល»នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ។ បន្ទាប់មកលោកបានទទួលការបណ្តុះបណ្តាលទាក់ទងនឹងការស៊ើបអង្កេតបទឧក្រិដ្ឋកម្មអន្តរជាតិដែលធ្វើនៅប្រទេសអៀរឡង់ ។ លោកក៏បានទៅបន្តការសិក្សានៅសហរដ្ឋអាមេរិក ដោយបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់សិទ្ធិមនុស្សនិងមនុស្សធម៌អន្តរជាតិនៅសាកលវិទ្យាល័យ ណូត្រឺដេម (Notre Dame) ។ លោកត្រូវបានអង្គជំនុំជម្រះអញ្ជើញឲ្យមកផ្តល់សក្ខីកម្មក្នុងនាមតំណាងឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាមជ្ឈមណ្ឌលមួយផ្តល់ឯកសារច្រើនជាងគេបំផុតដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីធ្វើការជំនុំជម្រះសេចក្តីលើឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

### ២) ភាពឯករាជ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ភាពឯករាជ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាបញ្ហាសំខាន់បំផុតដែលអង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីទាំងអស់សួរម្តងហើយម្តងទៀតដើម្បីធានាឲ្យបានថាពិតជាស្ថាបន័មួយដែលធ្វើការ

ដោយឯករាជ្យ និងមិនមានភាពលម្អៀង ។ ជាក់ស្តែង ទាំងលោក ចៅក្រម យ៉ា សាខន តំណាងសហព្រះរាជអាជ្ញា មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ជនជាប់ចោទសុទ្ធតែបានចោទសួរពីរចនាសម្ព័ន្ធគ្រប់គ្រង និងប្រព័ន្ធហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាងនេះទៅទៀត ភាគីតែងតែសួរពីទំនាក់ទំនងរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាកលវិទ្យាល័យយ៉េល(ប្រភពដើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) ឬជាមួយរាជរដ្ឋាភិបាលកម្ពុជា ឬជាមួយនឹងរដ្ឋាភិបាលរបស់ប្រទេសផ្សេងៗទៀត ។ មូលហេតុដែលភាគីនៃរឿងក្តីបានចោទសួរលើបញ្ហាទាំងនេះ គឺដើម្បីឲ្យប្រាកដថា មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានរៀបចំ និងអនុវត្តការងាររបស់ខ្លួនដោយឯករាជ្យ ដោយមិនមានការជ្រៀតជ្រែក ឬបង្គាប់បញ្ជាពីស្ថាប័ន ឬម្ចាស់ជំនួយណាមួយឡើយ ។ ឆ្លើយតបទៅនឹងការចោទសួរទាំងនេះ លោក ពៅដារ៉ា បានធ្វើការបញ្ជាក់ពីរចំណុចធំៗ គឺរចនាសម្ព័ន្ធនៃការគ្រប់គ្រងនិងប្រព័ន្ធហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រង លោក ពៅដារ៉ា បានបញ្ជាក់ថាមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ដែលដើមឡើយគឺជាការិយាល័យសិក្សាស្រាវជ្រាវមួយរបស់សាកលវិទ្យាល័យយ៉េល ។ ដោយគម្រោងនេះមានអាណត្តិ២ឆ្នាំ ដូចនេះនៅឆ្នាំ១៩៩៧ ការិយាល័យនេះត្រូវបានប្រែឈ្មោះមកជាមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានបន្តការងាររបស់ខ្លួនដោយឯករាជ្យពីការងារនៃគម្រោងរបស់សកលវិទ្យាល័យយ៉េល មកទល់នឹងពេលបច្ចុប្បន្ននេះ ។ បន្ទាប់ពីអនុវត្តការងាររបស់ខ្លួនដោយឯករាជ្យ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានរៀបចំ និងគ្រប់គ្រងដោយលោក ឆាំង យុ មានតួនាទីជាប្រធានដែលជួយការងារដោយនាយករងចំនួនពីររូប និងមានបុគ្គលិកមួយចំនួនធ្វើការតាមគម្រោងរៀងៗខ្លួនដែលអ្នកទាំងអស់គ្នាសុទ្ធសឹងជាជនជាតិខ្មែរ ។ ទោះបីជាយ៉ាងនេះក្តី មជ្ឈមណ្ឌលឯកសារកម្ពុជាមានអ្នកប្រឹក្សាយោបល់ជាជនជាតិបរទេសផងដែរ ប៉ុន្តែរាល់គំនិតប្រឹក្សាយោបល់ទាំងអស់មិនតម្រូវឲ្យមជ្ឈមណ្ឌលត្រូវតែអនុវត្តតាមនោះទេ ពោលគឺរាល់ការសម្រេចគឺជាសិទ្ធិរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ចំពោះហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក ពៅដារ៉ា បានលើកឡើងថា បន្ទាប់ពីអនុវត្តការងាររបស់ខ្លួនដោយឯករាជ្យក្នុងឆ្នាំ១៩៩៧មក មជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលបានទទួលជំនួយហិរញ្ញវត្ថុពីសាកលវិទ្យាល័យយ៉េលទៀតឡើយ ។ តែទោះបីជាយ៉ាងនេះក្តី ស្ថាប័នទាំងពីរនៅតែមានទំនាក់ទំនងគ្នាជាដៃគូក្នុងការបញ្ជូនសិស្ស និស្សិត ដើម្បីធ្វើការសិក្សាស្រាវជ្រាវទៅវិញទៅមក ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មិនដែលទទួលបានជំនួយហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលកម្ពុជាផងដែរ ។ ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ជំនួយតាមរយៈការអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការចុះសិក្សាស្រាវជ្រាវនៅគ្រប់ទីកន្លែងទូទាំងប្រទេស ផ្តល់ការគាំពារផ្សេងៗទាក់ទងនឹងសុវត្ថិភាពនៅពេលបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅប្រមូលឯកសារ ។

លោក ពៅដារ៉ា បញ្ជាក់យ៉ាងច្បាស់ថា ថវិការបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានមកតាមរយៈការផ្តល់ជំនួយពីរដ្ឋាភិបាលរបស់ប្រទេសនានា អង្គការមិនរកប្រាក់ចំណេញផ្សេងៗ (USIAD, SIDA...) អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងសាកលវិទ្យាល័យនានា ។ ហើយរាល់ការផ្តល់ជំនួយមកឲ្យមជ្ឈមណ្ឌលឯកសារ គឺមិនមានការកំណត់លក្ខខណ្ឌណាមួយឡើយ ពោលគឺមជ្ឈមណ្ឌលឯកសារកម្ពុជាអនុវត្តគម្រោងរបស់ខ្លួនដោយឯករាជ្យ ។ ម្យ៉ាងទៀតម្ចាស់ជំនួយផ្សេងៗ ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជាក៏មិនដែលបានបង្គាប់បញ្ជាណាមួយមកលើមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យអនុវត្តការងារណាមួយឡើយ ។

## ៣) កម្មវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

កម្មវត្ថុក្នុងការប្រមូលឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាចំណុចសំខាន់មួយដែលនឹងឆ្លុះបញ្ចាំងពីឯករាជ្យភាព និងភាពមិនលម្អៀងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សំណួរជាច្រើនដែលបានចោទសួរក្នុងកំឡុងពេលសវនាការថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលចងក្រងឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីអ្វី?

ឆ្លើយតបទៅនឹងការចោទសួរទាំងនេះ លោក ពៅដារ៉ា បានលើកឡើងថា ក្នុងការប្រមូលចងក្រងឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោល

បំណងធំៗពីរគឺ ដើម្បីបម្រើដល់ការចងចាំ និងស្វែងរកយុត្តិធម៌ចំពោះអំពើដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សម្រាប់គោលបំណងធ្វើឲ្យមានការចងចាំនូវរបបកម្ពុជាប្រជាធិបតេយ្យ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូលចងក្រងជាសៀវភៅប្រវត្តិសាស្ត្រស្តីពីរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីបង្រៀនដល់សិស្សានុសិស្សនៅទូទាំងប្រទេសកម្ពុជា ។ ដូច្នេះដើម្បីធានាចំពោះការបង្រៀននេះឲ្យមានប្រសិទ្ធិភាព មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនប្រវត្តិសាស្ត្រប្រមាណជាង ៣០០០នាក់នៅទូទាំងប្រទេស ។ បន្ថែមលើនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបណ្តុះបណ្តាលដល់មន្ត្រីនគរបាល និងយោធិនមួយចំនួនធំផងដែរ ។ លោក ពៅដារ៉ា បានបញ្ជាក់យ៉ាងច្បាស់ថា គោលបំណងនៃការដាក់ឲ្យសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងកម្មវិធីសិក្សាប្រវត្តិសាស្ត្រ គឺដើម្បីឲ្យមនុស្សជំនាន់ក្រោយមានការយល់ដឹង និងចងចាំចំពោះរបបនេះក្នុងគោលបំណងធ្វើការទប់ស្កាត់ អត់ឱនឲ្យគ្នាទៅវិញទៅមក ដើម្បីទទួលបាននូវការផ្សះផ្សាជាតិ ។ ចំពោះគោលបំណងនៃការស្វែងរកយុត្តិធម៌ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងផ្តល់ឯកសារដល់បុគ្គលណាដែលមានបំណងស្វែងរកយុត្តិធម៌ជូនអ្នកដែលបានស្លាប់ ក៏ដូចអ្នកដែលបានរស់រាន់មានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។

ទោះបីជា លោក ពៅដារ៉ា បានបញ្ជាក់យ៉ាងច្បាស់ពីកម្មវត្ថុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ដោយ ប៉ុន្តែនៅតែមានភាពមន្ទិលសង្ស័យជាច្រើនពីសំណាក់មេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុមចំពោះគម្រោងមួយចំនួនដូចជា គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ គម្រោងកសាងដែនទីរណ្តៅសាកសពរួមជាដើម ។ សំណួរត្រូវបានចោទសួរឡើងថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតគម្រោងទាំងនេះដើម្បីអ្វី?

ឆ្លើយតបទៅនឹងចម្ងល់ទាំងនេះ លោក ពៅដារ៉ា បញ្ជាក់ថា គម្រោងជំរុញឲ្យមានការទទួលខុសត្រូវបានបង្កើតឡើងដើម្បីធ្វើការសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ។ តាមរយៈបទសម្ភាសន៍នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការរៀបចំចងក្រងជាសៀវភៅប្រវត្តិសាស្ត្រ ដែលបានដាក់ក្នុងកម្មវិធីសិក្សាសម្រាប់សិស្សនិស្សិត ហើយបទសម្ភាសន៍ទាំងនេះក៏ត្រូវបានទុកសម្រាប់សាធារណជនធ្វើការសិក្សាស្រាវជ្រាវផងដែរ ។

### ៤) ការប្រមូលឯកសារពាក់ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ

របៀបរបបនៃការប្រមែប្រមូលឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ត្រូវបានភាគីក្នុងរឿងក្តីសួរលម្អិតផងដែរ ។ គោលបំណងគឺដើម្បីបង្ហាញឲ្យឃើញថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានការលម្អៀងក្នុងការប្រមូលឯកសារដែរឬយ៉ាងណា ឬអាចនិយាយម្យ៉ាងទៀតថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការប្រមូលឯកសារណាដែលអាចដោះបន្ទុកឲ្យជនជាប់ចោទដែរឬទេ? ឬគ្រាន់តែរកឯកសារណាដែលអាចដាក់បន្ទុកលើជនជាប់ចោទតែប៉ុណ្ណោះ ។ បន្ថែមលើនេះថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានព្យាយាមរកឯកសារនៅក្នុងស្ថាប័នណាមួយក្រៅពីស្ថាប័នរបស់រដ្ឋាភិបាលបច្ចុប្បន្នដែរឬទេ? ជាក់ស្តែង មេធាវីរបស់ជនជាប់ចោទ អៀង សារី គឺលោក ខាណារ៉ាស់ បានចោទសំណួរថា «តើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងស្វែងរកឯកសារពាក់ព័ន្ធនឹងរបបខ្មែរក្រហម ដែលមាននៅក្នុងបណ្ណសារដ្ឋានរបស់ព្រះបាទនរោត្តម សីហនុ ដែរឬទេ?» ។ ជាងនេះទៅទៀត មេធាវីទាំងបីក្រុមសួរផ្តោតសំខាន់ថា «តើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការ ប្រមូលឯកសារដោយធ្វើការវិភាគទៅលើឯកសារណាមួយដែលអាចដាក់បន្ទុកលើជនជាប់ចោទដែរឬទេ?» និងថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការប្រមូលឯកសារយ៉ាងដូចម្តេច?

ឆ្លើយតបទៅនឹងសំណួរទាំងនេះ លោក ពៅដារ៉ា បានលើកឡើងថា ក្នុងការប្រមូលឯកសារពាក់ព័ន្ធនឹងរបបខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តនូវវិធីសាស្ត្រជាច្រើនប្រភេទ ។ ជាក់ស្តែងបន្ទាប់ពីទទួលបានការអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះធ្វើការស្រាវជ្រាវគ្រប់ទីកន្លែងទៅទូទាំងប្រទេសកម្ពុជា ទាំងក្នុងស្ថាប័នឯកជន និងស្ថាប័ននានារបស់រដ្ឋបន្ទាប់ពីបានធ្វើការទំនាក់ទំនង និងទទួលបានការយល់ព្រមពីអ្នកកាន់កាប់ស្ថាប័នទាំងនោះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការអំពាវនាវដល់ស្ថាប័នផ្សេងៗទៀតទាំងក្នុងនិងក្រៅប្រទេសឲ្យផ្តល់ឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យមកមជ្ឈមណ្ឌលឯកសារកម្ពុជា ឬឲ្យស្ថាប័នណាមួយដែលខ្លួនយល់ថាអាចនឹងរៀបចំទុកដាក់បាន ជាពិសេសគឺឲ្យមកអង្គជំនុំជម្រះវិសាមញ្ញក្នុង

តុលាការកម្ពុជាដើម្បីជាប្រយោជន៍ក្នុងការសម្រេចសេចក្ដី នៅពេលតុលាការត្រូវបានបង្កើតឡើង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានធ្វើការអំពាវនាវស្វែងរកឯកសារពាក់ព័ន្ធរបបខ្មែរក្រហមតាមរយៈទស្សនាវដ្ដីស្វែងរកការពិតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយជារៀងរាល់ខែ និងបានចែកចាយទស្សនាវដ្ដីនេះនៅទូទាំងប្រទេស និងគ្រប់ស្ថានទូតប្រចាំនៅប្រទេសកម្ពុជា ។ តាមរយៈការអំពាវនាវទាំងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារមួយចំនួនធំទាំងក្នុងនិងក្រៅប្រទេស ។ ជាក់ស្ដែង មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលឯកសារពីប្រទេសស៊ុយអ៊ែតពីបណ្ណសាររបស់សាស្ត្រាចារ្យ ឡូវ៉ា សាំមី សាស្ត្រចារ្យ ដេវីដ ឆេនដ៏ល័រ លោក ដេវីដ ហក និងមានបុគ្គលមួយចំនួនទៀតផង ។

ឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុមពាក់ព័ន្ធប្រភពឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជានឹងត្រូវធ្វើការស្រាវជ្រាវ លោក ពោជារ៉ា បានលើកឡើងថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនត្រឹមតែប្រមូលឯកសារដែលមាននៅក្នុងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានធ្វើការប្រមូលយកឯកសារមកពីគ្រប់មជ្ឈដ្ឋានដែលមានឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមលើនេះទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ធ្លាប់ទទួលបានឯកសារដែលមាននៅក្នុងបណ្ណសាររបស់ព្រះបាទ នរោត្ដម សីហនុ ដែលឯកសារទាំងនោះត្រូវបានផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់ព្រះអង្គ ។

ចំពោះការលើកឡើងរបស់មេធាវីការពារក្ដីឲ្យជនជាប់ចោទ នួន ជា និងជនជាប់ចោទ អៀង សារី ពាក់ព័ន្ធនឹងការវិភាគលើឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាន លោក ពោជារ៉ា បានលើកឡើងថា រាល់ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាននឹងមិនមានការវិភាគណាមួយឡើយ ។ ពេលមជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានវិភាគថា ឯកសារណាមួយអាចដាក់បន្ទុកលើជនជាប់ចោទ ឬឯកសារណាមួយអាចដោះបន្ទុកឲ្យជនជាប់ចោទនោះឡើយ ។ ក៏ប៉ុន្តែ អ្នកសិក្សាស្រាវជ្រាវអាចធ្វើការវិភាគនិងវាយតម្លៃលើឯកសារទាំងនោះទៅតាមការយល់ឃើញរៀងៗខ្លួន ។

បញ្ហាមួយទៀតដែលគួរឲ្យចាប់អារម្មណ៍ គឺពាក់ព័ន្ធនឹងការប្រមូលចងក្រងឯកសារដាក់លាក់តាមជនជាប់ចោទនីមួយៗ នៅក្នុងសំណុំរឿង០០២ ។ សំណួរត្រូវបានចោទសួរដោយមេធាវីរបស់ជនជាប់ចោទ នួន ជា និងត្រូវបានរំឭកដោយមេធាវីរបស់ជនជាប់ចោទ អៀង សារីម្ដងហើយម្ដងទៀតពីគោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចងក្រងឯកសារដាក់លាក់ពាក់ព័ន្ធនឹងជនជាប់ចោទទាំងបួននៅក្នុងសំណុំរឿង០០២ ។ ក្នុងការស្រាយបំភ្លឺបញ្ហានេះ លោក ពោជារ៉ា បានលើកឡើងថា លោកពិតជាបានចងក្រងឯកសារពាក់ព័ន្ធនឹងជនជាប់ចោទនីមួយៗមែន ដែលការចងក្រងបែបនេះគឺធ្វើឡើងក្នុងគោលបំណងបម្រើដល់ការសិក្សាស្រាវជ្រាវ ។ ឯកសារទាំងនេះត្រូវបានចងក្រងឡើងបន្ទាប់ពីធ្លាប់មានសំណើសុំពីអ្នកសិក្សាស្រាវជ្រាវជាបន្តបន្ទាប់ ដូចនេះរាល់ឯកសារព័ន្ធដែលអ្នកសិក្សាស្រាវជ្រាវបានស្នើសុំត្រូវបានប្រមូលចងក្រងជា «ហ្វូលឌ័រ» ដើម្បីងាយស្រួលក្នុងការផ្ដល់ឯកសារទាំងនោះឲ្យទៅអ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត ។

ហាក់ដូចជាមានការភាន់ច្រឡំគ្នាបន្តិចចំពោះសំណួរ និងចម្លើយពាក់ព័ន្ធនឹងការប្រមូលចងក្រងឯកសារដាក់លាក់នេះ ។ មេធាវីទាំងពីក្រុមរបស់ជនជាប់ចោទ នួន ជា និង អៀង សារី បានហៅឯកសារដែលបានប្រមូលចងក្រងនេះថាជា «ហ្វាល(File)» ដែលពាក្យនេះត្រូវបានអ្នកបកប្រែបកថាជា «សំណុំរឿង» ។ ដូចនេះលោក ពោជារ៉ា យល់ថាមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមានឯកសារជាសំណុំរឿងរបស់ជនជាប់ចោទនីមួយៗនោះទេ គឺមានតែឯកសារពាក់ព័ន្ធនឹងជនជាប់ចោទនីមួយដែលត្រូវបានចងក្រងទុក បន្ទាប់ពីមានសំណើសុំដែលការចងក្រងបែបនេះលោកហៅថាជា «ហ្វូលឌ័រ(Folder)» ។

## ៥) ភាពត្រឹមត្រូវនៃឯកសារ

ការសួរដេញដោលលើយថាភាពនៃឯកសារ (ភាពពិតប្រាកដនៃឯកសារ) គឺជាបញ្ហាសំខាន់ដែលភាគីនៃរឿងក្ដីបានសួរម្ដងហើយម្ដងទៀត ដើម្បីបង្ហាញឲ្យឃើញថាមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការប្រមូលឯកសារពាក់ព័ន្ធនឹងរបបខ្មែរក្រហមបានត្រឹមត្រូវកម្រិតណា ។ ជាក់ស្ដែងក្នុងកំឡុងពេលសវនាការ ភាគីទាំងអស់បានសួរដោយផ្ដោតសំខាន់ទៅលើប្រភព និងច្បាប់ដើម

នៃឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ឲ្យឃើញថា ឯកសារទាំងនោះពិតជាត្រូវបានធ្វើឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមលើនេះភាគីនៃរឿងក្ដីសួរសង្កត់ធ្ងន់លើវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាយកមកប្រើប្រាស់ក្នុងការវាយតម្លៃពីយថាភាពនៃឯកសារ ។

ឆ្លើយតបទៅនឹងការចោទសួរទាំងនេះ លោក ពៅដារ៉ា បានលើកឡើងថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលការណ៍ណែនាំច្បាស់លាស់ក្នុងការទទួលយកឯកសារ ពោលរាល់ការទទួលយកឯកសារពីស្ថាប័នណាមួយ ឬពីបុគ្គលណាម្នាក់ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសួរនាំពីប្រភពដើមនៃឯកសារនោះជានិច្ច ហើយការសួរនាំបែបនេះត្រូវបានអនុវត្តចាប់តាំងពីដំបូងរហូតមកដល់ពេលបច្ចុប្បន្ន ។ លោក ពៅដារ៉ា បានបន្ថែមថា ក្នុងការធ្វើយថាភាពនៃឯកសារ គឺលោកបានធ្វើការអានខ្លឹមសារទាំងស្រុងរបស់ឯកសារ ពិនិត្យការប្រើប្រាស់ពាក្យពេចន៍ កាលបរិច្ឆេទនៃការធ្វើឯកសារ ប្រភេទនិងពណ៌របស់ក្រដាសឯកសារដើម្បីឲ្យប្រាកដថាពិតជាឯកសារដែលបានធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែងក្នុងការប្រមូលឯកសារមកពីបណ្ណសារដ្ឋានជាតិ លោក ពៅដារ៉ា បានសួរនាំពីប្រភពដំបូងនៃឯកសារទាំងនោះមុននឹងត្រូវបានយកមកតម្កល់ទុកនៅក្នុងបណ្ណសារដ្ឋានជាតិនេះ ។ និយាយឲ្យខ្លី រាល់ឯកសារទាំងអស់ត្រូវបានធ្វើយថាភាពយ៉ាងត្រឹមត្រូវ ហើយបន្ទាប់ពីបានធ្វើយថាភាពរួចហើយ ឯកសារទាំងនេះត្រូវបានថតចម្លងទាំងស្រុង ដែលឯកសារថតចម្លងនេះនឹងត្រូវធ្វើការចុះលេខសម្គាល់ដោយមានបញ្ជាក់ពីប្រភពនៃឯកសារថតចម្លងនេះដើម្បីមានភាពងាយស្រួលក្នុងការស្វែងរកឯកសារដើម ។

## ៦) របៀបនៃការចងក្រង និងថែរក្សាទុកឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

របៀបនៃការចងក្រង និងថែរក្សាឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាន ត្រូវបានភាគីទាំងអស់លើកយកមកសួរដេញដោល ដើម្បីបង្ហាញឲ្យឃើញពីសមត្ថភាពក្នុងការគ្រប់គ្រងឯកសារ និងភាពមិនលម្អៀងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការដាក់បង្ហាញឯកសាររបស់ខ្លួនជាសាធារណៈ ដើម្បីឲ្យសាធារណជនស្រាវជ្រាវ ។ បន្ថែមលើនេះ សំណួរជាច្រើនដែលភាគីបានសួរគឺក្នុងគោលបំណងចង់ដឹងថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើចំណារណាមួយនៅលើឯកសារដែលខ្លួនទទួលបាននៅក្នុងកំឡុងពេលធ្វើការចងក្រងដែរឬទេ?

ឆ្លើយតបទៅនឹងសំណួរទាំងនេះ លោក ពៅដារ៉ា បានលើកឡើងថា ក្នុងការចងក្រងឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការបែងចែកជាប្រាំប្រភេទ ។ ប្រភេទទីមួយគឺជាប្រភេទឯកសារដែលមានលក្ខណៈជាប្រភេទសន្លឹកក្រដាស ។ ឯកសារទាំងនេះមានប្រមាណជិតមួយលានទំព័រ ហើយមានជាច្រើនភាសារួមមានភាសាខ្មែរ ភាសាអង់គ្លេស ភាសាស៊ុយអែត ភាសាអាល្លឺម៉ង់ និងមានភាសាមួយចំនួនទៀត ដែលមានខ្លះជាច្បាប់ដើម និងខ្លះទៀតជាច្បាប់ថតចម្លង ។ ប្រភេទទីពីរជាប្រភេទឯកសារបទសម្ភាសន៍ ដែលឯកសារប្រភេទនេះបានមកតាមរយៈការចុះទៅធ្វើសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរួមមានទាំងជនរងគ្រោះ និងកម្មាភិបាលខ្មែរក្រហម ។ ប្រភេទទីបីជាប្រភេទឯកសារទាក់ទងនឹងរូបថតសម័យខ្មែរក្រហម ដែលរូបថតទាំងនេះត្រូវបានរក្សាទុកយ៉ាងប្រយ័ត្នប្រយែងបំផុត ។ ប្រភេទទីបួនជាប្រភេទឯកសារទាក់ទងនឹងការធ្វើផែនទីរណ្តៅសាកសពរួម ដែលឯកសារទាំងនេះបង្ហាញពីរណ្តៅសាកសពដែលជាអតីតមន្ទីរសន្តិសុខ ឬជាកន្លែងបូជនីយដ្ឋានអំឡុងក្រោយរបបខ្មែរក្រហម ។ រីឯប្រភេទចុងក្រោយជាប្រភេទឯកសារទាក់ទងនឹងខ្សែភាពយន្ត ដែលឯកសារទាំងនេះត្រូវបានផលិតក្នុងរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហម ។

ចំពោះការធ្វើចំណាត់ថ្នាក់ឯកសារ លោក ពៅដារ៉ា បានលើកឡើងថា រាល់ឯកសារទាំងអស់ត្រូវបានចុះលេខសម្រាប់សម្គាល់ឯកសារនីមួយៗ ដើម្បីងាយស្រួលសម្រាប់អ្នកសិក្សាស្រាវជ្រាវក្នុងការស្វែងរកឯកសារ ។ មានន័យថារាល់ឯកសារទាំងអស់ត្រូវបែងចែកទៅតាមប្រភេទនីមួយៗ ដែលមានផ្តើមដោយអក្សរជាភាសាអង់គ្លេសមួយខ្ទង់ និងអមដោយលេខចំនួនប្រាំខ្ទង់ ហើយធ្វើការចុះជាបន្តបន្ទាប់ គ្នាដើម្បីជៀសវៀងការចុះលេខស្ទួនគ្នា ។ លោក ពៅដារ៉ា បានបញ្ជាក់យ៉ាងច្បាស់ថា រាល់ការចុះលេខឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនបានចុះលេខ

សម្គាល់ណាមួយលើឯកសារដើមឡើយ ឬអាចនិយាយម្យ៉ាងទៀតថា "មិនមានការចុះលេខសម្គាល់លើឯកសារណាមួយក្រៅពីឯកសារថតចម្លងឡើយ" ។ បន្ថែមលើនេះទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មិនដែលបានធ្វើចំណារណាមួយលើឯកសារដែលប្រមូលបានឡើយ ពោលគឺមជ្ឈមណ្ឌលឯកសារកម្ពុជាបានរក្សាសភាពដើមរបស់ឯកសារដោយមិនឲ្យមានការប៉ះពាល់ឡើយ ។ ជាងនេះទៅទៀត រាល់ឯកសារដើមដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានត្រូវបានរក្សាទុកនៅកន្លែងមានសុវត្ថិភាពដែលមានសីតុណ្ហភាពអាចរក្សាសភាពដើមរបស់ឯកសារបាន ។

## ៧) ការផ្តល់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ការផ្តល់ឯកសារដល់សាធារណជន ក៏ដូចជាការផ្តល់ឯកសារជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាកត្តាសំខាន់ដែលបង្ហាញពីឯករាជ្យភាព និងភាពមិនលម្អៀងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សំណួរជាច្រើនដែលភាគីបានចោទសួរនោះគឺថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានភាពលម្អៀងដែរឬទេក្នុងការផ្តល់ឯកសារដល់ការិយាល័យនីមួយៗរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ជាងនេះទៅទៀត រាល់ឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបានត្រូវបានដាក់បង្ហាញឲ្យសាធារណជនអាចធ្វើការសិក្សាស្រាវជ្រាវ និងយកទៅប្រើប្រាស់បានដែរឬទេ ។ និយាយឲ្យខ្លីក្នុងនាមជា ស្ថាប័នសិក្សាស្រាវជ្រាវឯករាជ្យមួយតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានការលាក់កំបាំងឯកសារណាមួយដែលជាផលប្រយោជន៍ក្នុងការសិក្សាពីរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ ។

ឆ្លើយតបទៅនឹងបញ្ហាចោទទាំងនេះ លោក ពៅដារ៉ា បានលើកឡើងថា រាល់ឯកសារទាំងអស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាននឹងត្រូវធ្វើការចងក្រងទៅតាមប្រភេទនៃឯកសារនោះ ហើយឯកសារទាំងនេះនឹងត្រូវផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សាធារណជនអាចធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារដែលមាននៅក្នុងគេហទំព័រនេះ ឬអាចមកមជ្ឈមណ្ឌលឯកសារកម្ពុជាដោយផ្ទាល់ក្នុងករណីមានការស្នើសុំឯកសារណាមួយដែលខ្លួនចង់បានដោយមិនមានកម្រិតលក្ខខណ្ឌណាមួយឡើយ ។

ចំពោះឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ជូនតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម លោក ពៅដារ៉ា បានបញ្ជាក់យ៉ាងច្បាស់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារជូនអង្គភាពនីមួយៗរបស់តុលាការតាមរយៈការស្នើសុំរបស់ការិយាល័យទាំងនោះ ។ ជាក់ស្តែងតាមរយៈការស្នើសុំនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារជូនការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យគាំពារជនរងគ្រោះ និងការិយាល័យគាំពារការការពារក្តីជនជាប់ចោទ ។ បន្ថែមលើនេះទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកពេលវេលាសម្រាប់ឲ្យអង្គភាពនីមួយៗរបស់តុលាការមកធ្វើការសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារដោយផ្ទាល់នៅការិយាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីឲ្យការិយាល័យទាំងអស់របស់តុលាការមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ និយាយឲ្យខ្លី ការិយាល័យនីមួយៗទទួលបានឯកសារតិច ឬច្រើន គឺអាស្រ័យលើការស្នើសុំរបស់ការិយាល័យនោះផ្ទាល់ ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមិនដែលធ្វើការជិទាស់ក្នុងការផ្តល់ឯកសារណាមួយដែលខ្លួនមាននៅពេលមានភាគីណាមួយបានស្នើសុំនោះឡើយ ។

សរុបសេចក្តីមកក្នុងរយៈពេលសវនាការចំនួនបីថ្ងៃពេញ លោក ពៅដារ៉ា បានបញ្ជាក់យ៉ាងច្បាស់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការងាររបស់ខ្លួនដោយឯករាជ្យ ដោយមិនមានការបង្គាប់បញ្ជាពីមជ្ឈដ្ឋានណាមួយឡើយ ។ ហើយកិច្ចការដែលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើ គឺក្នុងគោលបំណងបម្រើការចងចាំ និងស្វែងរកយុត្តិធម៌ចំពោះអំពើដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូចនេះ រាល់ឯកសារដែលមជ្ឈមណ្ឌលប្រមូលបាន នឹងត្រូវផ្តល់ឲ្យ និងបើកទូលាយសម្រាប់សាធារណជនធ្វើការសិក្សាស្រាវជ្រាវដោយមិនមានការលាក់កំបាំងឡើយ ។

បន្ទាប់ពីការបញ្ចប់ការធ្វើសក្ខីកម្មរបស់លោក វ៉ាន់ថាន់ ពៅដារ៉ា នៅរសៀលថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានកោះហៅសាក្សីម្នាក់ទៀតឈ្មោះ ប្រាក់ យុទ មកធ្វើការសាកសួរដេញដោល នៅក្នុងអង្គសវនាការស្តីពីរចនាសម្ព័ន្ធប្រវត្តិបក្សកុម្មុយនីស្ត និងតួនាទីរបស់ជនជាប់ចោទ ។

## ■ សវនាការស្ដីពីការសួរដេញដោលលើសាក្សី ប្រាក់ យុត ថ្ងៃទី ២៥,២៦,៣០ ខែមករា ឆ្នាំ២០១២

### សេចក្ដីផ្ដើម

នៅថ្ងៃទី២៥-២៦ និង៣០ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្ដាប់សក្ខីកម្មរបស់សាក្សី ប្រាក់ យុត ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំពីប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា តួនាទីជនជាប់ចោទម្នាក់ៗ និងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

សវនាការស្ដាប់សក្ខីកម្មរបស់សាក្សី ប្រាក់ យុត ត្រូវបានអង្គជំនុំជម្រះកម្រិតឲ្យភាគីនីមួយៗតាំងសំណួរទាក់ទងនឹងអង្គហេតុដែលនឹងត្រូវជំនុំជម្រះក្នុងដំណាក់កាលដំបូង ឬហៅម្យ៉ាងទៀតថា សំណុំរឿង០០២/១តែប៉ុណ្ណោះ ។

### ១) ការផ្ដល់សក្ខីកម្មរបស់សាក្សីចំពោះសំណួរសហព្រះរាជអាជ្ញា

បន្ទាប់ពីប្រធានអង្គជំនុំជម្រះបានតាំងសំណួរមួយចំនួនដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់សាក្សី ប្រាក់ យុត និងផ្ដល់ការណែនាំអំពីសិទ្ធមួយចំនួនរបស់សាក្សីក្នុងការធ្វើសក្ខីកម្មរួចមក តំណាងសហព្រះរាជអាជ្ញាជាតិគឺលោក សេង ប៊ុនឃាង បានចាប់ផ្ដើមតាំងសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិនៃការចូលរួមបដិវត្តន៍ ។ តាមរយៈសំណួរទាំងនោះលោកស្រី ប្រាក់ យុត បានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនបានចូលរួមក្នុងចលនាបដិវត្តក្នុងឆ្នាំ១៩៧០ ដែលពេលនោះលោកស្រីនៅតូច មិនបានដឹងថាមូលហេតុនៃការចូលរួមក្នុងបដិវត្តនោះជាអ្វីឡើយ គឺគ្រាន់តែចូលតាមគេប៉ុណ្ណោះ ហើយមិនបានសិក្សាអំពីគោលនយោបាយរបស់បក្សអ្វីទាំងអស់ ។ ពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៦ លោកស្រីមានឋានៈជាសមាជិកទី៦ នៃតំបន់៣៥ ដែលកាលនោះមាន កង ចាប ធ្វើជាលេខាតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក គណៈភូមិភាគនិរតី ។ នៅក្នុងកំឡុងពេលនោះ លោកស្រីមានតួនាទីជាប្រធានកងចល័តនៅស្រុកឈូក ដែលមានសមាជិកប្រមាណ៥០០នាក់ ។ លោកស្រីក៏ធ្លាប់បំរើការងារក្នុងតួនាទីទទួលបន្ទុកខាងកិច្ចការនារីទៀតផង ។

នៅឆ្នាំ១៩៧៧ កង ចាប បានបញ្ជូនលោកស្រីទៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ស្ថិតក្នុងភូមិភាគកណ្ដាលដែលត្រូវបានគ្រប់គ្រងដោយ កែ ពក ។ ក្នុងកំឡុងពេលនោះ លោកស្រីមានតួនាទីជាលេខាស្រុកកំពង់សៀម និងជាសមាជិកទី៤នៃតំបន់៤១ ដែលស្ថិតនៅក្នុងភូមិភាគកណ្ដាល ។ ក្នុងនាមជាលេខាស្រុក លោកស្រីធ្លាប់ធ្វើជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខនៅស្រុកកំពង់សៀម ដែលមន្ទីរសន្តិសុខនេះគឺជាកន្លែងសម្រាប់ធ្វើការអប់រំដល់អ្នកដែលបានធ្វើខុស ។

ចំពោះការរាយការណ៍ ក្នុងឋានៈជាលេខាស្រុកកំពង់សៀម លោកស្រី ប្រាក់ យុត បានរៀបចំធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនទៅលេខាតំបន់តាមរយៈនិរសាជារៀងរាល់មួយខែម្ដង ដែលក្នុងរបាយការណ៍នោះ បានរាយការណ៍ទៅលេខាតំបន់អំពីការអនុវត្តការងារនៅក្នុងស្រុកជាបន្តបន្ទាប់ និងហេតុការណ៍ផ្សេងៗដែលកើតមានឡើងនៅក្នុងកន្លែងរបស់ខ្លួនគ្រប់គ្រង ។ បន្ថែមលើនេះទៀត លោកស្រីបានបញ្ជាក់ថា លោកស្រីបានចូលរួមប្រជុំជាមួយគណៈភូមិភាគ កែ ពក និងលេខាតំបន់ផ្សេងៗជាញឹកញាប់



សាក្សី ប្រាក់ យុត

នៅមន្ទីរភូមិភាគក្នុងក្រុងកំពង់ចាម ។ ជាទូទៅការប្រជុំទាំងនោះពិភាក្សាអំពីការងារប្រចាំថ្ងៃដូចជាការលើកទំនប់ ការជីកប្រឡាយ ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន និងបញ្ហាផ្សេងៗ ដើម្បីឲ្យភូមិភាគជាអ្នកជួយដោះស្រាយ ។

ក្រោយមកនៅឆ្នាំ១៩៧៨ លោកស្រីត្រូវបាន តាម៉ុក បញ្ជូនទៅភូមិភាគពាយ័ព្យ ដែលពេលនោះលោកស្រីត្រូវបានចាត់តាំងឲ្យមើលការខុសត្រូវលើចម្ការកប្បាស ដោយមិនមានតំណែងអ្វីដូចកាលពីមុនទេ ។ ការដកហូតតំណែងរបស់លោកស្រីដោយផ្ទេរពីភូមិភាគកណ្តាលទៅភូមិភាគពាយ័ព្យនេះបានធ្វើឡើងបន្ទាប់ពីប្តីរបស់លោកស្រីត្រូវបានចាប់ខ្លួន ។ ពាក់ព័ន្ធនឹងការចាប់ប្តីរបស់លោកស្រី ប្រាក់ យុត តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោក ខេល លីសាក់ បានសួរថា *«លោកស្រីបានឆ្លើយជាច្រើនដងរួចមកហើយដែលថា លោកស្រីបានទទួលការណែនាំ និងបង្គាប់ទាំងឡាយដែលបានផ្តល់ជូនមកដល់លោកស្រីដូចជា តាម៉ុក ជាដើម ដែលបានផ្តល់ការបង្គាប់ ហើយថាតើលោកស្រីអាចរៀបរាប់បានឬទេ ប្រសិនបើមិនស្តាប់បង្គាប់របស់ថ្នាក់លើ តើយ៉ាងម៉េចដែរ?»* ឆ្លើយតបនឹងសំណួរនេះ សាក្សី ប្រាក់ យុត លើកឡើងថា *«ខ្ញុំសូមបញ្ជាក់ថា គឺដូចមានការណែនាំរបស់ខាងលើ (តាម៉ុក) ពេលចាប់ប្តីខ្ញុំ បើសិនជាខ្ញុំមានការប្រឆាំង ឬទំនាស់ គឺខ្ញុំមិនហ៊ានដែរ ព្រោះសម័យនោះលោកក៏ដឹងដែរ ខ្ញុំមិនហ៊ាននិយាយអីទាំងអស់ និយាយរួមគឺថា បញ្ហាម៉េចគឺធ្វើតាមបញ្ជារបស់ថ្នាក់លើនេះខ្ញុំនិយាយត្រង់ ។ ខ្ញុំអត់ហ៊ាននិយាយអីទេ ព្រោះគាត់ប្រាប់មកខ្ញុំ ខ្ញុំអត់ហ៊ាននិយាយជាមួយប្តីខ្ញុំផង ។ ខ្ញុំមិនហ៊ាននិយាយអី ក្រៅពីផ្លូវការដែលគាត់ណែនាំនោះទេ កាលណាគាត់ណែនាំម៉េចគឺខ្ញុំធ្វើអញ្ចឹង ហើយកាលណាខ្ញុំនិយាយខុស ប្តីរត់បាត់ នោះខ្ញុំមានរឿង»* ។



ខេល លីសាក់ តំណាង
សហព្រះរាជអាជ្ញាអន្តរជាតិ

**២) ការផ្តល់សក្ខីកម្មរបស់សាក្សីចំពោះសំណួរសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបានសួរចប់សព្វគ្រប់លើសាក្សី លោកមេធាវី សំ សុគង់ តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការតាំងសំណួរមួយចំនួនទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធរាយការណ៍ថែមទៀត ។ ឆ្លើយតបទៅនឹងការចោទសួរនេះ សាក្សី ប្រាក់ យុត បានផ្តល់សក្ខីកម្មថា ប្រព័ន្ធចាត់តាំងការងារ និងប្រព័ន្ធរាយការណ៍នៅរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើឡើងដើម្បីធានាថា ផែនការណ៍ដែលថ្នាក់លើបានដាក់ចុះត្រូវបានអនុវត្ត ។ ពាក់ព័ន្ធនឹងការដាក់ផែនការណ៍ឲ្យអនុវត្ត សាក្សីលើកឡើងថា គណៈភូមិភាគជាអ្នកដាក់ផែនការណ៍ឲ្យគណៈតំបន់ ហើយគណៈតំបន់ត្រូវបញ្ជូនបន្តទៅគណៈស្រុកនីមួយៗរបស់ខ្លួន ។ បន្ទាប់ពីទទួលបានផែនការណ៍ គណៈស្រុកត្រូវផ្សព្វផ្សាយទៅតាមឃុំនីមួយៗរបស់ខ្លួន ។ ជាក់ស្តែងសាក្សីបញ្ជាក់ថា តាម៉ុក ដែលជាលេខាភូមិភាគនិរតី បានដាក់ផែនការណ៍ឲ្យ កង ចាប ដែលជាលេខាតំបន់៣៥ ដើម្បីធ្វើការផ្សព្វផ្សាយបន្ត ។ ក្នុងនាមជាសមាជិកទី៦នៃគណៈតំបន់៣៥ ខ្លួន(សាក្សី ប្រាក់ យុត) ត្រូវចូលរួមប្រជុំជាមួយគណៈស្រុក ដើម្បីធ្វើការណែនាំផែនការណ៍ដែលត្រូវអនុវត្ត ។ សាក្សីក៏ធ្លាប់បានទទួលផែនការណ៍រៀបចំចាត់ចែងការងារពី កែ ពក ជាលេខាភូមិភាគកណ្តាលដែរ ដែលកាលនោះខ្លួនមានតួនាទីជាលេខាស្រុកកំពង់សៀម និងជាសមាជិកទី៤នៃគណៈតំបន់៤១ របស់ភូមិភាគកណ្តាល ។ តែទោះបីជាយ៉ាងនេះក្តី សាក្សីមិនបានដឹងថា មានការដាក់ផែនការណ៍ពីលើមកថ្នាក់ភូមិភាគដែរ ឬយ៉ាងណានោះឡើយ ។ តែចំណុចមួយគួរឲ្យកត់សម្គាល់នោះ សាក្សីបានលើកឡើងថា ខ្លួនធ្លាប់បានឃើញទស្សនាវដ្តីទង់បដិវត្តមាននៅមន្ទីររបស់គណៈតំបន់៣៥ ដែលដាក់នៅផ្ទះរបស់លេខាតំបន់ឈ្មោះ កង ចាប ។

ពាក់ព័ន្ធនឹងការរាយការណ៍ សាក្សី ប្រាក់ យុត លើកឡើងថា ឃុំទាំងអស់ត្រូវរាយការណ៍ទៅស្រុករបស់ខ្លួន ហើយស្រុករាយការណ៍ទៅតំបន់ និងតំបន់រាយការណ៍ទៅភូមិភាគ ពោលគឺ

ឃុំនីមួយៗ ត្រូវរាយការណ៍ពីលទ្ធផលដែលខ្លួនបានធ្វើទៅស្រុក ដើម្បីជាព័ត៌មាន ។ កម្មវត្ថុនៃការរាយការណ៍ត្រូវបានរួមបញ្ចូលនូវស្ថានភាពក្នុងឃុំរបស់ខ្លួនដូចជា ភាពទុកលំបាករបស់ប្រជាជន ការខ្វះខាតអាហារបរិភោគ ស្ថានភាពអ្នកជំងឺនិងអ្នកស្លាប់ និងអ្នកដែលធ្វើខុសសីលធម៌ជាដើម ។ សាក្សីបញ្ជាក់យ៉ាងច្បាស់ថា ស្រុកទទួលបានរបាយការណ៍ជាប្រចាំខែពីឃុំ ពោលគឺស្រុកមានការប្រជុំជាប្រចាំខែដើម្បីត្រួតពិនិត្យការងារដែលបានដាក់ឲ្យឃុំអនុវត្ត ។ ចំណែកតំបន់មានការប្រជុំប្រចាំខែ ដើម្បីត្រួតពិនិត្យការងារដែលបានដាក់ឲ្យស្រុកធ្វើ និងរាយការណ៍បន្តទៅថ្នាក់ភូមិភាគ ។ តែទោះបីជាយ៉ាងណា សាក្សីមិនបានដឹងថាមានការរាយការណ៍ពីថ្នាក់ភូមិភាគទៅគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍ដែរ ឬយ៉ាងណានោះទេ ។

**៣) ការផ្តល់សក្ខីកម្មរបស់សាក្សីចំពោះសំណួរក្រុមមេធាវីការពារក្តី**

នៅរសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ បន្ទាប់ពីការសួរចម្លើយជនជាប់ចោទ នួន ជា នៅពេលព្រឹករួចមក ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទបានបន្តការតាំងសំណួរទៅសាក្សី ប្រាក់ យុត ។ មានតែក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា តែប៉ុណ្ណោះដែលធ្វើការសាកសួរដេញដោលលើសាក្សី ប្រាក់ យុត ។ លោកមេធាវីអន្តរជាតិ ម៉ៃឃើល ដេស្តមេន បានតាំងសំណួរអំពីសមាជិកនៅក្នុងតំបន់៣៥ និងសមាជិកនៅតំបន់១៣ ។ តាំងពីដំបូងលោកស្រី ប្រាក់ យុត បានឆ្លើយថាខ្លួនជាសមាជិកទី៦នៅតំបន់៣៥ មាន៦នាក់ គឺ តាផន តាសៀន តាទី តាកុត តាណយ និងលោកស្រីផ្ទាល់ ។ ប៉ុន្តែសមាជិកទាំងនោះបានស្លាប់អស់ទៅហើយ នៅសល់តែលោកស្រីម្នាក់ប៉ុណ្ណោះ ។ នៅពេលដែលមេធាវីបានលើកឈ្មោះ តាអាន ដែលកាលនោះក៏ស្ថិតក្នុងតំបន់៣៥នោះដែរ ពេលនោះសាក្សីបានឆ្លើយដោយភាពប្រហាក់ប្រហែលថាខ្លួនមិនចាំឈ្មោះតាអាននេះទេ ដោយសារនៅតំបន់៣៥ មានសមាជិករហូតដល់ទៅ៨-៩រូបឯនោះ ។ បើតាមចម្លើយរបស់លោកស្រី ប្រាក់ យុត នៅតំបន់៤១ តាអានគឺជាប្រធានរបស់គាត់ ។ មេធាវីបានសួរដេញដោលលើសាក្សីដោយភាពសង្ស័យចំពោះចម្លើយទាក់ទងទៅនឹងឈ្មោះ អាន នេះ ។ ជាក់ស្តែងមេធាវីបានព្យាយាមជជីកសួរអំពីទំនាក់ទំនងរបស់សាក្សីជាមួយបុគ្គលម្នាក់នេះម្តងហើយម្តងទៀត ប៉ុន្តែសាក្សីបានឆ្លើយថាខ្លួនមិនមានទំនាក់ទំនងជាមួយតាអានឡើយរហូតមកដល់ពេលនេះ ហើយសូម្បីតែ តាអាន រស់ ឬស្លាប់ក៏ខ្លួនមិនបានដឹងដែរ ។ ក្រោយពីសួរទំនាក់ទំនងរវាងសាក្សីជាមួយ តាអាន មេធាវីក៏សួរផ្តោតសំខាន់ចំពោះទំនាក់ទំនងរវាងសាក្សី និងលោកស្រី អ៊ឹម ចែម ថែមទៀត ។ ឆ្លើយតបនឹងការចោទសួរនេះ សាក្សីអះអាងថា លោកស្រី អ៊ឹម ចែម គឺជាសមាជិករបស់តំបន់១៣ ។ សាក្សីបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនមិនដែលមានទំនាក់ទំនងអ្វីជាមួយលោកស្រី អ៊ឹម ចែម ឡើយ ។

ខណៈដែលមេធាវីកំពុងតែជជីកសួរសាក្សីពីបញ្ហាសំណុំរឿង ០០៤ លោកប្រធានអង្គជំនុំជម្រះ បានធ្វើអន្តរាគមន៍មិនឲ្យសាក្សី ប្រាក់ យុត ឆ្លើយតបនឹងសំណួរនោះឡើយ ។ លោកប្រធានចៅក្រមបានផ្តល់ហេតុផលថា សំណួរនោះមិនទាក់ទងនឹងករណីសំណុំរឿង០០២ ដែលនឹងត្រូវជំនុំជម្រះក្នុងដំណាក់កាលទីមួយនេះឡើយ ។ ទោះបីជាមានការរំឭកពីលោកប្រធានអង្គជំនុំជម្រះយ៉ាងនេះក្តី ក៏មេធាវីនៅតែព្យាយាមបញ្ចេញអត្តសញ្ញាណរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង០០៤ ដើម្បីសួរទៅសាក្សីដដែល ។ មេធាវីថែមទាំងបានតវ៉ានឹងសហចៅក្រមអន្តរជាតិទៀតថាសំណួរដែលខ្លួនសួរនោះមានការជាប់ទាក់ទងគ្នាទៅនឹងសំណុំរឿង០០២ ។ លោកមេធាវីបានលើកឡើងថា សាក្សី ប្រាក់ យុត ហាក់ដូចជាមិនបង្ហាញអំពីការផ្តល់សក្ខីកម្មដោយសេរីនោះទេ ។ ភ្លាមនោះ លោកស្រីចៅក្រមអន្តរជាតិ ស៊ីលវៀ ខាតវ៉្រាយត៍ បានធ្វើការតាំងសំណួរមួយចំនួនទៅកាន់សាក្សី ប្រាក់ យុត ថាតើមានការគាបសង្កត់ណាមួយមកលើលោកស្រីមុនពេលមកផ្តល់សក្ខីកម្មនេះដែរទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីអះអាងថា ខ្លួនមិនបានទទួលការគំរាមកំហែងណាមួយឡើយ ប៉ុន្តែអ្វីដែលខ្លួនអាចឆ្លើយបានគឺអាស្រ័យលើការចងចាំតែប៉ុណ្ណោះ ។

នៅរសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់សវនាលើការសួរដេញដោលសាក្សី ប្រាក់ យុត ។ ការបញ្ចប់នេះហាក់ដូចជាធ្វើឡើងមុនពេលគ្រោងទុកបន្តិច ដោយសារតែក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី និងក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន មិនមានសំណួរចោទសួរទៅកាន់សាក្សី ប្រាក់ យុត ។

**ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ម៉ាន់ថាន់ ពៅដារ៉ា**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : *dccam@online.com.kh*

គេហទំព័រ : *www.dccam.org* ឬ *www.cambodiatribunal.org*

គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ

*John D. and Catherine T. MacArthur Foundation and*

*British Embassy-Cambodia* ។




**ឆាយ ឈុនលី**

**ឈុនលី** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ឌី សុជាតា**

**សុជាតា** ជានិស្សិតថ្នាក់ បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យទ័ត្ត**

**ជ័យទ័ត្ត** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទ័ត្ត ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ចាន ប្រាថ្នា**

**ប្រាថ្នា** ទទួលបាន បរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវីនៅកម្ពុជា ។











មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែមីនា ឆ្នាំ២០១២